ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ខៀវ សំផន
- ខៀវ សំផន

លេខ៨៦ ខែកុម្ភៈ ឆ្នាំ២០០៧

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៦ ខែកុម្ភៈ ឆ្នាំ២០០២




អ្នកទោសមន្ទីរស-២១ សុក ម៉ុច

## មាតិកា


◆ សំបុត្រ៖ កម្ពុជាអាចនឹងគ្មានយុត្តិធម៌ជារៀងរហូត ........................១

**ផ្នែកឯកសារ**

◆ សេចក្ដីសម្រេចរបស់គណៈមជ្ឈិម ............................................២

◆ បទយកការណ៍ពិសេស ....................................................៦

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍ ................................៩

◆ គោលនយោបាយប្រឆាំងខ្មែរក្រហម ......................................១១

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ ..........១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រូបថតឯកសារ ..............................................................១៧

◆ សម្លេងពីមន្ទីរ ស-២១ ....................................................១៩

◆ ខៀវ សំផនៈ រឿងនេះជាអំពើឃោរឃៅផ្ទាល់របស់បុគ្គល ........២៣

◆ សង្គមបរិសុទ្ធដែលគ្មានក្រដាសប្រាក់ ....................................២៥

**ផ្នែកច្បាប់**

◆ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ....................................៣២

◆ តុលាការនៅទីម័រខាងកើត ..................................................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ អង្គការសហប្រជាជាតិមិនចូលរួមកាត់ទោស ............................៣៩

◆ ប្រសាសន៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន.................៤៥

◆ សេចក្ដីដកស្រង់អំពីសន្និសីទកាសែត ឯកឧត្តម សុខ អាន...........៤៧

◆ ការរសាយចិត្តនិងការផ្សះផ្សា ..............................................៥៣

◆ ការស្ទាបស្ទង់មតិអ្នកអានទស្សនាវដ្ដីស្វែងរកការពិត ................៥៥

◆ អង្គការសហប្រជាជាតិចាំបាច់.................................................៥៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រលោមលោកបដិវត្តខ្មែរក្រហមៈ ពលិកម្មម៉ែៗយើង ..............៦០

**សិល្បៈខ្មែរក្រហមៈ**

◆ កងទ័ពបដិវត្តន៍ប្រយុទ្ធបង្កបង្កើនផល .........................ក្របក្រោយ



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ៖*** *អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ដេវីដ ឆេនដល័រ, ស៊ូហ្សាណា លីនតុន, ពីធ័រ ម៉ាគ្វាយ, ហ្រ្វេដ អេកហាដ, អៀ ម៉េងទ្រី, ហ៊ុយ សោភ័ណ, ហ៊ុយ វណ្ណៈ,* ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** *លី សុផល, ដួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយកៈ*** *សាន់ កល្យាណ* ***និពន្ធនាយករងទី១ៈ*** *ស្លូ ប៊ុនស៊ូ* ***និពន្ធនាយករងទី២ៈ*** *សឹម សុរិយ៉ា* ***អ្នកបកប្រែៈ*** *អេង គុកថាយ* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *សុខ វណ្ណៈ*

*សំបុត្រៈ*

# កម្ពុជាអាចនឹងគ្មានយុត្តិធម៌ជារៀងរហូត

ខ្មែរក្រហមបានប្រព្រឹត្តខក្រិដ្ឋកម្មរាប់លានករណីមកលើប្រជាជនកម្ពុជា ដែលជាខក្រិដ្ឋកម្មមិនទាន់ត្រូវបានវិនិច្ឆ័យក្តីនិងមិនទាន់ត្រូវបានផ្តន្ទាទោសតាមច្បាប់ ។ ខ្មែរក្រហមបានរត់គេចពីការទទួលខុសត្រូវដោយនាំយកទៅជាមួយនូវអំពើមនុស្សឃាតជាប់នឹងខ្លួន ។ **ពិភពលោកមិនត្រូវបោះបង់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការនាំមេដឹកនាំខ្មែរក្រហមមកកាត់ទោសនោះទេ ។**

ដំណើរការស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជាហាក់បីដូចជាកំពុងតែធ្វើដំណើរបញ្ច្រាសទិស ។ ក្រោយពេលមានការចរចាអស់រយៈពេលជាច្រើនឆ្នាំមក នៅថ្ងៃសុក្រទី៨ ខែកុម្ភៈ អង្គការសហប្រជាជាតិប្រកាសថាខ្លួននឹងបញ្ឈប់កិច្ចខិតខំប្រឹងប្រែងក្នុងការឈានដល់កិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃនេះ ស្តីអំពីការបង្កើតតុលាការមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។

ទោះបីជារដ្ឋាភិបាលកម្ពុជានិយាយថាខ្លួននឹងបន្តដំណើរទៅមុខប្រសិនបើចាំបាច់យ៉ាងណាក៏ដោយ ក៏អង្គការសហប្រជាជាតិនិងកម្ពុជាត្រូវតែបន្តការពិភាក្សារកដំណោះស្រាយនិងសហការជាមួយគ្នាឡើងវិញទាក់ទងនឹងបញ្ហាបង្កើតតុលាការនេះ ។ ចាប់តាំងពីកម្ពុជាស្នើសុំឲ្យមានការជ្រោមជ្រែងពីសំណាក់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៧មកទល់នឹងថ្ងៃនេះ គឺត្រូវចំណាយពេលវេលាអស់ជាច្រើនណាស់ គឺច្រើនជាងរយៈពេលដែលខ្មែរក្រហមបំផ្លិចបំផ្លាញកម្ពុជាឲ្យទៅជាគំនរដេះដង់និងសម្លាប់ប្រជាជនកម្ពុជាអស់រាប់លាននាក់ ។

២៣ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម មេដឹកនាំខ្មែរក្រហមទាំងឡាយនៅតែបន្តរស់នៅយ៉ាងជម្ងើយនៅក្នុងសង្គមកម្ពុជា ។ ចំណែកឯជនរងគ្រោះក្រោមស្នាដៃរបបខ្មែរក្រហមវិញរស់នៅក្នុងភាពក្រីក្រលំបាកវេទនាគោកយ៉ាក ។ អតីតមេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា អៀង សារី និងប្រពន្ធឈ្មោះ អៀង ធីរិទ្ធ មានទាំងលទ្ធភាពធ្វើដំណើរទៅប្រទេសថៃដើម្បីព្យាបាលជំងឺដោយចំណាយប្រាក់យ៉ាងសន្ធឹកសន្ធាប់ទៀតផង ។

ការនាំយកបុគ្គលប្រភេទនេះមកកាត់ទោសមិនមែនជាការពិបាកប៉ុន្មានទេ គឺគ្រាន់តែយកឆន្ទៈនយោបាយរបស់សហគមន៍អន្តរជាតិមកប្រសព្វគ្នាជាមួយឆន្ទៈនយោបាយរបស់កម្ពុជាគឺជាការស្រេច ។ ចំណុចនេះគឺជាការដែលអាចធ្វើទៅបាន ។ ក៏ប៉ុន្តែវានឹងក្លាយទៅជាសោកនាដកម្មមួយទៀតសម្រាប់កម្ពុជា ប្រសិនបើធ្វើឲ្យឱកាសនេះត្រូវបាត់បង់ ហើយយុត្តិធម៌ត្រូវពន្យារពេលបន្តទៅទៀតនោះ ។

នៅឆ្នាំ១៩៩៨ សហរដ្ឋអាមេរិកបានអនុម័តច្បាប់ស្តីពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ដែលបញ្ជាក់ច្បាស់អំពីការគាំទ្ររបស់សហរដ្ឋអាមេរិកក្នុងកិច្ចខិតខំប្រឹងប្រែងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ សហរដ្ឋអាមេរិកអាចជួយប្រទេសកម្ពុជានៅពេលនេះ តាមរយៈការបន្តការគាំទ្ររបស់ខ្លួនសាជាថ្មី ។ សហរដ្ឋអាមេរិកគួរតែបញ្ចេញយោបល់របស់ខ្លួនទៅលើភាពចាំបាច់នៃការចូលរួមពីសំណាក់អង្គការសហប្រជាជាតិនៅក្នុងដំណើរការការបង្កើតតុលាការមួយដែលគ្មានមន្ទិលសង្ស័យអ្វីទាំងអស់ ។ ប្រសិនបើគ្មានសំឡេងដ៏មានឥទ្ធិពលចេញពីសហគមន៍អន្តរជាតិទេនោះ យុត្តិធម៌នឹងមិនអាចកើតឡើងនៅលើទឹកដីកម្ពុជាជារៀងរហូត ។

**ឆាំង យុ**

# សេចក្តីសម្រេចរបស់



នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាបានចេញសេចក្តីសម្រេចមួយស្តីអំពីបញ្ហាមួយចំនួនរួមមាន ១)សិទ្ធិសម្រេចក្នុងជួរនិងក្រៅជួរ ២)របបរាយការណ៍១អាទិត្យម្តងមកមន្ទីរ៨៧០ ៣)ការជ្រើសរើសស្រុកជាគំរូដែលបង្កបង្កើនផលបាន៣តោន១ហិកតា ៤)ទស្សនកិច្ចកម្មករ-កសិករ ៥)បញ្ហាប្រវត្តិបក្ស ៦)បញ្ហាវិហារអុងគូ ៧)បញ្ហាវិមានវីរបុរស ៨)ថ្ងៃរំឭកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ៩)កម្មវិធីបុណ្យឯករាជ្យ ១០)ការរៀនធ្វើរំសេវ ១១)ការអនុវត្តតារាងតម្លៃ និង ១២)ការរៀបចំបាត់តាំងអគ្គការរដ្ឋ ។

សិទ្ធិក្នុងការសម្រេចក្នុងជួរនិងក្រៅជួរ គណៈមជ្ឈិមបានលើកសំណូមពរពីរយ៉ាងៈ ទី១)ឲ្យមានក្របខ័ណ្ឌក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តរបស់ខ្លួន និង ទី២)ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់ខ្លួន ។ ចំណុចទាំងពីរខាងលើនេះ គណៈមជ្ឈិមមានគោលបំណងដើម្បីពង្រឹងរដ្ឋអំណាចរបស់ខ្លួនដោយបានកំណត់ថា បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍(ភូមិ)ភាគសម្រេច ។ ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ។ តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច ។ កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច ។

គណៈមជ្ឈិមបានកំណត់របបរាយការណ៍១អាទិត្យម្តងមកមន្ទីរ៨៧០ ដោយលើកសំណូមពរដើម្បីតាមដានផែនការឲ្យជាប់ និងដោះស្រាយបញ្ហាឲ្យទាន់ពេលវេលាក្នុងទិសដៅសម្រេចឲ្យបានតាមផែនការ៣តោនក្នុង១ហិកតារបស់ខ្លួន ។

ក្នុងគោលបំណងសម្រេចឲ្យបានតាមផែនការ៣តោនក្នុង១ហិកតា គណៈមជ្ឈិមបានតម្រូវឲ្យមានការជ្រើសរើសស្រុកជាគំរូដែលបង្កបង្កើនផលបានតាមផែនការនេះ ដើម្បីអាចជូន“ទង់មហាលោតផ្លោះ” ។ នេះជាគំរូនៃផែនការ៣តោនក្នុង១ហិកតា និងជាគំរូនៃគោលដំហរនយោបាយសតិអារម្មណ៍និងចាត់តាំង ។

# គណៈមជ្ឈិម



ផ្នែកនយោបាយមានគំរូខាងដំហរបដិវត្តន៍សង្គមនិយមនិងដំហរឯករាជ្យម្ចាស់ការ ។ ផ្នែកសតិអារម្មណ៍មានគំរូខាងគោលជំហរសមូហភាព គឺសមូហភាពក្នុងក្របខ័ណ្ឌស្រុកនីមួយៗនិងសមូហភាពជាមួយអង្គភាពផ្សេងៗទៀតទូទាំងប្រទេស ។ ផ្នែកចាត់តាំងមានគោលជំហរចាត់ចែងកម្លាំងរបស់ខ្លួនល្អត្រឹមត្រូវ ពោលគឺចេះដឹកនាំតាមមាគ៌ាប្រជាធិបតេយ្យប្រមូលផ្តុំចេះធ្វើការងារសតិអារម្មណ៍ និងចេះសាមគ្គីគ្នា ។ រីឯផ្នែកសម្ភារវិញត្រូវបានកំណត់ឲ្យសមល្មមមិនឲ្យសម្បូរបែប ។

គណៈមជ្ឈិមបានកំណត់អំពីទស្សនកិច្ចកម្មករ-កសិករថាជាទស្សនកិច្ចរៀនសូត្រនៅតាមស្រុក ដោយសំណូមពរឲ្យពង្រីងសាមគ្គីភាពរវាងកម្មករនិងកសិករ បើកចំហទស្សនៈឲ្យធំទូលាយស្គាល់នូវប្រទេសកម្ពុជាប្រជាធិបតេយ្យ ពង្រឹងស្មារតីស្នេហាជាតិថែមទៀត និងរៀនសូត្របទពិសោធន៍គ្នាទៅវិញទៅមក ។

ចំពោះបញ្ហាប្រវត្តិបក្ស គណៈមជ្ឈិមបានកំណត់ប្តូរឆ្នាំកំណើតបក្សរបស់ខ្លួនពីឆ្នាំ១៩៥១ទៅឆ្នាំ១៩៦០វិញ ព្រោះដើម្បីកុំឲ្យជាប់ពាក់ព័ន្ធនឹងបក្សកុម្មុយនិស្តឥណ្ឌូចិនទៀតក្នុងគោលបំណងធ្វើយ៉ាងណាឲ្យដាច់ស្រឡះពីគេឯង ។

គណៈមជ្ឈិមមានផែនការកម្ទេចវិហារអ៊ុងកូ(វិហារកាតូលិកវៀតណាម) ដោយកំណត់ប្រគល់ភារកិច្ចនេះទៅឲ្យខាងកងទ័ពជាអ្នកកម្ទេចចោល ។ ប៉ុន្តែតម្រូវឲ្យរកវិធីធ្វើយ៉ាងណាដើម្បីកុំមានផលប៉ះពាល់ដល់អគារផ្សេងៗទៀត ។ គណៈមជ្ឈិមបានកំណត់ថាវិមានវីរបុរស គឺជានិមិត្តរូបនៃវីរភាពរបស់ប្រជាជនក្នុងការតស៊ូប្រជាជាតិតស៊ូវណ្ណៈមុនពេលនិងក្រោយពេលសង្គ្រាមប្រជាជនប្រឆាំងសង្គ្រាមឈ្លានពានរបស់សហរដ្ឋអាមេរិក ។

ទាក់ទិននឹងថ្ងៃរំឭកព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ខ្មែរក្រហម គណៈមជ្ឈិមបានកំណត់យកកាលបរិច្ឆេទដូចខាងក្រោមៈ

១)បុណ្យឯករាជ្យជាតិជាបុណ្យជាតិធំជាងគេបំផុតត្រូវបានកំណត់យកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

២)ថ្ងៃកំណើតកងទ័ពបដិវត្តន៍ជាថ្ងៃតស៊ូដោយអាវុធទូទាំងប្រទេស ត្រូវកំណត់យកថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ ។

៣)ថ្ងៃកំណើតរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានកំណត់យកថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ។

៤)ថ្ងៃបរាជ័យសង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកត្រូវបានកំណត់យកថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ។

៥)មហាបរាជ័យនៃនយោបាយខ្មែរូបនីយកម្មសង្គ្រាមរបស់ចក្រក្រពត្តិអាមេរិកនៅកម្ពុជា ឬមហាជ័យជម្នះនៃទ្រឹស្តីណិចសុន យកខ្មែរវាយខ្មែរ ត្រូវបានកំណត់យកថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ ។

៦)មហាបរាជ័យនៃសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកជាមូលដ្ឋាន ដោយតំណាងជាផ្លូវការចក្រពត្តិត្រូវវាយបណ្តេញចេញពីប្រទេសកម្ពុជា ត្រូវបានកំណត់យកថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ។

៧)ថ្ងៃរំឭករដ្ឋប្រហារប្រតិកិរិយា ត្រូវបានកំណត់យកថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។

៨)ថ្ងៃចាត់តាំងពង្រឹងពង្រីករណសិរ្សប្រជាជាតិប្រជា-

ធិបតេយ្យ ឬថ្ងៃមហាបាតុកម្មមានលក្ខណៈជាកុប្បកម្មទូទាំងប្រទេស ត្រូវបានកំណត់យកថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ។

៩) ថ្ងៃបើកឆាកវាយប្រហារផ្តាច់ព្រ័ត្រត្រូវបានកំណត់យកថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ។

១០) កំណើតអង្គការយុវជនប្រជាធិបតេយ្យត្រូវបានកំណត់យកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៦១ ។

១១) កំណើតអង្គការនារីកម្ពុជាប្រជាធិបតេយ្យត្រូវបានកំណត់យកថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៦១ ។

១២) កំណើតអង្គការសហជីពកម្មករត្រូវបានកំណត់យកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥៥ ។

១៣) កំណើតអង្គការសហករណ៍កសិករត្រូវបានកំណត់យកថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ។

កម្មវិធីបុណ្យឯករាជ្យ គណៈមជ្ឈិមបានកំណត់ធ្វើឡើង៣ថ្ងៃ ដោយបញ្ចូលទាំងថ្ងៃបុណ្យចូលឆ្នាំផង ។ កម្មវិធីបុណ្យនេះត្រូវបានធ្វើចាប់ពីថ្ងៃទី១៥-១៧ ខែមេសា ឆ្នាំ១៩៧៥ដែលមានកំណត់ដូចខាងក្រោមៈ

ថ្ងៃទី១៥ៈ គោរពវិញ្ញាណក្ខន្ធវីរបុរស ទង់ជាតិត្រូវបង្ហូតចុះនៅត្រឹមពាក់កណ្តាលដង និងធ្វើវិចារណកថាតាមវិទ្យុស្តីពីការវាយចក្រពត្តិអាមេរិកដែលលាតត្រដាងឲ្យសកលលោកឃើញនូវពលិកម្មរបស់ប្រជាជន ក្នុង១ម៉ោងចាក់ផ្សាយម្តង និងមានចាក់ផ្សាយភ្លេងជាតិនិងភ្លេងវីរភាពក្នុងរយៈពេល១ម៉ោងម្តង ។

ថ្ងៃទី១៦ៈ ទទួលអំណរមហាជ័យជម្នះដោយរៀបរាប់ពីវីរភាពកងទ័ព យុទ្ធជន យុទ្ធនារី និងរៀបរាប់ពីសមរភូមិសំខាន់ៗ ។

ថ្ងៃទី១៧ៈ ថ្ងៃបំផុសនូវសេចក្តីប្តេជ្ញាចិត្តកសាងនិងការពារប្រទេសឲ្យបានមហាលោតផ្លោះមហាអស្ចារ្យទាំងនៅទីក្រុងនិងមូលដ្ឋាន ។ ប្រជាជនត្រូវបានឲ្យសម្រាកចំនួន៣ថ្ងៃ ដើម្បីអប់រំនយោបាយ ។

ក្នុងការរៀនធ្វើគ្រាប់រំសេវ សេចក្តីសម្រេចនេះបានកំណត់ជ្រើសរើសយុទ្ធជនទៅរៀននៅបរទេសដោយជ្រើសរើសតាមលក្ខណៈនយោបាយ សតិអារម្មណ៍ និងចាត់តាំង ដើម្បីធានាអះអាងថាជាស្នូល ។ យុទ្ធជនដែលត្រូវបានជ្រើសរើសមានចំនួនពី២០-២៥នាក់ ហើយក៏ត្រូវតែមានសមត្ថភាពបច្ចេកទេសខ្លះដែរ ។ ក្រោយពីរៀនសូត្រហើយ យុទ្ធជនទាំងនោះជាដំបូងត្រូវត្រឡប់មកកសាងរោងចក្រធ្វើគ្រាប់រំសេវសម្រាប់ទូទាំងប្រទេស ហើយបន្ទាប់មកត្រូវបានបែងចែកទៅតាមភូមិភាគរៀងៗខ្លួនវិញ ។

ការអនុវត្តតារាងតម្លៃត្រូវបានគណៈមជ្ឈិមកំណត់ធ្វើតាមគោលការណ៍ ដោយអនុវត្តចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦តទៅ ។ ក្នុងការអនុវត្តជាក់ស្តែង អនុវត្តមុនឬក្រោយថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ ទៅតាមសភាពការណ៍ចាំបាច់ ។ សំណួមពរសំខាន់ គឺគណៈមជ្ឈិមចង់ផ្លាស់ប្តូររវាងរដ្ឋនិងរដ្ឋដើម្បីកសាងនិងការពារប្រទេសតាមមាគ៌ាបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម ពោលគឺមិនមែនដើម្បីបំផុសកម្មសិទ្ធិឯកជនទេ ។

អំពីការរៀបចំចាត់តាំងអង្គការរដ្ឋ គណៈមជ្ឈិមបានលើកសំណួមពរនយោបាយថា ទិសដៅនៃការតស៊ូនយោបាយរបស់ខ្លួន គឺដណ្តើមអំណាចមកក្នុងកណ្តាប់ដៃកម្មករ កសិករ វាយរំលំរដ្ឋអំណាចជិះជាន់ទាំងអស់ ។ ថ្ងៃទី១៧ ខែមេសា (ឆ្នាំ១៩៧៥) ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនិងជាស្ថាពរ ហើយខ្មែរក្រហមត្រូវរៀបចំអង្គការរដ្ឋខ្លួនឲ្យមានលក្ខណៈជាអង្គការរដ្ឋបដិវត្តសុទ្ធសាធ ។ គណៈមជ្ឈិមយល់ថា “រៀបចំរដ្ឋធម្មនុញ្ញ ហើយដំណើរការបោះឆ្នោត ហើយសកលលោកឃើញថា ទាល់តែសភាពការណ៍នយោបាយក្នុងប្រទេសយើងល្អបានរៀបចំបោះឆ្នោតបានល្អយ៉ាងនេះ ។ បោះឆ្នោតហើយត្រូវរៀបចំរដ្ឋសភា គណៈប្រធានរដ្ឋ និងរដ្ឋាភិបាល” ។

គណៈមជ្ឈិមយល់ឃើញទៀតថា “ធាតុពិតអង្គការរដ្ឋយើងពេលនេះខុសពីពេលមុនៗ ។ ពេលមុនធាតុពិតរណសិរ្ស ។ ឥឡូវមិនដូច្នេះទេ ។ ជាអង្គការរដ្ឋរបស់បក្សសុទ្ធសាធ ។ ត្រូវឲ្យអង្គការរដ្ឋទាំងអស់មានលក្ខណៈជាតំណាងពិតប្រាកដមានឥទ្ធិពលគ្រប់គ្រាន់ទាំងនៅក្នុងបក្ស ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ។ នេះជាការវាយសំរុកខាងនយោបាយមួយដែរ” ។

គណៈមជ្ឈិមក៏យល់ឃើញដែរថា “ប៉ែន នុត មិនមានបញ្ហាអីទេ ។ សភាពការណ៍ សីហនុ ទុំហើយ ។ គាត់អស់ខ្យល់ហើយ ។

ដំណើរការទៅមុខទៀតមិនរួចទេ ។ ដូច្នេះយើងសម្រេចឲ្យគាត់ចូលនិវត្តន៍តាមសំណូមពររបស់គេ» ។

ក្នុងកិច្ចដំណើរការជាក់ស្តែង របៀបរបបធ្វើការងាររបស់សភាមានពីរយ៉ាង ទី១) តំណាងទាំងអស់ត្រូវឋិតនៅជាមួយប្រជាជនរបស់ខ្លួនតទៅទៀត ។ ទី២) គណៈកម្មការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ។

សមាសភាពសភារួមមានៈ

ប្រធានៈ សមមិត្ត នួន ជា

អនុប្រធានទី១ៈ សមមិត្ត ភឹម

អនុប្រធានទី២ៈ សមមិត្ត ម៉ុក

រីឯសមាសភាពផ្សេងៗទៀតនៃគណៈអចិន្ត្រៃយ៍ គឺទុកឲ្យគណៈអចិន្ត្រៃយ៍បក្សរៀបចំនៅពេលក្រោយ ។ សមាសភាពទាំងនេះមានទាំងអស់ប្រហែល១០នាក់ ។

សមាសភាពគណៈប្រធានរដ្ឋ រួមមានៈ

ប្រធានៈ សមមិត្ត ហែម

អនុប្រធានទី១ៈ ប៉ែន នុត

អនុប្រធានទី២ៈ សមមិត្ត ញឹម

គណៈមជ្ឈិមបានកំណត់ថា «រដ្ឋាភិបាលត្រូវតែជាអង្គការរដ្ឋសុទ្ធសាធ ។ ជារដ្ឋរបស់យើងផ្ទាល់ ។ សំណូមពរឲ្យខ្លាំងដែរ ។ ត្រូវមានឥទ្ធិពលនៅក្នុងបក្ស នៅក្នុងប្រទេស នៅក្រៅប្រទេស ចំពោះជាមិត្តក្តី ចំពោះខ្មាំងក្តី» ។

បញ្ហារៀបចំរដ្ឋាភិបាលនេះ គណៈមជ្ឈិមបានពិភាក្សាគ្នាសាចុះសាឡើងតាំងពីខែឧសភា ជាបន្តបន្ទាប់មក ។

សមាសភាពរដ្ឋាភិបាល រួមមានៈ

សមមិត្ត ប៉ុល ៖ រដ្ឋមន្ត្រីទី១

សមមិត្ត វ៉ាន់ ៖ ឧបនាយក ទទួលខាងការបរទេស

សមមិត្ត វន ៖ ឧបនាយក ទទួលខាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សមមិត្ត ខៀវ ៖ ឧបនាយក ទទួលខាងការពារប្រទេស

ត្រង់ចំណុចនេះ គណៈមជ្ឈិមយល់ថា ចោទបញ្ហាទំនាស់រវាងការងារបក្សនិងការងាររដ្ឋាភិបាល ហើយវិធានការដែលត្រូវដោះស្រាយមានពីរគឺៈ

១) ការងាររដ្ឋាភិបាលត្រូវឧបនាយកទាំង៣ទទួល ។ ដូច្នេះឧបនាយកទាំង៣ត្រូវខ្វាំង ។ ខ្វាំងទាំងបុគ្គល ខ្វាំងទាំងម៉ាស៊ីនធ្វើការងារ ។

២) សមមិត្តលេខាលៃពេលជួបបរទេសតែប៉ុន្មានថ្ងៃក្នុង១ខែ ។ ក្រៅពីប៉ុន្មានថ្ងៃនេះ គិតគូរការងារបក្សនិងការងារមូលដ្ឋាន ។

ចំពោះបញ្ហាសន្តិសុខ ខ្មែរក្រហមយល់ថា «នៅក្នុងប្រទេសយើងម្ចាស់ការបាន ។ នៅប្រទេសជាមិត្តគេការពារបាន ។ ចោទបញ្ហាមីនប្រាំស្កាត់បាញ់ ។ ដោះស្រាយបានដោយមានវិធានការបង្វែងផ្លូវ ។ ទៅវៀតណាមៈ វិធានការគេច ។ សមមិត្តលេខាមិនបាច់ទៅ ។ ដើម្បីសាមគ្គី លៃឲ្យគណៈប្រធានរដ្ឋឬប្រធានរដ្ឋសភាទៅ» ។

សេចក្តីសម្រេចរបស់គណៈមជ្ឈិមខាងលើនេះ បានឆ្លុះបញ្ចាំងពីការរៀបចំគ្រប់គ្រងរដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យឲ្យមានដំណើរការប្រព្រឹត្តទៅបានល្អ ដោយអនុវត្តទៅតាមរបបផ្តាច់ការនិងពង្រីងប្រជាធិបតេយ្យសង្គមនិយម ដើម្បីពង្រឹងរដ្ឋអំណាចរបស់ខ្លួន ក្រោយពីទើបបានទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ការកសាងនិងការពារប្រទេសរបស់ខ្មែរក្រហមតាមមាគ៌ាបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម ពោលគឺបង្កើតឡើងនូវរបបសមូហភាព ហើយលុបបំបាត់ចោលនូវកម្មសិទ្ធិឯកជនតាមលក្ខណៈប្រជាធិបតេយ្យប្រមូលផ្តុំដើម្បីរៀបចំអង្គការរដ្ឋឲ្យមានលក្ខណៈជាអង្គការរដ្ឋបដិវត្តសុទ្ធសាធដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននោះគឺមិនអាចធ្វើទៅបានទេ ។ ជាលទ្ធផលខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការដោយហូបចុកមិនគ្រប់គ្រាន់បាក់កម្លាំង ហើយចាប់ឃុំឃាំងធ្វើទារុណកម្មនិងយកទៅកាប់សម្លាប់ចំពោះជនណាដែលខ្មែរក្រហមយល់ថាប្រឆាំងនឹងគោលនយោបាយរបស់ខ្លួន សូម្បីតែកម្មាភិបាលនៅក្នុងជួរបក្សឬរដ្ឋាភិបាលរបស់ខ្លួនក៏ដោយ ។ ជាក់ស្តែងក្នុងឯកសារនេះសមមិត្តញឹម និងសមមិត្ត វន ត្រូវបានខ្មែរក្រហមចោទថាក្បត់ ហើយចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ សមមិត្ត ភឹម បានធ្វើអត្តឃាតដោយសារយល់ឃើញថា មិនអាចគេចខ្លួនរួចពីការតាមចាប់ខ្លួនរបស់អង្គការ ។

**ខ្មួន សុភារិទ្ធ**

# បទយកការណ៍ពិសេសៈ

## ខ្ញុំបានធ្វើដំណើរតាមលោកឧបនាយក ខៀវ សំផន ទៅធ្វើទស្សនកិច្ចនៅខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តសៀមរាប

ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧២ ខ្ញុំបានធ្វើដំណើរតាមឧបនាយក ខៀវ សំផន ទៅធ្វើទស្សនកិច្ចនៅខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តសៀមរាប ។ ស្រុកជ័យសែន ស្រុករៀង ក្នុងខេត្តព្រះវិហារ ស្រុកសណ្តាន់ ស្រុកសំបូរ ស្រុកកំពង់ស្វាយ ក្នុងខេត្តកំពង់ធំ ផ្លូវជាតិលេខ៦ ស្រុកបន្ទាយស្រី តំបន់អង្គរនិងជុំវិញអង្គរ ជាដំណាក់ធំៗនៃដំណើរការរបស់យើង ។

ទេសភាពតំបន់រំដោះរបស់យើងនៅចុងឆ្នាំនេះរំលេចទៅដោយពណ៌ស្រូវទុំលឿងប្រាលក្នុងវាលស្រែល្វឹងល្វើយ ចំរុះជាមួយនឹងពណ៌សំណាបស្រូវប្រាំងខៀវខ្ចីល្អក់នៅតាមដីទំនាប និងតាមមាត់ព្រែក មាត់បឹង ធ្វើឲ្យយើងរីករាយក្នុងចិត្តឥតឧបមា ។ ស្រូវវស្សាមិនទាន់ប្រូតកាត់អស់នៅឡើយទេ ឯសំណាបស្រូវប្រាំងដុះខៀវល្អក់ក្នុងថ្នាលតាមកន្លែងៗទៅហើយ ។ ឃើញថាចលនាប្រយុទ្ធបង្កបង្កើនផលកំពុងផុសផុលល្អណាស់ ហើយមានសន្ទុះទៅមុខយ៉ាងលឿន ។ ក្នុងមួយវស្សាកន្លងទៅនេះ ប្រជាជនយើងបានប្រយុទ្ធតឹងតែងណាស់ ។ ប្រជាជនយើងមិនត្រឹមតែប្រយុទ្ធទល់នឹងសង្គ្រាមបំផ្លិចបំផ្លាញដែលចក្រពត្តិអាមេរិកវាធ្វើដោយបាញ់រះ ទម្លាក់គ្រាប់បែក បាចថ្នាំគីមីពុលតាមយន្តហោះ ប៉ងប្រាថ្នារាំងរាការបង្កបង្កើនផលនិងកម្ទេចស្រែចម្ការរបស់ប្រជាជនយើងប៉ុណ្ណោះទេ ។ ឆ្នាំនេះប្រជាជនយើងថែមទាំងបានពុះពារឧបសគ្គធម្មជាតិជាច្រើនផងទៀត គឺឧបសគ្គរាំងស្ងួតសព្វទឹកកន្លែងកាលពីដើមឆ្នាំ ឧបសគ្គទឹកជំនន់លេចស្រូវនៅតាមកន្លែងខ្លះ ពិសេសនៅតាមដងស្ទឹងសែន ហើយនិងឧបសគ្គដង្កូវស៊ីគុម្ពស្រូវ ។ ឥឡូវស្រូវទុំពេញស្រែ នេះជាជ័យជម្នះមួយធំណាស់របស់ប្រជាជនយើងនៅសមរភូមិក្រោយទន្ទឹមនឹងជ័យជម្នះនៅសមរភូមិមុខ ។ ពេលនេះប្រជាជនយើងនៅគ្រប់ទីកន្លែងកាន់តែពេញចិត្តនឹងអង្គការ ពេញចិត្តនឹងកម្មាភិបាលដែលបានណែនាំបងប្អូនឲ្យរួមសាមគ្គីពុះពារឧបសគ្គ ព្រមទាំងបានចុះប្រឡូកជាមួយបងប្អូន រួមជាមួយបងប្អូនពុះពារឧបសគ្គ ។ អត់ទឹកប្រជាជននិងកម្មាភិបាលបានសាមគ្គីគ្នាធ្វើទំនប់ ទប់ព្រែក ទប់អូរ ដើម្បីសាប ។ សំណាបងាប់មួយសាជាពីរសា តែបងប្អូនសាបព្រោះទៀតទាល់តែបាន ។ គ្មានពូជប្រជាជនពិភាក្សាគ្នាក្នុងក្រុមស្នេហាជាតិពីក្រុមមួយទៅក្រុមមួយ សាមគ្គីគ្នា ផ្តល់ពូជគ្នាទៅវិញទៅមក មិនបង្អៀតបង្អល់ ធ្វើយ៉ាងណាឲ្យមានសំណាបគ្រប់គ្រាន់ ស្ទូងឲ្យបានពេញស្រែ ។ ភ្លៀងធ្លាក់មកភ្លាមក៏មានសំណាបគ្រប់គ្រាន់ដើម្បីសាបទាន់ពេលវេលា ។ កម្លាំងសាមគ្គីរបស់ប្រជាជន កម្លាំងចាត់តាំងបង្កបង្កើនផលរបស់ប្រជាជនលេចចេញឡើងជាក្រុមប្រវាស់ដៃនិងក្រុមបង្កបង្កើនផលតាមរូបភាពផ្សេងៗជាច្រើន ហើយជម្នះបាននូវឧបសគ្គទាំងអស់ដណ្តើមបានផលជាទីគាប់ចិត្ត ។ នៅព្រះវិហារ ស្រូវល្អជាទូទៅមានខូចខាតបន្តិចបន្តួច ដោយកន្លែង តាមផ្លូវជាតិលេខ៦ ពិសេសពីកំពង់ក្តីទៅសៀមរាប ស្រូវល្អមែនទែន ឃើញតែគួរឲ្យខ្នាប់ដាច់កន្ទុយភ្នែក ។ នៅកំពង់ធំក៏ស្រូវល្អបង្គួរ ។ នៅតាមផ្លូវដែលយើងបានទៅឃើញ មានតែស្រុកសណ្តាន់មួយទេដែលស្រូវត្រូវខូចខាតទៅវិញមួយភាគធំដែលទឹកស្ទឹងសែនជន់ខុសប្លែកពីសព្វឆ្នាំ លិចភូមិ លិចស្រែចម្ការអស់ កាលពីខែសីហា ខែកញ្ញាកន្លងទៅនេះ ។ ប៉ុន្តែបងប្អូននៅទីនោះនៅតែសុទិដ្ឋិនិយមជានិច្ច ។ ទឹកជំនន់មិនអាចឈ្នះលើកម្លាំងសាមគ្គីរបស់បងប្អូនទាំងស្រុងទេ ។ ទោះបីទឹកជន់លិចភូមិ លិចផ្ទះ លិចជង្រុក មិនដឹងខ្លួនមុនក្តី ក៏បងប្អូនការពារស្រូវចាស់ដែលនៅសល់ក្នុងជង្រុកចែកគ្នាហូបបណ្តោះអាសន្នបាន ទំរាំស្រូវប្រាំងមកដល់ ។ គោ ជ្រូក មាន់ ទា ក៏បងប្អូនការពារបានមិនឲ្យទឹកជំនន់ហូរចូលទៅបានឡើយ ។ ពេលទឹកលិច ក្រុមស្នេហាជាតិនីមួយៗក្នុងភូមិបានក្លាយទៅជាកងប្រយុទ្ធរួមជាមួយឈ្លបឃុំ ការពារផល ការពារ

ទ្រព្យសម្បត្តិប្រជាជនយ៉ាងសកម្ម ប្រមែប្រមូលជ្រូក មាន់ ទា ក្របី គោ ស្រូវអង្ករទាំងអស់ យកទៅដាក់ទីទួលបានទាន់ពេលវេលា រីឯតាយាយដូនចាស់ៗ កុមារាកុមារីតូចតាច ក៏បងប្អូនជួយដូននិងដឹកនាំយកទៅសម្រាកនៅកន្លែងទួលទាន់ពេលវេលា ។ ឥឡូវនេះនៅតាមភូមិគេឃើញដំណាំដាំដុះដូចជា ចេក ដំឡូងជ្វា ដំឡូងឈើ សណ្តែកបាយ សណ្តែកដី កំពុងលូតលាស់ខៀវស្រងាត់ឡើងវិញហើយ ។ ក្រោយភូមិនៅតាមដីទំនាបដែលមាននៅសល់ទឹកប្រជាជនកកំពុងមមាញឹកធ្វើស្រែប្រាំង ។ ស្រុកនេះមិនដែលធ្លាប់ធ្វើស្រែប្រាំងទេ ប៉ុន្តែឆ្នាំនេះ តាមការណែនាំរបស់អង្គការ ប្រជាជនកំពុងខិតខំធ្វើស្រែប្រាំងយ៉ាងសកម្ម ។ ដូចនេះដោយដោះដូរស្រូវពីស្រុករវាងនិងពីកន្លែងជិតខាងផ្សេងទៀត ប្រជាជននឹងដោះស្រាយបញ្ហាស្រូវអង្ករបានគ្រប់គ្រាន់ ។

នៅគ្រប់ទីកន្លែង ទោះបីស្រូវវស្សាបានផលហើយក៏ប្រជាជនកំពុងធ្វើស្រែប្រាំងយ៉ាងមមាញឹកតទៅទៀត ។ បងប្អូននិយាយប្រាប់យើងថា “យើងនៅសមរភូមិក្រោយ យើងមានស្រូវហូបគ្រប់គ្រាន់ហើយ ក៏ត្រូវបង្កបង្កើនផលឲ្យបានច្រើនទៀត ដើម្បីឧបត្ថមសមរភូមិមុខនិងកន្លែងឯទៀតដែលខ្វះខាត” ។

នៅគ្រប់ទីកន្លែង ព្រះសង្ឃ បានចូលរួមក្នុងចលនាធ្វើស្រែប្រាំង និងកំពុងជួយបំផុសចលនាធ្វើស្រែប្រាំងយ៉ាងសកម្មបំផុត ។ ឧទាហរណ៍នៅកំពង់ធំ ព្រះសង្ឃនៅវត្តសំបូរបានធ្វើរហាត់ទឹកជាច្រើនដើម្បីផ្តល់ជូនប្រជាជន ។ ព្រះសង្ឃនៅវត្តស្រងែក្រោមការដឹកនាំរបស់លោកគ្រូចៅអធិការ រ៉ាប់រងធ្វើទំនប់ទឹកនៅភូមិស្រងែក្នុងឃុំត្បែងបានបី ។ តាមប៉ាន់មើលទំនប់ទាំងបីនេះអាចផ្តល់ទឹកដល់ស្រែប្រាំងបានប្រហែល២០ហិកតា ។

ចំណុចមួយទៀតដែលគួរកត់សម្គាល់ គឺអាណិកជនចិនពិសេសអាណិកជនចិននៅរវៀងនិងនៅផ្សារសណ្តាន់ ក៏ចុះធ្វើស្រែដែរ ដោយបានការជួយឧបត្ថម្ភពីអង្គការរណសិរ្សពេញបន្ទុក ។ ទន្ទឹមនឹងចលនាធ្វើស្រែវស្សា ស្រែប្រាំង ចលនាដាំបន្លែបង្កា ចិញ្ចឹមជ្រូក មាន់ ទា ដើម្បីកែប្រែរបបស៊ីចុកនៅជនបទ ក៏មានសន្ទុះប្លែកណាស់ដែរ ។ ឧទាហរណ៍នៅភូមិខ្វាំង ស្រុករវៀង បងប្អូនអត់មានទុកដីឲ្យនៅសល់ទំនេរកន្លែងណាទេ ។ នៅតាមមាត់ព្រែក បងប្អូនឆ្លៀតដាំស្រូវបណ្តោញទឹក ។ នៅតាមផ្លូវដែលកាត់ភូមិ យើងឃើញតែរងដំឡូង រងឆៃថាវ ដង្ហែគ្នាជាប់រដឹក ។ សូម្បីតែបងប្អូននារីឈ្លបដែលមានភារៈយាមផ្លូវខាងវត្តខ្វាំង ក៏ឆ្លៀតលើករងដាំឆៃថាវបណ្តើរ យាមបណ្តើរផងដែរ ។ ឈ្លបភូមិនៅខ្វាំងនេះ មានសួនដំណាំរួមជាច្រើនកន្លែង គឺសួនដែលនៅចំពីមុខវត្តនេះមួយនិងសួនខាងក្រោយមួយទៀត ។ នៅជ័យសែន យើងបានទៅដល់ភូមិម៉ឺនរាជ ភូមិខ្សង ។ បងប្អូនចិញ្ចឹមជ្រូកស្ទើតែគ្រប់ផ្ទះ ដាក់ក្នុងទ្រុងមួយ ទ្រុងមួយគូៗ ។ ជ្រូកខ្លះមានកូនរញៀវក្នុងទ្រុងនៅតាមចិញ្ចើមថ្នល់ជាតិលេខ៦ ក៏



ដូចនេះដែរ ។ ដោយលិចទឹកនៅតាមភូមិ បងប្អូនធ្វើទូកដ្រុក នៅលើចិញ្ចើមថ្នល់ជាប់ដីកចប់តែផ្លូវរហូតដល់សៀមរាប ។ ទៅដល់ជិតសៀមរាប យើងចុះពីថ្នល់កៅស៊ូ កាត់តាមភូមិប្រជាជន ។ យើងឃើញហ្វូងទាជាច្រើន មួយហ្វូង១០ឬ២០ក្បាលដែលហែលលេងក្នុងទឹក ក្នុងប្រឡាយទឹកសងខាងផ្លូវ ។

យើញថា មាគ៌ាសេដ្ឋកិច្ចរបស់រណសិរ្សរួមរួមជាតិកម្ពុជា យើងដែលលើកឡើងថា «សមរភូមិក្រោយវាយសំរុកបង្កបង្កើនផល កែប្រែជីវភាពប្រជាជន ពិសេសប្រជាជននៅមូលដ្ឋាន ហើយខមត្តម្តសមរភូមិមុខ» បានជ្រួតជ្រាបយ៉ាងឆាប់រហ័សនៅក្នុងភូមិ ឃុំ នៅជនបទ ចុងកាត់មាត់ញកប្រទេសកម្ពុជា ។ ជីវភាពប្រជាជនក៏បានកែប្រែមួយជំហានធំ ប្រជាជន ពិសេសកសិករក្រីក្រ ដែលធ្លាប់តែខ្វះខាត ជំពាក់បំណុលគេរំលួក ឥឡូវអស់ជំពាក់គេហើយ ហើយមានស្រូវអង្ករហូបគ្រប់គ្រាន់ ។ ទិដ្ឋភាពដែលឈ្មួញស្ពានកណ្តាល ម្ចាស់បំណុលមកដណ្តើមកើបដឹកស្រូវកសិករពីលាន មិនមានទៀតទេតាំងពីរំដោះមក ។ នៅទីណាក៏បងប្អូនយើងបានលើកយកផែនការថ្មីនេះដោយទឹកចិត្តសោមនស្សរីករាយបំផុត ។ បងប្អូននារីរីករាយជាងគេ ។ ប្តីខ្លួនដែលពីដើមធ្លាប់តែផឹកស្រា ក៏ឈប់ផឹកស្រាឬផឹកទឹកត្នោតជូរ ឈប់ឡូឡាស្រវឹងអួរទីទួ ឈប់លេងបៀ ឈប់លេងអាប៉ោង ឈប់លេងកន្ទុយលេខ បំណុលក៏អស់មានជំពាក់គេ ស្រូវអង្ករក៏នៅសល់ បានហូបគ្រប់គ្រាន់ ។ នៅវៀង មីងម្នាក់កាត់ដាល់អំបុកជាមួយកូនស្រីជំទង់របស់គាត់បណ្តើរ និយាយដំណាលរឿងនេះប្រាប់ខ្ញុំបណ្តើរដោយសម្តីរដឹនៗ ។ ក្រោយពីរៀបរាប់សព្វគ្រប់គាត់សន្ធត់ពាក្យថា «នេះបានដោយសារគុណបដិវត្តណ៎ ។ អីចឹងបានជាកូនខ្ញុំពីរចូលកងទ័ពទាំងពីរ ខ្ញុំមិនដែលឃាត់វាទេ!» ។ គាត់មានកូនពីរចូលបម្រើក្នុងកម្លាំងប្រដាប់អាវុធរបស់ប្រជាជនរំដោះជាតិកម្ពុជា ហើយគាត់និយាយប្រាប់ខ្ញុំដោយញញឹមពេញចិត្តណាស់ ។ នៅស្រុកនេះស្ទើតែគ្រប់ផ្ទះ ផ្ទះណាក៏មានកូនប្រុសចូលកងទ័ពដែរ ហើយបងប្អូនមានមោទនភាពនឹងបានកូនចូលបម្រើទ័ពណាស់ ។ នៅកំពង់ព្រូ តាមផ្លូវពីជ័យសែនមករវៀង យើងឃើញពូម្នាក់កំពុងតែដាក់ទឹកត្នោត ។ យើងក៏ចូលទិញទឹកត្នោតគាត់ហូប ។ យើងហូបទឹកត្នោតមួយបំពង់ យើងជូនលុយគាត់ គាត់មិនព្រមយកសោះ ។ គាត់ឆ្លើយមកយើងវិញថា «បដិវត្តន៍រំដោះខ្ញុំពីបំណុលគេ ឲ្យខ្ញុំមានស្រែធ្វើ មានស្រូវអង្ករហូបគ្រប់គ្រាន់ ខ្ញុំគ្រាន់តែជូនទឹកត្នោតមិត្តទាំងអស់គ្នាមួយបំពង់ហូបមិនបានទេឬ? មិត្តទាំងអស់ធ្វើការមានប្រាក់ខែឯណា!» ។ ពាក្យសម្តីពោរពេញទៅដោយមនោសញ្ចេតនាបដិវត្តរបស់ពូធ្វើឲ្យយើងជាប់ចិត្តនឹងពូយ៉ាងខ្លាំង ។ យើងសំណេះសំណាលជាមួយគាត់អស់មួយសន្ទុះធំ ។ មុនរំដោះ គាត់មិនដែលមានស្រូវហូបគ្រប់គ្រាន់ទេ ដោយអាពួកក្បត់ លន់ ណុល សិរិមតៈ សឺង ង៉ុកថាន់ និងដៃជើងវា ទាំងពួកឈ្មួញស្ពានកណ្តាលជិះជាន់គាត់គ្រប់បែបយ៉ាង ។ ឥឡូវនេះគាត់មានស្រូវហូបគ្រប់គ្រាន់ ។ គាត់សព្វថ្ងៃជាឈ្លបភូមិ ។ យើងលាគាត់បន្តដំណើរ គាត់ទទូចឲ្យយើងហូបទឹកត្នោតទៀត ។

នៅគ្រប់ទីកន្លែងដែលយើងសម្រាកតាមផ្លូវ បងប្អូនទាំងនារី ទាំងបុរស ទាំងចាស់ ទាំងក្មេង ទាំងកុមារតូចធំ តែងមកចាប់ដៃយើង ហើយសួរសុខទុក្ខយើងយ៉ាងរាក់ទាក់កក់ក្តៅបំផុត ។ ព្រមទាំងយកទឹកដូង អំបុក ចេក មកឲ្យយើងបន្តៗគ្នាជាប់មិនដាច់ ។ នៅព្រះវិហារ ចាស់ៗមានអំបោះមកចងដៃយើងទៀត ដោយជូនពរយើងយ៉ាងកក់ក្តៅបំផុត ។ កុមារៗក៏រាក់ទាក់ណាស់ដែរ ។ ក្មួយៗឃើញយើងពីចម្ងាយ ក៏រត់មកហើយនិយាយថា «សុំចាប់ដៃពូ! សុំចាប់ដៃពូ» យើងសួរថា «ក្មួយធំឡើងធ្វើអ្វី?» ក្មួយឆ្លើយឡើងយ៉ាងច្បាស់ៗថា «ចូលកងទ័ពវាយអាមេរិកណាពូ!» ។ ប្រជាជនយើងស្គាល់មិត្ត ស្គាល់សត្រូវច្បាស់ណាស់ ហើយចងគំនុំនឹងខ្មាំងដាច់ខាត ។ នៅគ្រប់ទីកន្លែងដែលយើងទៅដល់ ប្រជាជន យុទ្ធជនទាំងប្រុសស្រី ទាំងក្មេង ទាំងចាស់ អបអរទទួលលោកឧបនាយក ខៀវ សំផន ដោយក្តីរំភើបក្រៃលែង ។ នៅពេលចេញដំណើរពីកន្លែងមួយទៅកន្លែងមួយ បងប្អូននាំគ្នាពាក់ពូនចាប់ដៃលោកឧបនាយកដោយសេចក្តីនឹករលឹកក្រៃលែង ហើយផ្តាំហើយផ្តាំទៀតសូមឲ្យលោកឧបនាយកអញ្ជើញមកទៀត ។ បងប្អូនបានជូនពរដល់លោកឧបនាយក ព្រមតាមរយៈលោកដល់រណសិរ្សនិងរាជរដ្ឋាភិបាលរួមរួមជាតិកម្ពុជា សូមឲ្យបានប្រកដោយមហាជ័យជម្នះនិងកម្លាំងពលំបរិបូរ ។

(ឯកសារទង់បដិវត្ត)

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| លរ | លរទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ៣០៥ | ០៣១៤០៣ | វត្តជ័យមង្គល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣០៦ | ០៣១៤០៤ | គុកតាដួង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣០៧ | ០៣១៤០៥ | គុកតាដួង | ជាង១០ | ៤០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣០៨ | ០៣១៤០៥ | មន្ទីរព្រៃតាបេះ | ៧ | ៨០០០-១០០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣០៩ | ០៤០១០១ | វត្តសម្តេចមុន្នី | ១០០ | ១៣០០០ | ប្រហែល១០០ | ៨០០-១៣០០ | ១៩៩៨ |
| ៣១០ | ០៤០១០២ | ព្រៃពោធិ៍តាវ៉ា | ១ | ៨០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣១១ | ០៤០១០៣ | ព្រៃពោធិ៍តាចារ្យ | គ្មាន | ប្រហែល៨០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣១២ | ០៤០១០៤ | ភូមិត្នោតជោរ | ១ | ៤០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣១៣ | ០៤០២០១ | កោះស្វែង | គ្មាន | ២០០០-៣០០០ | គ្មាន | ២០០០-៣០០០ | ១៩៩៨ |
| ៣១៤ | ០៤០៤០១ | វាលស្រែវែង | ៣ | ២០០-៣០០ | ៤ | គ្មាន | ១៩៩៨ |
| ៣១៥ | ០៤០៤០២ | ព្រៃខ្សាច់ | ៣០០-៥០០ | ១០០០០-១៥០០០ | ១៥-២០ | ជាង៦០០០ | ១៩៩៨ |
| ៣១៦ | ០៤០៤០៣ | ក្បាលខ្មោច | ១៥-២០ | ៦០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣១៧ | ០៤០៤០៤ | គុករកបាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣១៨ | ០៤០៦០១ | ចុងប្រាសាទ | ១៥០-២០០ | ១០០០-១៣០០ | ១៥០-២០០ | ១០០០-១៣០០ | ១៩៩៨ |
| ៣១៩ | ០៤០៦០២ | ត្រពាំងទឹកត្រជាក់ | ៣ | ១៥០ | ៣ | ១៧០-២៣០ | ១៩៩៨ |
| ៣២០ | ០៤០៦០៣ | ខ្សាច់ស | ១២៥ | ២០៩៥០ | ៥០០-១០០០ | ១០០០០-១៥០០០ | ១៩៩៨ |
| ៣២១ | ០៤០៦០៤ | ខ្សាច់ស | ១៤៣ | ៣៥០៤០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣២២ | ០៤០៦០៥ | ខ្សាច់ស | ៥៨ | ៤៥០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣២៣ | ០៤០៦០៦ | ខ្សាច់ស | ៩៥ | ៤២០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣២៤ | ០៤០៦០៧ | គុកចុងជ្រោយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣២៥ | ០៤០៦០៨ | គុកចុងជ្រោយ | ៥០០-១០៥០ | ៧ម៉ឺន-១០ម៉ឺន | ២០០-៣០០ | ៧ម៉ឺន-១៥ម៉ឺន | ១៩៩៨ |
| ៣២៦ | ០៥០៥០១ | ព្រៃក្តាមពង | ៣ | ៤៥០-៦០០ | ៣ | ៤៥០-៦០០ | ១៩៩៨ |
| ៣២៧ | ០៥០៥០២ | បុស្សឫម្ហូយគុម្ព | ៨០០-១០០០ | ៣២០០-៤០០០ | ៥០០-១០០០ | ៣២០០-៤០០០ | ១៩៩៨ |
| ៣២៨ | ០៥០៦០១ | ប៉េអាម | គ្មាន | ១៦០ | គ្មាន | ១៦០ | ១៩៨៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣២៩ | ០៥០៦០២ | ប៉េអា២ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៣០ | ០៥០៦០៣ | ប៉េអា១ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៣១ | ០៥០៦០៤ | ភ្នំគន្ធាក់ | ៣ | ១០-១២ | ២ | ៥០-៦០ | ១៩៩៨ |
| ៣៣២ | ០៥០៦០៥ | គីរីបឹងជុំ | ៣ | ៥០-៦០ | ១ | ១០-១២ | ១៩៩៨ |
| ៣៣៣ | ០៥០៨០១ | ស្រែតាមឿន | លើសពី១ | ១០៨០ | ត្រពាំង២ | ១៦៨០ | ១៩៩៨ |
| ៣៣៤ | ០៥០៨០២ | ព្រៃក្បាលខ្មោច | ៥០-៧០ | ១៥០០ | ៨០-១២០ | ៤៨០-៧២០ | ១៩៩៨ |
| ៣៣៥ | ០៦០៤០១ | វត្តសេរីសោភ័ណចាស់ | ១០០-១១០ | ៦០០-៧០០ | ១០០-១២០ | ៥០០-៧០០ | ១៩៩៨ |
| ៣៣៦ | ០៦០៥០១ | វត្តស្រីទេព | ២ | ១៥០-២៥០ | ២ | ១៥០-២៥០ | ១៩៩៨ |
| ៣៣៧ | ០៦០៥០២ | ព្រៃអ្នកតាចាស់ស្រុក | ៣០-៤០ | ១០០-២០០ | ១២-២០ | ២០០-២៥០ | ១៩៩៨ |
| ៣៣៨ | ០៦០៥០៣ | វត្តប្រាសាទសំបូរ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៣៩ | ០៦០៨០១ | វិទ្យាល័យសេរីសោភ័ណ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៤០ | ០៦០៨០២ | ទួលតាភួង | ២៥០-៥០២ | ៥ម៉ឺន-១០ម៉ឺន | ២០០-៥០២ | ១០ម៉ឺន-១៥ម៉ឺន | ១៩៩៨ |
| ៣៤១ | ០៧០២០១ | គុកទួរខៀវ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៤២ | ០៧០២០២ | ព្រៃចេក | ១២០០-១៥០០ | ៣០០០-៤៥០០ | ១២០០-១៥០០ | ៣៦០០-៤៥០០ | ១៩៩៨ |
| ៣៤៣ | ០៧០២០៣ | ព្រៃស្វាយស | ១០-២០ | ៨០០-១០០០ | ១០-២០ | ៨០០-១០០០ | ១៩៩៨ |
| ៣៤៤ | ០៧០២០៤ | គៀនជុំ | ៧០០-៨០០ | ៩០០-១០០០ | ៧០០-៨០០ | ៩០០-១០០០ | ១៩៩៨ |
| ៣៤៥ | ០៨០៣០១ | សាលាសន្ទុង | ១ | ១០-២០ | គ្មាន | ១២-១៥ | ១៩៩៨ |
| ៣៤៦ | ០៨០៣០២ | ដើមរុន | ១ | ៣០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣៤៧ | ០៨០៣០៣ | ចំការស៊ីវ | ១ | ៧០០-១០០០ | គ្មាន | ៧០០-១០០០ | ១៩៩៨ |
| ៣៤៨ | ០៨០៣០៤ | ចំការស៊ីវ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៤៩ | ០៨០៣០៥ | វត្តស្វាយរមៀត | ១ | ១០-២០ | ២ | ៨០-៩០ | ១៩៩៨ |
| ៣៥០ | ០៨០៧០១ | វត្តរកាកោង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៥១ | ០៨០៧០២ | កោះមរណៈ | ១ | ជាង១ម៉ឺន | គ្មាន | រាប់ពាន់ | ១៩៩៨ |
| ៣៥២ | ០៨០៧០៣ | សាលាសេរីមង្គល | ១ | ១០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣៥៣ | ០៨០៨០១ | ព្រៃស្រែកាច់ | គ្មាន | ៣០-៥០ | គ្មាន | ២០-៥០ | ១៩៩៨ |
| ៣៥៤ | ០៨០៨០២ | វត្តស្ពួនពេជ្រ | គ្មាន | ៣៥០-៧០០ | គ្មាន | ៤០០-៧០០ | ១៩៩៨ |
| ៣៥៥ | ០៨០៩០១ | ភ្នំខដុគ្គ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |

**(នៅមានត)**

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល និងកោះកុង ។

- ចំពោះពត៌មានមានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេងៗ ។
- ចំពោះពត៌មានដាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានដាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# គោលនយោបាយប្រឆាំងខ្មែរក្រហម

(ឯកសារលេខ D១៨៣៣៣)

*(តចប់)*

***ផែនការក្រោយចាញ់:***

នយោបាយមានតែផែនការបំផុសបំផុលកម្មករតាមរោងចក្រនានាដែលមានសេ.អ៊ី.អានៅក្នុងរោងចក្រនោះ ធ្វើឲ្យមានការរំដើបរំជួលក្នុងផ្ទៃក្នុងរោងចក្រនិងក្រសួងធំៗរបស់អង្គការនៅក្នុងទីក្រុងភ្នំពេញដើម្បីឲ្យមានបាតុភាពគ្រប់បែបយ៉ាងរវាងអង្គការនិងកម្មករ ឲ្យរោងចក្រអាក់ដំណើរការ គឺថាវាយប្រហារបដិវត្តតាមនយោបាយដែលយកកម្មកររោងចក្រជាមូលដ្ឋាន កសាងកម្លាំងថ្មីតាមរោងចក្រ ដើម្បីប្រើនយោបាយសេ.អ៊ី.អានៅតាមមូលដ្ឋាន ក៏ប្រើនយោបាយដំបូងបំផុសបំផុលជាមូលដ្ឋានដែរនិងការទាក់ទងរកខ្សែរយៈតទៅទៀតដែលនាំប្រជាជនឲ្យប្រឆាំងនឹងអង្គការតាមសង្កាត់និងមន្ទីរ ។

ចំពោះក្រសួងរបស់អង្គការនោះ គឺសំដៅទៅលើរដ្ឋករទឹករទេះភ្លើង អគ្គិសនី និងតម្បាញ គឺទឹកន្លែងពីដើមមកជារបស់រដ្ឋការក្រសួងសាធារណការក៏ចូលក្នុងក្រសួងនោះដែរ ។

***សកម្មភាពទូទៅ:***

សកម្មភាពជាក់ស្តែងដែលខ្ញុំផ្ទាល់បានដឹងគឺការបំផុសបំផុលតាមរោងចក្រក្នុងក្រុងភ្នំពេញឲ្យមានបាតុភាពច្របូកច្របល់ក្នុងរោងចក្ររវាងកម្មករថ្មីនិងកម្មករចាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃៗ មិនជឿលើអង្គការក្នុងការរស់នៅនិងការងារដោយនៅតែបារម្ភអង្គការជម្លៀសទៅក្រោយពេលបង្រៀនចេះបាតុភាពធ្វើឲ្យម៉ាស៊ីនក្នុងរោងចក្រសំខាន់ៗខូចដើម្បីបង្អាក់ដំណើការ ការរៀបចំរោងចក្រមិនបានត្រឹមត្រូវតាមគំនិតដើម្បីធានានូវគុណភាព បំផ្លិចបំផ្លាញរបស់ប្រើប្រាស់ក្នុងរោងចក្រ ធ្វើការខ្ជះខ្ជាយមិនមានកម្រិតខ្ពស់ក្នុងការបំពេញភារកិច្ច ប្រើប្រាស់វត្ថុធាតុដើមមិនសន្សំសំចៃនៅអគ្គិសនីកម្ពុជាជាដើម មានការរំដើបខ្លាំងក្នុងរោងចក្រ ចំពោះផែនការបំផ្លិចបំផ្លាញនៅក្នុងរោងចក្រក៏ចេះតែលេចចេញជារូបរាងបន្តិចម្តងៗ ក្រោយពីធ្វើឲ្យម៉ាស៊ីនតូចធំខូចមក ហើយថ្ងៃដែលគ្រោងទុកគឺថ្ងៃ ២៤-១២-៧៥ ម៉ោង២៤ ។

នៅតាមមូលដ្ឋានដែលខ្ញុំបានដឹង ដូចព្រែកតាគង់ ការបំផុសបំផុលនេះមានសកម្មភាពមិនខុសប្លែកពីមូលដ្ឋានខ្លះៗទៀតធ្វើឲ្យការរស់នៅប្រចាំថ្ងៃនិងកិច្ចការ... ។

***សកម្មភាពជាផែនការ សេ.អ៊ី.អា ក្រោយពេលចាញ់:***

◆ ប្រជាជនជម្លៀសចេញពីក្រុងភ្នំពេញចេញតាមគ្រប់ផ្លូវជាតិធំទាំងបីគឺលេខ១-៥ (អាចទៅព្រែកក្តាម) និងតាមផ្លូវពោធិចិនតុង នៅពេលចេញភ្លាមនោះ សមាជិក សេ.អ៊ី.អា ក៏ចេញគ្រប់ផ្លូវតាមប្រជាជនដែរ ។

◆ តាំងពីពេលចេញដំបូងមក នៅតាមផ្លូវមានសកម្មភាពបន្តិចៗជាមួយប្រជាជននិងមានប្រជុំរវាងសមាជិក សេ.អ៊ី.អា សួរគ្នាពីផ្លូវដែលមិត្តភក្តិចេញ និងគម្រោងទិសដៅដែលត្រូវទៅម្នាក់ៗ ។

◆ ក្រោយពីពេលអង្គការឲ្យរោងចក្រនានាមានដំណើរការជាបន្តបន្ទាប់មក សេ.អ៊ី.អា បានចូលតាមរោងចក្រ ទាំងកម្មករជាងចាស់និងថ្មីៗ បងប្អូនដែលមកជាមួយនិងអ្នកបច្ចេកទេសក្នុងរោងចក្រទាំងឡាយមានចម្រុះទៅដោយកម្មករមកពីគ្រប់មជ្ឈដ្ឋានទាហាន ស៊ីវិល មជ្ឈដ្ឋានសិក្សា និងរដ្ឋការស៊ីវិល ។

◆ កសាងកម្លាំងនៅក្នុងរោងចក្រ ដោយយោងទៅតាមគោលការណ៍លំបាកក្នុងជីវភាពរស់នៅតាមរោងចក្រ និងកំហឹងផ្ទាល់ខ្លួនផង កម្លាំងនេះបានពង្រីកជាលំដាប់ ។

◆ ការជួបគ្នារវាងសមាជិកតាមរោងចក្រដោយទាក់ទងតាមផ្លូវអង្គការដូចជាដើររកផវ៉ាន់ប្រើប្រាស់ និងពឹងពាក់អ្នកបច្ចេកទេសពីរោងចក្រក្រៅជួរក្នុងកិច្ចការ និងទាក់ទងតាមពេលបើកវគ្គខសុរាហកម្ម និងពេលបុណ្យប្រក្សនៅពហុកីឡដ្ឋាន ។

◆ ពីខែ៧មក រោងចក្រមួយចំនួនបានដំណើរការ រីឯការបំផុសគឺផែនការបានចាប់កម្រើកឡើងតាមរោងចក្រក្នុងក្រុងអគ្គិសនីដែលមានសមាជិក សេ.អ៊ី.អា បង្កប់ក្នុងរោងចក្រដែរក៏កំរើក រោងចក្រឯទៀតៗមានសកម្មភាពតាំងពីពេលនោះមក រីឯផែនការមានដូចជាៈ

◆ គោលធំគឺមិនឲ្យរោងចក្រមានដំណើរការស្រួល ហើយបំផ្លាញរោងចក្រ ។

◆ ធ្វើយ៉ាងណាឲ្យខូចម៉ាស៊ីនតូចធំតាមរបៀបបច្ចេកទេស និងធ្វេសប្រហែសម៉ាស៊ីនណាសំខាន់ៗក្នុងខ្សែផលិត ។

**ពង្រីកកម្លាំងៈ**

ក្នុងឆ្នាំ១៩៧៣ដែលជាឆ្នាំសង្គ្រាមក្តៅក្នុងប្រទេស ហើយជាឆ្នាំដែលប្រកាសចង់ចរចារកសន្តិភាពដោយឥតលក្ខខណ្ឌ នៅក្នុងឆ្នាំងដែលកម្លាំងពង្រីកពី៤០-៥០ភាគរយលើសពីឆ្នាំ១៩៧០-១៩៧៣ ដើម្បីបង្កើនកម្លាំងនៅក្នុងប្រទេសតាមមជ្ឈដ្ឋាននានា តាមយោធា រដ្ឋការស៊ីវិល មជ្ឈដ្ឋានសិក្សាស៊ីវិល ហើយក្នុងឆ្នាំបន្តបន្ទាប់មកទៀតក្នុងឆ្នាំ១៩៧៤រហូតមកក៏បង្កើនបានកម្លាំងតាមធម្មតាមកទៀត ។

**បង្កប់កម្លាំងមនុស្សៈ**

ចំពោះកម្លាំងមនុស្សដែលបង្កប់នៅក្នុងក្រុងដូចបានជម្រាបមកនោះ គឺមានចម្រុះជាទូទៅទាំងទាហានពាសពេញក្រុងសម្រាប់អនុវត្តផែនការ ចំណែកនៅតាមខេត្តនានាក៏មានកម្លាំងបង្កប់នៅក្នុងខេត្តនិងតាមជនបទដែលមានខ្សែទាក់ទងតាមផ្នែកនីមួយៗជាមួយនឹងខេត្តឬក្រុង ពិសេសនៅតាមទល់ដែនប្រទេសជាមួយនឹងសៀម មានទាហាននិង សេ.អ៊ី.អា បង្កប់មកច្រើន ត្រៀមខ្លួននឹងធ្វើសកម្មភាពនានា ពលទាហាននិងនាយទាហានទាំងនេះ សេ.អ៊ី.អាបានទទួលការផ្គត់ផ្គង់សព្វបែបយ៉ាងដើម្បីធ្វើចលនាប្រឆាំងនឹងអង្គការបដិវត្ត បង្កប់នៅជនបទ ដើម្បីជាខ្សែនិងបំផុសប្រជាជនតាមមូលដ្ឋាននានាដែលអាចធ្វើបាន ហើយសមាជិកទាំងនេះខំរកកម្លាំងតៗទៀត ។

នៅក្រុង កម្លាំងនៅតាមរោងចក្រឯកជននិងរដ្ឋការ និងតាមទីកន្លែងរដ្ឋការក្នុងក្រុង ដែលត្រូវការជាចាំបាច់ក្នុងការផ្គត់ផ្គង់ដល់ក្រុង ដាក់ស្តែងរទេះភ្លើងកម្ពុជា រដ្ឋករទឹក រោងចក្រកម្សាញរដ្ឋ អគ្គិសនីកម្ពុជា មូលហេតុដែលបង្កប់បានដោយយោងទៅតាមរោងចក្រនិងកន្លែងរដ្ឋការទាំងនោះត្រូវការអ្នកបច្ចេកទេសសម្រាប់ដំណើរការ ម៉្លោះហើយទោះជាយ៉ាងណាក៏អង្គការត្រូវការអ្នកបច្ចេកទេសមករៀបចំរោងចក្រដែលជាចាំបាច់សម្រាប់ប្រទេស ។ ក្នុងចំណោមអ្នកបច្ចេកទេស សឹងថាភាគច្រើនជា សេ.អ៊ី.អា កាលណាចូលមកដល់រោងចក្រក៏ធ្វើសកម្មភាពកសាងកម្លាំងថ្មីនិងទាក់ទងតាមរោងចក្ររកខ្សែរយៈនានាហើយដែលភាគច្រើនសុទ្ធតែជាមិត្តភក្តិឬស្គាល់មកយូរហើយ ។

**អាវុធៈ**

ចំពោះអាវុធសម្រាប់កម្លាំងតាមជាយដែនគឺមានតាំងពីពេលដែលបង្កប់កម្លាំងមកម្ល៉េះ ជាពិសេសនៅតាមជាយដែនជាប់នឹងសៀម អាវុធអាចផ្តល់តាមសៀមដោយគ្មានអ្វីពិបាកឡើយទោះជាតាមវិធីណាក៏ដោយ ហើយសៀមព្រួយបារម្ភថាក្រោយពីខ្មែរ យួន និងលាវ ធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ប្រជាជនបដិវត្តមក សៀមបានប្រកាសចង់ចំណងទូតជាមួយប្រទេសជិតជាប់ទាំងអស់ ជាពិសេសខ្មែរ ។ ខាងផ្នែកនយោបាយក្រៅប្រទេសឃើញថាជាការទាក់ទងដើម្បីរក្សាសន្តិភាពមិនជ្រៀតជ្រែកគ្នា គោរពគ្នាទៅវិញទៅមកតាមផែនការផ្ទៃក្នុងដើម្បីកុំឲ្យបក្សកុម្មុយនិស្តជ្រៀតចូលទៅសៀមទៀត គឺមានតែងតាំងទ័ពតាមព្រំប្រទល់ តែបើចងចំណងទូត ហើយរៀបចំទ័ពផងឃើញថាមិនសូវស្របនយោបាយទាំងពីរនេះ ម៉្លោះហើយត្រូវតែរកមធ្យោបាយដើម្បីបិទបាំងនយោបាយនេះ ត្រង់នេះហើយបានបញ្ជាក់ថា សៀមគ្មានប្រឆាំងនឹងការផ្តល់អាវុធនិងឲ្យទ័ពជ្រកនៅក្នុងដែនដីជាយដែនឡើយ អាមេរិកភ័យជាងសៀមទៅទៀត គឺឲ្យតែអស់សៀមមួយទៀត គឺឥណ្ឌូចិននិងជ្រោយឥណ្ឌូចិនត្រូវតែនៅក្រោមការត្រួតត្រារបស់កុម្មុយនិស្ត ហើយប្រទេសជាបន្តបន្ទាប់ទៅទៀត ។ ចំពោះអាវុធតាមរដ្ឋការស៊ីវិលក៏គ្មានដែរ ព្រោះស៊ីវិលច្រើនតែនៅតាមរោងចក្រនិងក្រសួងនានាដែលនៅជាមួយនឹងមិត្តកម្មករគ្មានលទ្ធភាពប្រើអាវុធដូចជាផ្នែកខាងយោធា ។

ក្នុងវិស័យខ្លះទៀតដូចជាវិស័យអប់រំប្រជាជន សិស្សកម្មករឲ្យស្អប់កុម្មុយនិស្តដែលមានខ្មែរក្រហមជាអ្នកធ្វើបាប

ប្រជាជន សម្លាប់ព្រះសង្ឃ ដុតវត្តអារាម បំបាត់សាសនា ជិះជាន់ សម្លាប់ប្រជាជនស្លូតត្រង់ គឺធ្វើបាបគ្រប់បែបយ៉ាង ហើយឃោសនាឲ្យប្រជាជនរស់នៅក្នុងផ្នែកជាមួយខ្មាំងត្រឡប់មករួមរស់ជាមួយបងប្អូនខាងសាធារណរដ្ឋវិញ ហើយដែលមានការខបត្តម្ភនិងជ្រោមជ្រែងគ្រប់បែបយ៉ាងពីរដ្ឋាភិបាលនិងអង្គការមនុស្សធម៌នានា ។

បង្កើតឲ្យមានការអប់រំតាមសង្កាត់ ខណ្ឌ ចំពោះប្រជាជននៅក្នុងក្រុង ដើម្បីពន្យល់សភាពការណ៍បច្ចុប្បន្នដែលរដ្ឋាភិបាលខំស្វែងរកសន្តិភាពជូនប្រជារាស្ត្រ តែខ្មែរម្នាងនៅតែធ្វើសង្គ្រាមសម្លាប់ប្រជារាស្ត្រនិងព្រះសង្ឃស្លូតត្រង់តទៅទៀត ។

## គោលនយោបាយ

### ក្រៅប្រទេសៈ ពីក្រៅចូលក្នុង មុនចាញ់

១) ទាក់ទងជាមួយប្រទេសនានា ជប៉ុន សៀម ឥណ្ឌូណេស៊ី ហ្វីលីពីន ដែលជាបក្សសម្ព័ន្ធ ឲ្យជួយប្រកាសចរចាបញ្ឈប់សង្គ្រាមបង្ហូរឈាមក្នុងប្រទេស ។

២) ផ្លាស់ប្តូរអ្នកនយោបាយសំខាន់ៗក្នុងស្រុកដើម្បីលុបលាងនូវអំពើដែលធ្វើពីមុនមក លន់ ណុល សុសស្តែន ។

៣) ប្រកាសថាសង្គ្រាមដែលជ្រៀតជ្រែកដោយពួកកុម្មុយនិស្តតាមសារពត៌មាននៅសៀម ជប៉ុន អូស្ត្រាលី ។

៤) ធ្វើអន្តរាគមន៍ជាមួយនឹងប្រទេសចិន-យួនដែលមានឥទ្ធិពលលើខ្មែរក្រហម ជំរុញឲ្យចរចា ។

៥) ឲ្យតំណាងសភាអាមេរិកកាំងចូលមកក្នុងប្រទេសកម្ពុជា ហើយទៅវិញផ្សាយសង្គ្រាមដែលជិះជាន់ដីព្រៃផ្សរបស់កុម្មុយនិស្ត ដើម្បីសុំជំនួយថែមផ្តល់ដល់កម្ពុជា ។

៦) ទាក់ទងនឹងប្រទេសសៀម ឥណ្ឌូណេស៊ី ដែលទៅថ្ងៃក្រោយអាចទាក់ទងការទូតជាមួយនឹងកម្ពុជាដើម្បីជួយផ្តល់ពត៌មានក្នុងប្រទេស ។

៧) បង្កបង្កើតអង្គការជាច្រើនដើម្បីជួយប្រជារាស្ត្រ ពិសេសជនភៀសខ្លួន ដូចជា *RDF, CARE, World Vision, CRS, Red Cross* ។

### ពីក្នុងចេញក្រៅ មុនចាញ់

១) បណ្តុះបុគ្គលិកចេញពីកន្លែងនានា ពិសេសមុនគេគឺពួកអង្គការមនុស្សធម៌ គ្រួសារបុគ្គលិកស្ថានទូត និងជនជាតិអាមេរិកាំងដែលមិនមែនជាបុគ្គលិកស្ថានទូត ។

២) ពេលចេញទៅ ទោះបីជាតាមវិធីណាក៏ដោយ ឲ្យផ្សព្វផ្សាយសង្គ្រាមរំលោភរបស់កុម្មុយនិស្តនៅក្នុងប្រទេសខ្មែរដល់ពិភពលោកទាំងមូល ។

៣) ផ្សាយនូវពាក្យ «ទោះជាកុម្មុយនិស្តឈ្នះក៏ដោយ ក៏មិនយូរដែរ» ក្នុងរវាង៦-៧ខែ មុខតែមានសង្គ្រាមក្នុងស្រុករំលំរបបកុម្មុយនិស្តមិនខាន ពីព្រោះពត៌មាននេះដឹងច្បាស់ណាស់តាមរយៈបុគ្គលិក ។

៤) ការផ្សាយពាក្យទាំងនេះមិនថាតែបុគ្គលិកស្ថានទូតអាមេរិកកាំងនោះទេ គឺស្ថានទូតនានាដែលជាបក្សសម្ព័ន្ធដូចជានៅអូស្ត្រាលី ហ្វីលីពីន ចិនតៃវ៉ាន់ ក៏ផ្សាយថាជាសង្គ្រាមលេបទឹកដីឥណ្ឌូចិនដែរ ។

៥) ដឹកនាំបុគ្គលិកខ្មែរនិងអ្នកដែលទាក់ទងទៅជាមួយទាំងយោធា ទាំងស៊ីវិលទាំងអាមេរិក ឬប្រទេសបក្សសម្ព័ន្ធ ដូចជានៅសៀមជាដើម គឺជាក់ស្តែងនៅរដ្ឋកាលីហ្វ័រនីសព្វថ្ងៃមានជនភៀសខ្លួនខ្មែរនៅជាច្រើន ។

៦) ពេលចុងក្រោយទើបដឹកបុគ្គលិកស្ថានទូតអាមេរិកាំងទាំងអស់ចេញ ។ ជាសកម្មភាពទូទៅៈ

◆ មានការបង្កើតជាបក្សក្នុងរដ្ឋាភិបាល ហើយខ្មែរក៏មានបែកខ្មែរ-មន អង្គរ ជាដើម ។

◆ អ្នក១៨មីនាក៏បែកខ្ញែកគ្នារៀងៗខ្លួន ។

◆ កិច្ចការរដ្ឋនៅចំការមន *Mr. Dean* ត្រូវចេញចូលញឹកញាប់ដើម្បីពិភាក្សាជាមួយប្រធានាធិបតី ។

◆ អង្គការមនុស្សធម៌មានសកម្មភាពខ្លាំងក្នុងការផ្គត់ផ្គង់ម្ហូបចំណីជាដើម រីឯសកម្មភាពនេះខ្លាំងជាងអង្គការរដ្ឋទៅទៀត ស្បៀងដឹកតាមយន្តហោះក៏មាន ។

◆ ទោះជាយ៉ាងណា លុយរៀលចេះតែចុះតាមការកម្រិតរបស់អាមេរិកជា៣ខែឬក៏ជា៥ខែម្តង ម៉្លោះហើយទំនិញក្នុងស្រុកចេះតែឡើងថ្លៃ កើតមានការរំជើបរំជួលក្នុងជីវភាពរស់នៅជាទូទៅ ទាំងរដ្ឋការ ទាំងឯកជន ជាក់ស្តែងគ្រូមិនព្រមទៅបង្រៀនគ្រប់ម៉ោង និងកម្មកររោងចក្រនានាទាមទារឡើងប្រាក់

ខែ និងបន្ថយម៉ោងធ្វើការ ។

◆ ខេត្តកំពតផ្លាស់ប្តូរចៅហ្វាយខេត្តថ្មី ជាប្អូនបង្កើតរបស់ សុសស្តែន គឺ ផូរិន ហៅរណាន់ដែល បាត់ដំបងពី សេក សំអៀត ដាក់ ស ហោ និងកំពង់ចាមពី ស ហោ មក នូ ជូ និងភូមិភាគទី២ ខេត្តគីរីរម្យក៏ប្រគល់ឲ្យ ចន្ទ រង្សី ទៀត ។

◆ ការនាំចូលទាំងឡាយក្រោមជំនួយ សេដ្ឋកិច្ចអាមេរិកាំង ទិញបានតែពីប្រទេសណាដែលជារណបរបស់អាមេរិកឬបានតែ ពីអាមេរិកតែមួយគត់ ។

◆ សាំងឡើងខ្ពស់បំផុតមុនពេលរំដោះ ធ្វើឲ្យវត្ថុឯទៀតៗ ឡើងតាម ។

◆ តាមផ្នែកយោធាមានការលួចឥវ៉ាន់លក់ និងលុយពី ពលទាហានគ្រប់ផ្នែក ពិសេសបំផុតសាំងទាហានដាក់ដបលក់ ពាសពេញទីក្រុងដែលតម្លៃថោកជាងតាមស្ថានីយ៍ប្រេង ។

◆ តាមដឹងពីមិត្ត គឺសភាបែកគ្នាជាបក្សពួកដែរ ដោយសភា ខ្លះចង់ហៅរដ្ឋាភិបាលមកចោទសួរកិច្ចការរដ្ឋ តែហៅមិនបាន ដោយសំអាងលើកាលៈទេសៈ អ្នកខ្លះទៀតដែលនៅក្នុងសភា ហើយកាន់ការរដ្ឋបាលផងគឺពិបាកដោះស្រាយ ឧទាហរណ៍ ប៉ាន់ សុធី និង កឹក គីលឹម ។

**ពីក្នុងចេញក្រៅៈ ក្រោយចាញ់**

១) នៅពេលក្រោយចាញ់ហើយដែលអង្គការជម្លៀស ប្រជាជនចេញអស់ទៅ ផ្នែកខាងនយោបាយពីក្នុងចេញក្រៅ មានផ្តល់ព័ត៌មានតាមប្រជាជននិងសេ.អ៊ី.អាដែលរត់ចេញពី ក្នុងប្រទេសទៅសៀមតែប៉ុណ្ណោះ ។

២) អ្នកដែលចេញទៅបាន ច្រើនតែនៅតាមខេត្តជាប់នឹង សៀមនិងអ្នកចូលមកយកព័ត៌មាន ក៏មាននៅតាមជាយដែននោះ ដែរ ។



រូបថតឯកសារៈ ចូសេហ្វ កូហ្វម៉ាន់

៣) ដោយគ្មានស្ថានទូតណាមួយជាបក្សសម្ព័ន្ធ នោះការយកការណ៍នៅក្នុងទីក្រុងភ្នំពេញ ឃើញថាគ្មានលទ្ធភាពអ្វីទាំងអស់ក្រៅអំពីការ ស្មាននិងតាមព័ត៌មានមិនច្បាស់ខ្លះៗពីប្រទេស នានាដែលទាក់ទងជាមួយនឹងកម្ពុជា ។

៤) ចំពោះអ្នកដែលចូលមកយកព័ត៌មានក្នុង ប្រទេសច្រើនតែគេចមិនផុតពីការចាប់ពី ក្រុមយោធាបដិវត្តន៍ឡើយ ។

**ពីក្រៅចូលក្នុងៈ ក្រោយចាញ់**

១) គោលនយោបាយពីក្រៅចូលក្នុងក្រោយ ពេលចាញ់ ពុំមានគោលការណ៍អ្វីដែលមាន លក្ខណៈសំខាន់ទេ គឺមានតែការឃោសនាតាម វិទ្យុ ដោយសង្ឃឹមថាមានប្រជាជនស្តាប់តាម ការជាក់ស្តែងមានប្រជាជនខ្លះស្តាប់វិទ្យុសំឡេង សហរដ្ឋអាមេរិក និងប៊ីប៊ីស៊ីដែរ ។

២) បញ្ចូលបុគ្គលិកតាមជាយដែនសៀមមក ស៊ើបការណ៍និងខ្លះចូលមកបង្កប់ជាមួយប្រជាជន មុនពេលរៀបចំសហករណ៍ដើម្បីបំផុសនិង កសាងកម្លាំងថ្មីទៀតក្នុងចំណោមប្រជាជន ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

***រៀបចំនិងចងក្រងដោយ យិន នាន***

**(តពីលេខមុន)**

| លរ | ឈ្មោះដើម | តួនាទី | កន្លែងយក | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|
| ៦៧ | អោម សារិន | ប៉េអឹម | | ២១-៣-៧៦ | |
| ៦៨ | យស់ គីន | ទាហានពលទោ | | ២១-៣-៧៦ | |
| ៦៩ | ប៉ាន់ នី | ប៉េអ៊ឹម ពលបាលទោ | | ២១-៣-៧៦ | |
| ៧០ | អ៊ិន នាន | ទាហានគិញ | | ២២-៣-៧៦ | |
| ៧១ | ហ៊ុយ គាន ហៅ ខូវ វុទ្ធី | ទាហានពលទោ | | ២២-៣-៧៦ | |
| ៧២ | ដឹម ត្រី ហៅ វង់ សារិត | ទាហានពលទោ | | ២២-៣-៧៦ | |
| ៧៣ | ស សាវ៉ាត ហៅ ស គិន | ទាហាននាយឯក | | ២២-៣-៧៦ | |
| ៧៤ | ឡុង សុជាតិ | កូនសិស្ស | | ២៩-៣-៧៦ | |
| ៧៥ | ឡុង សេរីរដ្ឋ | ទាហានពលបាលត្រី | | ២៩-៣-៧៦ | ខ្មែរឡុងប៉ូរ៉ែត |
| ៧៦ | គីម វាសនា | និស្សិត | | ២៩-៣-៧៦ | សាសនាកាតូលិក |
| ៧៧ | គីម ស៊ីនួន | ទាហានស័ក្តិ២ | | ២៩-៣-៧៦ | សាសនាកាតូលិក |
| ៧៨ | គីម ស៊ីថា | និស្សិតពេទ្យ | | ២៩-៣-៧៦ | សាសនាកាតូលិក |
| ៧៩ | ទឹម ប៉ែម | ទាហានស័ក្តិ៤ | | ២៩-៣-៧៦ | |
| ៨០ | ចាន់ កៀន | ទាហានសក្តិ២ | | ២៩-៣-៧៦ | |
| ៨១ | ហាក់ ហេង | ទាហានស័ក្តិ១ | | ២៩-៣-៧៦ | |
| ៨២ | កុយ ប៉ុក | ទាហានស័ក្តិ១ | | ២៩-៣-៧៦ | |
| ៨៣ | នួ្វ វ៉ាន់ | ទាហានស័ក្តិ១ | | ២៩-៣-៧៦ | |
| ៨៤ | ហ៊ុន ហុងស្រ៊ុន | ទាហានស័ក្តិ២ | | ២៩-៣-៧៦ | |
| ៨៥ | នូ យ៉យ | ទាហានស័ក្តិ១ | | ២៩-៣-៧៦ | |
| ៨៦ | អ៊ឹម ពេជ | ទាហានស័ក្តិ២ | | ២៩-៣-៧៦ | |
| ៨៧ | ជៀម ភាម | ទាហានស័ក្តិ១ | | ២៩-៣-៧៦ | |
| ៨៨ | សំបុក សំប៊ុន | ទាហានស័ក្តិ៣ | | ២៩-៣-៧៦ | |
| ៨៩ | អៀម គន | ទាហានស័ក្តិ៣ | | ២៩-៣-៧៦ | |
| ៩០ | ចិន ឌៀវ | ប្រជាជន | | ២៩-៣-៧៦ | ជាតិ ឥណ្ឌា |
| ៩១ | សាន់ សារ៉េត | ទាហានស័ក្តិ២ | | ២៩-៣-៧៦ | |
| ៩២ | ហ៊ី កេន | ទាហានស័ក្តិ២ | | ៣០-៣-៧៦ | |
| ៩៣ | អ៊ុក សាអែម | ទាហានស័ក្តិ៤កន្លះ | | ៣០-៣-៧៦ | |
| ៩៤ | ម៉ែន ហម | ទាហានស័ក្តិ១ | | ៣០-៣-៧៦ | |
| ៩៥ | ម៉ុល សាម៉េន | ទាហានស័ក្តិ៤កន្លះ | | ៣០-៣-៧៦ | |
| ៩៦ | សំ សារី | ទាហានស័ក្តិ២ | | ៣០-៣-៧៦ | |

| | | | | |
|---|---|---|---|---|
| ៩៧ | ឯក ពិនវុធ | ទាហានស័ក្តិ៤កន្លះ | ៣០-៣-៧៦ | |
| ៩៨ | អ៊ុច សារឿន | ទាហានស័ក្តិ២ | ៣០-៣-៧៦ | |
| ៩៩ | លុន ខេម | ទាហានស័ក្តិ២ | ៣០-៣-៧៦ | |
| ១០០ | គុង សុមង្គល | ទាហានស័ក្តិ៣ | ៣០-៣-៧៦ | |
| ១០១ | ដួង ភួន | ទាហានស័ក្តិ៥ | ៣០-៣-៧៦ | |
| ១០២ | គឹម យីស៊ុន | ទាហានស័ក្តិ៤កន្លះ | ៣០-៣-៧៦ | |
| ១០៣ | ប៉ែន ឌៀន | ទាហានសក្តិ២ | ៣០-៣-៧៦ | |
| ១០៤ | គាំ អួន | ទាហានសក្តិ៤កន្លះ | ៣០-៣-៧៦ | |
| ១០៥ | កែវ ថុន | ទាហនស័ក្តិ២ | ៣០-៣-៧៦ | |
| ១០៦ | សោម សារិន | ទាហានស័ក្តិ៣ | ៣០-៣-៧៦ | |
| ១០៧ | នៅ ធីម | ទាហានស័ក្តិ២ | ៣០-៣-៧៦ | |
| ១០៨ | ឆួន ឆែម | ទាហានស័ក្តិ៥ ពេទ្យ | ៣០-៣-៧៦ | |
| ១០៩ | កា បូនី | ទាហានស័ក្តិ៥ | ៣០-៣-៧៦ | |
| ១១០ | ផែង ណាត | ទាហានដោយ៣ជាន់ | ៣០-៣-៧៦ | |
| ១១១ | ប៉ែម វី | ប្រជាជនសន្តិសម្ព័ន្ធ | ៣០-៣-៧៦ | |
| ១១២ | ស វ៉ាន់ចាន់ | ទាហានស័ក្តិ៤ | ៣០-៣-៧៦ | |
| ១១៣ | ឯក សុផុន | គិញ | ៣០-៣-៧៦ | |
| ១១៤ | ខៀវ សំអាត ហៅ ខៀវ សុជាតា | កូនសិស្ស | ៣០-៣-៧៦ | |
| ១១៥ | យី សុខា | ប្រពន្ធទាហានទ | ៣០-៣-៧៦ | |
| ១១៦ | ឆាយ គឹមហេង | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១១៧ | សៀង សុន | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១១៨ | គឹង ឡៃ | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១១៩ | កែ សារិន | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១២០ | អោម បាក់សៀង | ទាហានស័ក្តិ២ | ៣០-៣-៧៦ | |
| ១២១ | ហែម ខន | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១២២ | ដួង ជី | ទាហានស័ក្តិ១ | ៣០-៣-៧៦ | |
| ១២៣ | គាំ យុន | ប៉ូលិស | ៣០-៣-៧៦ | |
| ១២៤ | ប៉ែន ដារ៉ាស៊ី | ប៉ូលិស | ៣០-៣-៧៦ | |
| ១២៥ | តាន់ គឹមធួន | ប៉េអឹម ស័ក្តិ១ | ៣០-៣-៧៦ | |
| ១២៦ | ឡឹក សំអុល | ទាហាន ស័ក្តិ១ | ៣០-៣-៧៦ | |
| ១២៧ | ប៉ក់ វ៉ាន់ឌី | ទាហានដោយ ៣ជាន់ | ៣០-៣-៧៦ | |
| ១២៨ | គិន សុនលី | ទាហានពលទោ | ៣០-៣-៧៦ | |
| ១២៩ | ប៉ាន់ ណន | ទាហាន ស័ក្តិ១ | ៣០-៣-៧៦ | |
| ១៣០ | ម៉ូវ ចាន់ផល | ទាហានពលបាលត្រី | ២១-៣-៧៦ | |
| ១៣១ | ហង់ សៀ | ទាហានពលទោស | ២៦-៣-៧៦ | **(នៅមានត)** |

# រូបថតឯកសារ




**(តពីលេខមុន)**

***រូបទី៧***

◆ អៀវ ស៊ី អាយុ២០ឆ្នាំ (ឆ្នាំ១៩៧៧) ជាយុទ្ធជននៅក្នុងកងការពារមន្ទីរ ស-២១ ។ កើតនៅភូមិពោធិលើ ឃុំត្រើយស្លា ស្រុក១៦ តំបន់២៥ ។ ម្តាយឈ្មោះ ចាយ មុំ ឪពុកឈ្មោះ អៀវ ឈាង។ ចូលបដិវត្តន៍ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៤។ មានបងប្អូន៧នាក់ ប្រុស៤នាក់ ស្រី៣នាក់ ។ បច្ចុប្បន្នមិនដឹងរស់ ឬស្លាប់ ។

***រូបទី៨***

◆ វ៉ែន ហ៊ាង អាយុ២២ឆ្នាំ យុទ្ធនារីនៅមន្ទីរ ស-២១ ក្នុងកង១៤ ។ ស្រុកកំណើតភូមិត្រើយស្លា ឃុំត្រើយស្លា ស្រុក២៦(ស្អាង) តំបន់២៥ ។ ចេញមកពីកងពល ៧០៣ ។ ឪពុកឈ្មោះ ឡាច ដាន់ ម្តាយឈ្មោះ វ៉ែន រុន ។ កម្រិតវប្បធម៌ថ្នាក់ទី១០ ចាស់ ។ ចូលបដិវត្តន៍ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៣ ។ ចូលបំពេញការងារនៅអង្គភាព ស-២១ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៥ ។ បច្ចុប្បន្នរស់នៅអន្លង់វែង ។







***រូបទី៩***

◆ ហម សេង អាយុ២២ឆ្នាំ យុទ្ធជននៅក្នុងកងទី១១នៃកងការពារនៅមន្ទីរ ស-២១ ។ ស្រុកកំណើតកើតនៅស្រុក១៨ តំបន់២៥ ។ ឪពុកឈ្មោះ ហម ម្តាយ ឈ្មោះ អ៊ុន ។ ចូលបដិវត្តន៍ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៣ ។ បច្ចុប្បន្នមិនដឹងរស់ ឬស្លាប់ ។




***រូបទី១០***

◆ មាស ប៉េងគ្រី អាយុ២២ឆ្នាំ អ្នកបើករថយន្តនៅមន្ទីរសន្តិសុខព្រៃស (មន្ទីរ២៤) ។ ស្រុកកំណើតនៅភូមិកំពង់ស្វាយ ឃុំព្រែកថ្មី ស្រុក១៨(កោះធំ) តំបន់២៥ ។ កងចាស់៧០៣ មន្ទីរ២១ ។ ឪពុកឈ្មោះ មាស គ្រិស ម្តាយឈ្មោះ យន ហុង ។ កម្រិតវប្បធម៌ថ្នាក់ទី១២ចាស់ ។ ចូលបដិវត្តន៍ថ្ងៃទី៨ ខែមីនា ឆ្នាំ ១៩៧៣ ។ ចូលបំពេញការងារនៅអង្គភាពមន្ទីរ-២៤ ថ្ងៃទី៥ ខែសីហា ឆ្នាំ ១៩៧៧ ។ គ្រី ត្រូវបានចាប់ឃុំខ្លួនពីបទបើកឡានក្រឡាប់ ។ បច្ចុប្បន្នរស់នៅ

ខេត្តកណ្ដាល ។

**រូបទី១១**

◆ ស៊ុន ស្រៀន អាយុ ២០ឆ្នាំ (ឆ្នាំ១៩៧៧) យុទ្ធជនក្នុងកង១១ នៃកងការពារមន្ទីរស-២១ ។ ស្រុកកំណើតភូមិព្រែកគេរ ឃុំកោះធំ ស្រុក១៨(កោះធំ) តំបន់២៥ ។ ម្ដាយឈ្មោះ ទ្រី យន ឪពុកឈ្មោះ ស៊ុន លក ។ កម្រិតវប្បធម៌ថ្នាក់ទី១១ចាស់ ។ ចូលបដិវត្តន៍ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៤ ។ ស្រៀន ត្រូវបានចាប់ខ្លួនឃុំឃាំងនៅឆ្នាំ១៩៧៧ ពីបទ«មិនព្រមកែប្រែ» (តាមចំណារនៅលើឯកសារប្រវត្តិរូបរបស់ស្រៀន) ។ បច្ចុប្បន្នមិនដឹងរស់ ឬស្លាប់ ។




**រូបទី១២**

◆ ឆេង ថន អាយុ២៧ឆ្នាំ (ឆ្នាំ១៩៧៧) អ្នកកាន់សេដ្ឋកិច្ច និងបញ្ជី នៅមន្ទីរ ស-២១ ។ កើតនៅភូមិកោះខែល ឃុំកោះខែល ស្រុក២០ តំបន់២៥ ។ ឪពុកឈ្មោះ ឆេង ព្រាម ម្ដាយឈ្មោះ សែន នួន ។ មានបងប្អូន៤នាក់ ប្រុស១នាក់ ស្រី៣នាក់ ។ ចូលបដិវត្តន៍ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧២ និងចូលបំពេញការងារនៅមន្ទីរ ស-២១ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៥ ។ បច្ចុប្បន្នមិនដឹងរស់ ឬស្លាប់ ។







**រូបទី១៣**

◆ អែម សារឿន អាយុ១៨ឆ្នាំ (ឆ្នាំ១៩៧៧) ជាអ្នកបើកបររថយន្តនៅមន្ទីរ ស-២១ ។ កើតនៅភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុក១៨ តំបន់២៥ ។ ឪពុកឈ្មោះ អែម ម៉ិច ម្ដាយឈ្មោះ រស់ ស្រីម ។ មានបងប្អូន ៥នាក់ ប្រុស២នាក់ ស្រី៣នាក់ ។ ចូលបដិវត្តន៍ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៥ ។ មកបំពេញការងារនៅមន្ទីរស-២១ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ ។ បច្ចុប្បន្នមិនដឹងរស់ ឬស្លាប់ ។




**រូបទី១៤**

◆ ញ៉ែប ហូ ហៅ ញ៉ែប សុវណ្ណ អាយុ២៧ឆ្នាំ (ឆ្នាំ១៩៧៧) យុទ្ធជនក្នុងកងការពារមន្ទីរស-២១ ។ កើតនៅភូមិសំប៉ានក្រោម ឃុំព្រែកអំបិល ស្រុក២០ តំបន់២៥ ។ ឪពុកឈ្មោះ ញ៉ែប មោក ម្ដាយឈ្មោះ សុក ឆេង ។ មានបងប្អូន៧នាក់ ប្រុស៥នាក់ ស្រី២នាក់ ។ ចូលបដិវត្តន៍ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៣ ។ ចូលបំពេញការងារនៅមន្ទីរ ស-២១ នៅខែមករា ឆ្នាំ១៩៧៦ ។ សុវណ្ណ ជាបងប្រុសរបស់ ប៉េង ប្រធានកងវរយការពារនៅមន្ទីរស-២១ ។ បច្ចុប្បន្នរស់នៅខេត្តកណ្ដាល ។ **(នៅមានត)**

**សាន់ កល្យាណ**

**(តពីលេខមុន)**

## ទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាបានបាត់ស្រមោលឈឹងតែម្តង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានតុលាការ គ្មានចៅក្រម គ្មានច្បាប់ និងគ្មានការជំនុំជម្រះក្តីអ្វីទាំងអស់ ។ "តុលាការប្រជាជន" ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រា៩ មិនដែលមានជារូបរាងទេ ។ ភាពគ្មានច្បាប់ឬការការពារ ការផ្តាច់ខ្លួនចេញពីពិភពលោក សារសំខាន់ដែលកំណត់ដោយមជ្ឈិមបក្សចំពោះចម្លើយសារភាពរបស់ "ខ្មាំង" និងការលាយឡំរវាងកិត្យានុភាពនិងភាពសម្ងាត់របស់មន្ទីរ ស-២១ ទាំងអស់នេះបានជំរុញឲ្យឌុច និងបក្ខពួកធ្វើទារុណកម្ម បានប្រើមធ្យោបាយផ្សេងទៀតដែលខ្លួនមានដើម្បីជម្រិតយកចម្លើយសារភាព ។ ក៏ប៉ុន្តែអ្នកធ្វើការនៅមន្ទីរស-២១ បានលាក់បាំងរឿងនេះក៏ដូចជារឿងផ្សេងៗទៀតមិនឲ្យមហាជនកម្ពុជាដឹងឡើយ ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៥: បង្ខំឲ្យឆ្លើយ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

កម្មាភិបាលធ្វើការនៅមន្ទីរស-២១ ជឿជាក់ថា ពេលដែលខ្លួនធ្វើទារុណកម្មអ្នកទោសគឺពិតជាបានឆ្លើយតបទៅនឹងអ្វីដែលប្រទេសជាតិត្រូវការជាចាំបាច់ និងឆ្លើយតបទៅនឹងការភ័យខ្លាចរបស់អ្នកដឹកនាំប្រទេសនេះផង ។ ដូចយើងឃើញស្រាប់ហើយថា មនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ គឺការបន្តធ្វើសង្គ្រាមវណ្ណៈនិងធ្វើបដិវត្តន៍ ។ "ខ្មាំង" មាននៅគ្រប់កន្លែង ហើយត្រូវតែកម្ទេចចោល ។ ខ្មាំងខ្លះនៅរាយតាមព្រំដែនកម្ពុជា ចំណែកខ្មាំងផ្សេងទៀតនៅឆ្ងាយពីនេះទៀត ហើយមានមួយចំនួនទៀត"បង្កប់ស៊ីរូងផ្ទៃក្នុងបក្ស" ។ ខ្មាំងភាគច្រើនបន្លំខ្លួនធ្វើជាមិត្ត ។ ដើម្បីតាមដជឹករកពួកនេះ ចាំបាច់ត្រូវតែចាត់វិធានការឲ្យបានតឹងរ៉ឹង ។

ទារុណកម្មតាមផ្លូវតុលាការភាគច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលកើតឡើងនៅក្នុងមន្ទីរ ស-២១ គឺប្រហែលដោយសារមន្ទីរនេះមានតែមួយនៅក្នុងប្រទេសដែលមាននាទីគតិយុត្តិស៊ើរតែពេញលេញដូចដែលបានបង្ហាញតាមរយៈការធ្វើឯកសារផលិតដោយមន្ទីរនេះស្រាប់ ។ មន្ទីរ ស-២១ ក៏មានអំណាចដែលផ្តល់ដោយមជ្ឈិមបក្សក្នុងការចាត់ការរឿងទោសក្បត់បក្សដែរ ។ បុរសនិងស្ត្រីរាប់ពាន់នាក់ដែលមានទោសស្រាលឬចាប់ដាក់គុកដោយចោទថាជាខ្មាំងវណ្ណៈ ត្រូវស្លាប់ដោយកង្វះចំណីអាហារ ជំងឺ និងការប្រព្រឹត្តអំពើសាហាវឃោរឃៅក្នុងគុកនានានៅតាមបណ្តាខេត្តផ្សេងៗ ។ ប៉ុន្តែជាទូទៅប្រជាជនទាំងនេះមិនទទួលរងទារុណកម្មដើម្បីបង្ខំឲ្យបង្ហាញភស្តុតាងថាខ្លួនធ្វើខុសឡើយ ។ ថ្វីបើដូច្នេះមែន ជារឿយៗអ្នកទោសដែលត្រូវដាក់ផ្លាកសម្រាប់បញ្ជូនមកទួលស្លែងត្រូវបានធ្វើទារុណ-កម្មនៅក្នុងគុកនៅតាមបណ្តាខេត្តជាមុនសិនដើម្បីលត់អ្នកទោសនិងប្រមូលយកពត៌មានដំបូងៗសម្រាប់យកមកផ្តល់ឲ្យអ្នកសួរចម្លើយនៅទីក្រុងភ្នំពេញធ្វើជាឯកសារ ។ ជាអាទិ៍ វ៉ាន់ ណាត ត្រូវបានធ្វើទារុណកម្ម"អស់ជាច្រើនម៉ោង" នៅខេត្តបាត់ដំបង មុនពេលគាត់មកដល់មន្ទីរស-២១ ។ ចំណែកឯឈ្មោះ ប៊ើន ឆែ (ហៅ ឆោម សាវ៉ាត) បានរៀបរាប់នៅក្នុងចម្លើយសារភាពរបស់ខ្លួនថា គាត់បានទទួលទារុណកម្មនៅខេត្តកំពង់ចាមមុនពេលត្រូវបញ្ជូនមកភ្នំពេញ ។

ដូច្នេះទារុណកម្មផ្លូវតុលាការនៅមន្ទីរ ស-២១ ត្រូវបានភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មដូចអញ្ញមតិនៅអឺរ៉ុបកាលពីមជ្ឈិមសម័យដែរ ។ ឧក្រិដ្ឋកម្មនេះរួមមានការក្បត់នឹងសតិអារម្មណ៍ក្នុងការដឹកនាំ និងការសង្ស័យទៅលើខ្សែបណ្តាញបង្កប់ផ្ទៃក្នុង ។ កាលនៅក្នុងមជ្ឈិមសម័យ ចម្លើយសារភាពរបស់អ្នកទោសបានធ្វើ

ឲ្យលេចចេញនូវទោសកំហុសឡើងមុនបន្តស់។ គ្មានការបង្ហាញជាភស្តុតាងត្រឹមត្រូវទេ។ ដូចយើងឃើញស្រាប់ ក្រោយពី“ការបះបោរ”របស់ ចាន់ ចក្រី នៅខែមេសា ឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យមានអារម្មណ៍ភ័យខ្លាចមិនឈប់ឈរ។ ថ្នាក់ដឹកនាំទាំងនេះត្រូវការឲ្យមានមនុស្សទទួលថ្មបាក់ដែលត្រូវរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ(មាត្រា១០) ហៅថា“សកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន”។ មិនយូរប៉ុន្មាន បរាជ័យនៃផែនការសេដ្ឋកិច្ចត្រូវការឲ្យមានមនុស្សទទួលថ្មបាក់ថែមទៀត។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ អ្នកទោសភាគច្រើនដែលនាំមកមន្ទីរស-២១ ត្រូវបានចោទប្រកាន់ថាក្បត់ឬមានការពាក់ព័ន្ធនឹងអ្នកដទៃទៀតដែលត្រូវបានចោទប្រកាន់រួចហើយ។ មន្ទីរស-២១ បានក្លាយ




ជាកន្លែងដ៏មានសារសំខាន់សម្រាប់ជីវិតរបស់របបកម្ពុជាប្រជាធិបតេយ្យ។

ជំហានទី១ក្នុងការដាក់គុកនិងកាន់តែសោះកក្រោះទៀតក្នុងការធ្វើទារុណកម្មដូវតុលាការ គឺបំបាត់លក្ខណៈជាមនុស្សពីអ្នកទោស។ នៅមន្ទីរស-២១ ការអនុវត្តបែបនេះមានឥទ្ធិពលពីរយ៉ាង ទីមួយគឺធ្វើឲ្យអ្នកធ្វើទារុណកម្មប្រព្រឹត្តទាំងងងឹតងងល់មកលើអ្នកទោស និងទីពីរកាត់ផ្តាច់អ្នកទោសមិនឲ្យមានគំនិតសហគមន៍ ឬគោរពខ្លួនឯង។ ដោយសារខ្លួនត្រូវបានដាក់ងារថា “ខ្មាំង” (ដូចទមិឡកាលពីសម័យមុនបដិវត្តន៍) អ្នកទោសបានបាត់បង់សិទ្ធិជាប្រជាជនកម្ពុជាឬជាមនុស្សជាតិទៅហើយ។ នៅពេលមកដល់មន្ទីរស-២១ អ្នកទោសត្រូវបានរុញច្រមុជចូលក្នុងឋាននរកដូចជាជនរងគ្រោះនៅក្នុងរូបចម្លាក់តាមជញ្ជាំងអង្គរវត្តយ៉ាងដូច្នោះដែរ។ ក្រោយពេលត្រូវចាប់ខ្លួន វាសនាអ្នកទោសបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ វ៉ាន់ ណាត បានរំឭករឿងរ៉ាវកាលពីនៅជាប់គុកក្នុងបន្ទប់ជាមួយកម្មាភិបាលខ្មែរក្រហមថា “កាលពីនៅក្នុងសហករណ៍ គេគោរពវាដូចស្តេច គ្មានអ្នកណាហ៊ានមើលមុខវាទេ។ ប៉ុន្តែឥឡូវនេះ ពេលជាប់ខ្នោះជើងអ៊ីចឹងមើលទៅមុខដូចស្វាក្រិស”។ ការបំបាត់លក្ខណៈជាមនុស្សពី វ៉ាន់ ណាត ធ្វើឲ្យនឹកឃើញដល់រឿងរ៉ាវរបស់អ្នកទោសនៅប្រទេសផ្សេងៗទៀតដែរ។ នៅទសវត្សរ៍ឆ្នាំ១៩៣០ អឺជីននៀ ជីនហ្សបើហ្គ ដែលជាយុវតីកុម្មុយនិស្តវ័យក្មេងជាតិរុស្ស៊ីដែល ស្តាលីន ចាប់ដាក់គុកមុនបន្តស់ និងក្រោយមកបញ្ជូនមក អ៊ូស៊ីត បានជួបជាមួយចៅក្រមសូវៀតម្នាក់។ ចៅក្រមនោះប្រាប់នាងថា “ខ្មាំងមិនមែនជាមនុស្សទេ។ គេឲ្យយើងធ្វើចំពោះខ្មាំងតាមចិត្តចង់ធ្វើយ៉ាងម៉េចក៏គ្មានបញ្ហាដែរ”។ ពាក្យរបស់ចៅក្រមម្នាក់នេះប្រហែលជាពាក្យដែលក្រសោបនូវសកម្មភាពទាំងអស់នៅមន្ទីរស-២១ ក៏ថាបាន។

នៅគ្រប់ទីកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ “ប្រជាជនមូលដ្ឋាន”ភាគច្រើនតែងទទួលបាននូវឋានៈយ៉ាងប្រសើរ។ ប្រជាជនទាំងនេះត្រូវបានចាត់ទុកដូចជាសមាជិកបក្សកុម្មុយនិស្តដែលបានឆ្លងកាត់ “សម្ព័ន្ធយុវជនកុម្មុយនិស្ត” ទាំងត្រៀមទាំងពេញសិទ្ធិ។ ចំណែកឯ “ប្រជាជនថ្មី” វិញដូចជាប្រជាជនមកពីទីក្រុងឬប្រជាជនមានជំហរមិនបដិវត្ត ត្រូវបានហៅថា “ប្រជាជនបញ្ញើ” ជាងារបញ្ជាក់ថាប្រជាជនទាំងនេះជាអ្នកដែលត្រូវបានជម្លៀសទៅជនបទ។ អ្នកទោសនៅមន្ទីរស-២១មានឋានៈទាបជាងប្រជាជនបញ្ញើទៅទៀត។ មុនពេលសួរចម្លើយ អ្នកទោសត្រូវបានឆ្មាំឲ្យដោះសម្លៀកបំពាក់ខ្មៅបដិវត្តចេញ ហើយឆ្មាំក៏បោះខោអាវរហែករយ៉ៃដែលមិនសមនឹងខ្លួនឲ្យស៊ីកជំនួសវិញ។ ឆ្មាំគុកប្រើពាក្យ “អាម៉ីង-អ្ហែង-ហាង” ដូចភាសាប្រើចំពោះក្មេងនិងសត្វធាតុអ៊ីចឹង។ មុនពេលចាប់ផ្តើមសរសេរចម្លើយសារភាព អ្នកទោសតែងតែរៀបរាប់ពីប្រវត្តិរូបផ្ទាល់ខ្លួនជាមុនសិន។ ប៉ុន្តែប្រវត្តិរូបផ្ទាល់ខ្លួននៅពេលនេះមិនមានដាក់វណ្ណភាពដូចជានៅក្នុងឯកសារដែលបក្សតម្រូវនោះទេ។ អ្នកទោសត្រូវបានដោះសម្លៀកបំពាក់ចេញបំបាត់ភាពជាមនុស្សនិងវណ្ណភាព រំលោភបំពាន វាយដំច្រំធាក់ និងធ្វើឲ្យ

អាម៉ាស់មុខ ។ ឆ្នាំធ្វើយ៉ាងនេះរហូតទាល់តែអ្នកទោសឆ្លើយតាមអ្វីដែលបក្សចង់បាន ដែលជាការបង្ហាញថា អ្នកទោសត្រូវបានធ្វើបាបស្ទើរស្លាប់ស្ទើររស់ ។

## ការជំនុំជម្រះទោសរបស់សូវៀតដែលធ្វើឱ្យតែល្អមើល

ដូចយើងបានឃើញស្រាប់ហើយ កម្មាភិបាលធ្វើការនៅមន្ទីរ ស-២១ ធ្វើការដោយផ្អែកតែលើការសន្មតប៉ុណ្ណោះ ដែលថាអ្នកទោសមានកំហុសដោយសារតែការចោទប្រកាន់ ហើយការដែលចាត់ទុកអ្នកទោសក្រោមឋានៈមនុស្សទូទៅ គឺដោយសារតែអ្នកទោសទាំងនោះត្រូវបានចាប់ខ្លួន ។ គំនិតនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌ខ្មែរ ។ ប៉ុន្តែគួរវិពុកថា ការជំរុញឲ្យមានការសួរចម្លើយរយៈពេលយូរនៅមន្ទីរស-២១ដែលអមដោយការធ្វើទារុណកម្មដូវគុលាការ និងដើម្បីផលិតចេញជាឯកសារចម្លើយសារភាពដ៏ច្រើនហូរហៀរនោះ គឺមានប្រភពចេញមកពីបរទេសទៅវិញទេ ពោលគឺប្រភពមកពី"ការជម្រះក្តីស្តីគេនោះ"ដែលធ្វើឡើងនៅទីក្រុងមូស្គូ (ជួនកាលហៅថាមហាភយន្តរាយ) នៅឆ្នាំ១៩៣៦-១៩៣៨ ។ កាលនោះកម្មាភិបាលកុម្មុយនិស្តនិងឥស្សរជនសូវៀតរាប់រយនាក់បានឆ្លើយសារភាពជាសាធារណៈថា ខ្លួនបានធ្វើវិទ្ធង្សនាចារកម្មនិងប្រព្រឹត្តអំពើក្បត់ ។ ប៉ុន្តែការឆ្លើយសារភាពភាគច្រើនមិនមានលក្ខណៈត្រឹមត្រូវឡើយ ចេះតែឆ្លើយឲ្យតែបានៗប៉ុណ្ណោះ ។ មានមនុស្សរាប់ពាន់នាក់ផ្សេងទៀតត្រូវបានសម្លាប់ចោលដោយគ្មានការជម្រះក្តីឡើយ ។ ចម្លើយសារភាពយ៉ាងល្អិតល្អន់ដែលដកស្រង់នៅទីក្រុងមូស្គូគឺត្រូវបានធ្វើឡើងសម្រាប់តម្រូវចិត្ត ស្តាលីន តែប៉ុណ្ណោះ ។ ធ្វើនេះគឺដើម្បីឲ្យ ស្តាលីន លែងមានការភ័យខ្លាចនិងមមៃពីរឿង "ខ្មាំង" ព្រមទាំងដើម្បីពង្រីកអំណាចរបស់ខ្លួនផ្ទាល់ ។ ទាក់ទងរឿងនេះ វិសុទ្ធកម្មនិងចម្លើយសារភាពធ្វើឡើងនៅសូវៀតដូចគ្នាទៅនឹងចម្លើយសារភាពដែលចម្រាញ់នៅមន្ទីរ ស-២១ដែរ ។ ស្តាលីន បានចំណាយពេលយ៉ាងច្រើនទៅលើការជម្រះក្តី ដើម្បីបិទបាំងមិនឲ្យមតិសាធារណៈដឹងពុតុសសាយ ។ ប៉ុល ពត ក៏ដូច ស្តាលីន បានរៀបចំឈុតឆាកមួយចំនួនតូចប្រកបដោយការប្រុងប្រយ័ត្ននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៀត ចុងចោទជនជាតិសូវៀតដែលទទួលការចង្អុលបង្ហាញ (ឬបំពាក់ជំហរដោគជាំ) រួចហើយនោះភាគច្រើនមិនដែលបដិសេធពីកំហុសរបស់ខ្លួនទេ នៅពេលឡើងដល់តុលាការហើយកម្របាននិយាយការពារខ្លួនណាស់ ។ ករណីនេះមិនខុសពីចុងចោទនៅក្នុងប្រទេសកម្ពុជានៅសម័យក្រោយៗនេះទេ ។ អ្នកទោសនៅប្រទេសទាំងពីរនេះ ត្រូវចាត់ទុកថា "ថោកជាងសំរាមទៅទៀត" ។ ក្រោយពីអានចម្លើយសារភាពរបស់ខ្លួនឡើងវិញចំពោះមុខតុលាការរួចហើយ អ្នកទោសសូវៀតភាគច្រើនដូចអ្នកទោសនៅទួលស្លែងដែរគឺត្រូវបានសម្លាប់ចោលយ៉ាងសម្ងាត់បំផុត ។

នៅក្នុងករណីទាំងពីនេះ ការកាត់ទោសប្រហារជីវិតត្រូវបានធ្វើឡើងជាមុន ដូចជាសម្តីរបស់ រ៉េត យ៉ឺន ដែលថា "កាត់ទោសមុនសឹមសម្រេចជាក្រោយ" ។ ប៉ុន្តែនៅទីក្រុងមូស្គូ ពិសោធន៍នេះត្រូវធ្វើឡើងជាចំហនៅក្នុងតុលាការដែលមានលក្ខណៈយុត្តិធម៌នៅក្នុងសតវត្សរ៍ទី២០ ។ ចំណែកនៅមន្ទីរ ស-២១វិញ អ្វីៗគ្រប់យ៉ាងត្រូវតែសម្ងាត់គ្មានឱកាសបាននិយាយគ្នា ហើយទាំងអ្នកទោស ទាំងចៅក្រម មិនដែលចេញមុខទេ ។ មូលហេតុដែលនាំឲ្យមានភាពខុសគ្នាគឺថា ការជម្រះទោសនៅទីក្រុងមូស្គូធ្វើឡើងដោយចេតនា ដើម្បីបង្ហាញថាសហភាពសូវៀតជាអ្នកដឹកនាំចលនាកុម្មុយនិស្តពិភពលោក ចំណែកថ្នាក់ដឹកនាំខ្មែរក្រហមមិនខ្វល់នឹងទស្សនៈពិភពលោកទេ ហើយជឿថាការរក្សាភាពសម្ងាត់ គឺជាធាតុផ្សំយ៉ាងសំខាន់សម្រាប់នាំខ្លួនទៅដល់ជោគជ័យ ។

ភាពខុសគ្នាមួយទៀតរវាងដំណើរការនៃនីតិវិធីទាំងពីរនេះគឺថាការធ្វើទារុណកម្មលើរាងកាយមុនពេលមានការជម្រះក្តីនៅសូវៀតហាក់ដូចជាមិនសូវជាញឹកញាប់ប៉ុន្មានទេ ហើយមានកម្រិតទៀតផង គឺគ្រាន់តែមិនឲ្យអ្នកទោសដេក និងដាក់អ្នកទោសចំពន្លឺភ្លើងខ្លាំង បន្ទាយពេលវេលាសួរចម្លើយ ផ្តល់អាហារមិនគ្រប់គ្រាន់និងការដាក់ឲ្យនៅតែឯង ។ សូលហ្សិន នីតស៊ីន បានសរសេរដោយយោងតាមបទពិសោធន៍របស់ខ្លួនដែលត្រូវទទួលរងការសួរចម្លើយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០ថា "អ្នកសួរចម្លើយខ្ញុំ បានប្រើវិធីផ្សេងៗមកលើខ្ញុំជាជាងមិនឲ្យដេកលក់ ភូតភរ និងគំរាមកំហែង ។ អ្វីៗគ្រប់យ៉ាងគឺតាមច្បាប់ទាំងអស់" ។

នៅមន្ទីរស-២១ ការគាបសង្កត់ទាំងនេះត្រូវបានប្រើប្រាស់ជាមួយនឹងការប្រើអំពើហិង្សា ។ វិធីសាស្ត្ររបស់សូវៀត វាគ្រប់គ្រាន់ទៅហើយសម្រាប់វាយបំបាក់អ្នកទោស ។ ទារុណកម្មលើរូបរាងកាយត្រូវបានធ្វើឡើងតែនៅពេលណាដែលមើលទៅអ្នកទោសហាក់ដូចជាមានសុខភាពមាំមួននៅមុខតុលាការ ហើយស្តាប់ទៅ អ្នកទោសអាចឆ្លើយតាមចិត្តរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើទារុណកម្មលើរាងកាយត្រូវបានអនុញ្ញាតឲ្យប្រើដោយ ស្តាលីន ទៅលើ "ខ្មាំងរបស់ប្រជាជនដែលល្បីល្បាញនិងពិបាកកម្ចាត់" តែប៉ុណ្ណោះ ដោយសារថាអំពើនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយ "ភ្នាក់ងារស៊ើបការណ៍គហបតី" ។ ចំណែកឯជនរងគ្រោះនៅមន្ទីរស-២១ ដែលបានមិនបញ្ចេញឲ្យឃើញវិញ អាចត្រូវបានវាយដំនិងធ្វើទារុណកម្មញឹកញយឬសាហាវយ៉ាងណាស្រេចតែលើអ្វីដែលអ្នកចាប់ចងយល់ថាសមស្រប ។

ទោះបីជាមានការកត់ទុកក្នុងចិត្តអំពីការខុសប្លែកគ្នាយ៉ាងនេះក៏ដោយ ប៉ុន្តែក៏នៅមានភាពដូចគ្នាច្រើនរាប់មិនអស់ដែលមិនមែនជាការចៃដន្យឡើយរវាងការចោទប្រកាន់និងការឆ្លើយសារភាពនៅសូវៀតនិងនៅមន្ទីរស-២១ ។ តើគំរូទាំងនេះមកដល់កម្ពុជាដោយរបៀបណាទៅ? ចម្លើយគឺ"បងៗថ្នាក់លើ" ភាគច្រើនដឹងច្បាស់អំពីការជម្រះក្តីនៅមូស្គូនេះ ។ ប៉ុល ពត សុន សេន អៀង សារី និង ខៀវ សំផន អាចដឹងអំពីការជម្រះក្តីទាំងនេះនៅដើមទសវត្សរ៍ឆ្នាំ១៩៥០ពេលអ្នកទាំងនេះកំពុងរៀននៅស្រុកបារាំងនិងធ្វើជាសមាជិកបក្សកុម្មុយនិស្តបារាំង ។ និស្សិតក្រហមទាំងនេះអាចបានអានឯកសារទិនានុប្បវត្តិនិងពត៌មានសង្ខេបរបស់បក្សដែលនិយាយពីរឿងវិសុទ្ធកម្មនិងក៏ប្រហែលជាបានដឹងនិងយល់ស្របតាមការជម្រះក្តីដែលរៀបចំឡើងដោយសូវៀតនៅប្រទេសឆេកូស្លូវ៉ាគី ហុងគ្រី និងប្រទេសផ្សេងៗទៀតដែលជាប្តូករបស់សូវៀតដែរ ។

ទោះជាមិនបានបញ្ចេញយោបល់ជាសាធារណៈចំពោះការជម្រះក្តីក៏ដោយ ប៉ុន្តែជនជាតិកម្ពុជាវ័យក្មេងទាំងនេះច្បាស់ជាមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការធ្វើទោសដោយខ្លួនឯងរបស់ជនជាប់ចោទ ភ័ស្តុតាងលម្អិតគ្រប់បែបយ៉ាងប្រឆាំងនឹងជនជាប់ចោទ និងការរកយុត្តិធម៌បដិវត្តជាមួយនឹងថ្នាក់ដឹកនាំដែលលាក់មុខនិងមានអំណាចបំផុត ។ ការហ៊ឹកហ៊ឺនរបស់ខ្លួននៅក្នុងបក្សកុម្មុយនិស្តបារាំងដែលគាំទ្រ ស្តាលីន ដាច់ខាតពិបាកនឹងគាំទ្រជនរងគ្រោះរបស់ ស្តាលីន ឬកោតសរសើរសុជីវធម៌របស់គហបតីដែលជាការប្រឆាំងនឹងយុត្តិធម៌បដិវត្តណាស់ ។ ពេលវេលាមកដល់ ចម្លើយសារភាពដែលដកស្រង់នៅមន្ទីរ ស-២១ ដូចគ្នាទៅនឹងគំនិតសង្ស័យនិងមិនទុកចិត្តគ្នា ការគិតថា អ្វីៗទាំងមូលវាសំខាន់ជាង ដោយផ្នែកទម្រង់នៃការចោទប្រកាន់និងដំណើរការសួរចម្លើយនៅក្នុងការជម្រះក្តីនៅសូវៀតដែលធ្វើឲ្យតែល្អមើលនោះ ។ តាមរយៈករណីទាំងពីរនេះ បក្សកុម្មុយនិស្តមួយដែលមមៃដល់ប្រវត្តិសាស្ត្រ បានធ្វើវិសុទ្ធកម្មលើខ្លួនឯងដើម្បីការពារមេដឹកនាំរបស់ខ្លួនដែលចេះតែមានការសង្ស័យ ។ ទង្វើបែបនេះមិនមែនជាការដែលគួរឲ្យភ្ញាក់ផ្អើលអ្វីទេ ។

## គំរូរបស់ប្រទេសចិននិងវៀតណាម

គំរូមួយទៀតដែលនាំឲ្យមាននីតិវិធីឃោរឃៅព្រៃផ្សៃនៅមន្ទីរ ស-២១ គឺបានមកពីវិសុទ្ធកម្មរបស់បក្សកុម្មុយនិស្តនិងយុទ្ធនាការអប់រំកសាងខ្លួននៅក្នុងប្រទេសចិនដែលជ្រាបរហូតមកដល់ប្រទេសវៀតណាម ។ ជនកុម្មុយនិស្តកម្ពុជាដែលកំពុងតែប្រកៀកស្មាប្រយុទ្ធជាមួយវៀតណាមនៅក្នុងសង្គ្រាមឥណ្ឌូចិន (១៩៤៦-១៩៥៤) ប្រហែលជាបានដឹងពីបច្ចេកទេសសួរចម្លើយរបស់សូវៀត "ការអប់រំកសាងខ្លួន" តាមបែបចិន និងទម្រង់ធម្មតានៃចម្លើយសារភាព"ដែលប្រឆាំងនឹងបដិវត្តន៍" តាមរយៈវៀតណាមដែលជាអ្នកឧបត្ថម្ភខ្លួន ។ ការហ៊ឹកហាត់របស់វៀតណាមចំពោះកម្មាភិបាលខ្មែរក្នុងផ្នែកសន្តិសុខប្រសិនបើមានគឺប្រហែលជាយកតាមគំរូរបស់ចិន ។ នៅដំណាក់កាលដំបូងនេះមានការកែយុទ្ធនាការតម្រង់ *(zhen-fan)* ដែលធ្វើឡើងនៅ *Yan's* នៅឆ្នាំ១៩៤៣និងយុទ្ធនាការកែទម្រង់ដីធ្លីនៅចិនខាងជើងក្រោយឆ្នាំ១៩៤៩ ។ រលកវិសុទ្ធកម្មកើតឡើងនៅទូទាំងប្រទេសចិននិងវៀតណាមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ ។ មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ អាជីពការងាររាប់ពាន់ត្រូវបានបំផ្លាញ ហើយមនុស្សរាប់សែននាក់ត្រូវបានចាប់មកសួរចម្លើយរួចហើយក៏លែងទៅវិញ ។ **(នៅមានត)**

# ខៀវ សំផន: រឿងនេះជាអំពើឃោរឃៅផ្ទាល់របស់បុគ្គល

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ បានសរសេរសំបុត្រចំហជូនបងប្អូនជនរួមជាតិទាំងអស់ដើម្បីលាតត្រដាងអំពីភាពគ្មានទោសរបស់ខ្លួន ។ ខៀវ សំផន បានអះអាងនៅក្នុងសំបុត្រចំហរបស់ខ្លួនថា «ការកាប់សម្លាប់ក៏ខ្ញុំមិនបានដឹងអ្វីទាំងអស់ ។ នៅរវាងពាក់កណ្តាលឆ្នាំ១៩៧៨ ខ្ញុំបានឮដោយចៃដន្យអំពីករណីមួយនៃការចាប់ចងនិងអំពើឃោរឃៅនៅក្នុងខេត្តព្រះវិហារ» ។ ដោយសារតែភាពខ្វល់ខ្វាយក្នុងការអះអាងថា ខ្លួនជាជនស្លូតត្រង់ ហើយគ្មានកំហុសនោះ ខៀវ សំផន បានបកស្រាយចំពោះការសម្លាប់មនុស្សដ៏ឃោរឃៅនៅក្នុងខេត្តព្រះវិហារថា «រឿងនេះជាអំពើឃោរឃៅផ្ទាល់របស់បុគ្គល» ទៅវិញ ។

ខ្ញុំយល់ថា ការសម្លាប់មនុស្សដ៏ឃោរឃៅនៅខេត្តព្រះវិហារមិនមែនជា«អំពើ» និង«បញ្ហា»ដោយលេខាភូមិភាគតែម្នាក់គត់ដូចដែល ខៀវ សំផន បាននិយាយនោះទេ ។ សកម្មភាពទាំងឡាយ និងផែនការដ៏ជាក់លាក់ចំពោះករណីសម្លាប់មនុស្សនៅខេត្តព្រះវិហារ គឺបានកើតចេញមកពីសេចក្តីសម្រេចចិត្តរបស់មេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជា ។ ជាការពិត ដូចដែល ខៀវ សំផន បាននិយាយអឺចឹងថា «ការសម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃស្តាប់ទៅគួរឲ្យព្រឺក្បាល» ។

បន្ថែមទៅលើតួនាទីជាគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានទទួលស្គាល់ថាខ្លួនជាសមាជិកមួយរូបនៃ«មន្ទីរ៨៧០» ។ ឯកសារជាច្រើនដែលកម្មាភិបាលថ្នាក់ក្រោមបញ្ជូនមក«មន្ទីរ៨៧០» និងឯកសារជាច្រើនដែលមន្ទីរនេះបានបញ្ជូនទៅកន្លែងផ្សេងៗទៀតទាក់ទងនឹងបញ្ហាដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខាងក្រោមនេះខ្ញុំសូមបង្ហាញជូននូវឯកសារទូរលេខ៣ច្បាប់ដែលបញ្ជាក់ពីសកម្មភាពឃោរឃៅដែលកើតមាននៅក្នុងខេត្តព្រះវិហារ ÷

◆◆◆ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ សែ បានផ្ញើទូរលេខ ២៥៤ជូនគណៈ៨៧០ ដោយរាយការណ៍អំពីសភាពការណ៍នៅតាមព្រំដែននៃខេត្តព្រះវិហារនិងខេត្តឧត្តរមានជ័យ ។ សែ បានរាយការណ៍ថា «ខ្មាំងបានធ្វើសកម្មភាពឆក់ឱកាសក្នុងពេលដែលយើងកំពុងវាយយួននៅសមរភូមិមុខ វាក៏អុកឡុកយើងនៅសមរភូមិក្រោយដែរ» ។ សែ បានរាយការណ៍ទៀតថា «សភាពការណ៍នៅតំបន់១០៣ ខ្មាំងបង្កប់ស៊ីរូងនិងខ្មាំងចោរព្រៃបានធ្វើសកម្មភាពជាបន្តបន្ទាប់ដោយកម្មាភិបាលមួយចំនួនមានលក្ខណៈសម្រុះសម្រួលខ្មាំង បើកដៃឲ្យខ្មាំងធ្វើសកម្មភាពបានតាមចិត្ត ។ ដូច្នេះខ្មាំងស៊ីរូងតាំងពីតំបន់ ស្រុក រហូតដល់សហករណ៍ ។ ខ្មាំងវាបំផ្លាញការបង្កបង្កើនផលសមូហភាពបានជាបន្តបន្ទាប់តាំងពីភ្ជួររាស់ដកស្ទូង ច្រូតកាត់ រហូតដល់ស្រូវក្នុងជង្រុក ។ ឆ្នាំនេះ ជាទូទៅក្នុងតំបន់ព្រះវិហារកន្លែងភាគច្រើនត្រូវអត់បាយ» ។ ចំពោះបាតុភាពខាងលើនេះ សែ បានស្នើវិធានការ៤ចំណុចដល់គណៈមន្ទីរ៨៧០ដូចតទៅ «១) កាត់ផ្តាច់ស្បៀងខ្មាំងដោយប្រមូលស្រូវជាប់ៗព្រៃឲ្យបានអស់និងជាបន្ទាន់កុំឲ្យខ្មាំងលួចបាន ។ ២) កាត់ផ្តាច់ការទាក់ទងខ្មាំងពីខាងក្រៅ និងខ្មាំងនៅតាមមូលដ្ឋាន តាមភូមិដែលនៅជាប់ព្រៃ ។ ត្រូវប្រមូលឲ្យអស់និងជាបន្តបន្ទាប់ ពិសេសនៅតាមព្រំដែនត្រូវរៀបចំកន្លែងយោធានិងដកប្រជាជន ដកពួកសមាសភាពអាក្រក់ប្រមូលផ្តុំដាក់ការដ្ឋាន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងកុំឲ្យខ្មាំងពីក្រៅទាក់ទង ។ ៣) ពង្រឹងសហករណ៍ ពិសេសផ្អែកលើវណ្ណៈមូលដ្ឋាន ដើម្បីបោសសម្អាតខ្មាំងបង្កប់ ក៏ដូចជាខ្មាំងចោរព្រៃ ។ ៤) តំបន់ស្រុកត្រូវមានវិធានការរុករកខ្មាំងនិងវាយខ្មាំងគ្រប់ច្រកល្ហកចេញចូលតាមដែលយើងក្តាប់ក្រិត្យក្រមខ្មាំងបាន» ។ សែ បានបញ្ជាក់ថា «ចាប់តាំងពីថ្ងៃ ១១ មករា នេះ ខ្ញុំចុះទៅធ្វើការនៅតំបន់១០៣ហើយ ។ ដោយប៉ុន្មានថ្ងៃនេះជាប់បើកវគ្គរៀនឲ្យកម្មាភិបាលមូលដ្ឋានមន្ទីរក្រសួងយោធាបានជាមិនបានទៅភ្នំ ។ ប៉ុន្តែខ្ញុំបានឲ្យមិត្ត ប៉ុន ចាន់ ជំនួសនៅតំបន់នោះហើយ» ។ ទូរលេខនេះបានចម្លងជូន អ៊ុំ អ៊ុំនួន បងវ៉ាន់ បងវន បងខៀវ មន្ទីរ ឯកសារ ហើយបញ្ជាក់កាលបរិច្ឆេទទទួលនៅថ្ងៃទី១២

ខែមករា ឆ្នាំ១៩៧៨ ម៉ោង៨:៣០នាទី ។

◆◆◆ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ សែ បានផ្ញើទូរលេខ ៣១៣រាយការណ៍អំពីសកម្មភាពខ្មាំងនៅតាមព្រំដែនខេត្តព្រះវិហារដល់"មន្ទីរ៨៧០" ។ សែ បានរាយការណ៍អំពីសភាព–ការណ៍បីចំណុចគឺ "១) សភាពការណ៍ខ្មាំង ២) សភាពការណ៍ចោរព្រៃ និង ៣) សភាពការណ៍ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" ។ ចំពោះសភាពការណ៍ខ្មាំង សែ បានរាយការណ៍ថា "ខ្មាំងគ្មានលទ្ធភាពអុកឡុកយើងតាមព្រំដែនទេ ហើយមានតែកម្លាំង អ៊ិន តាំ ប៉ុណ្ណោះដែលលបលួចវាយឈ្លបនៅព្រំដែនខេត្តព្រះវិហារ" ។ សែ បានបញ្ជាក់ថា "ខ្មាំងអាចពង្រេចពង្រើលយើងបានខ្លះៗមកពីមូលហេតុផ្ទៃក្នុងកងទ័ពយើងមិនទាន់ល្អ ។ បញ្ហានេះបានមានវិធានហើយ" ។ ចំណែកឯសភាពការណ៍នៅតាមព្រំដែនលាវ សែ បានរាយការណ៍ថា "យើងបានឃើញខ្មាំងចំនួនមួយកងអនុសេនាតូចបោះជំរំនៅអូរអាកង ។ វាឲ្យគ្នាវាបីនាក់ចូលមកដីយើងនៅម្តុំពាមអូរពោនប៉ះចំរូងយើងត្រូវរបួសវាដកថយវិញ" ។ សែ បានរាយការណ៍អំពីសភាពការណ៍របស់ចោរព្រៃថា សព្វថ្ងៃមានចោរព្រៃមួយក្រុមប្រមាណពី៣០ទៅ៤០នាក់នៅព្រៃស្អាក ជាប់តំបន់ព្រះវិហារមកស្រុកវ៉ារិន ទល់នឹងស្រុកស្រីស្នំ និងស្រុកអន្លង់វែង ។ សែ បានបញ្ជាក់ថា វិធានការកន្លងមក កងទ័ពស្រុកនិងតំបន់កំពុងតែរុករកកម្ទេចចោរព្រៃទាំងនេះ ។ "យើងកម្ទេចនិងចាប់បានអាចោរព្រៃទាំងនេះជាបន្តបន្ទាប់" ។ ចំពោះសភាពការណ៍ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង សែ បានរាយការណ៍ថា "នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើងនៅតាមការដ្ឋាន ។ ពួកខ្មាំងទាំងនេះវាទាក់ទងជាមួយប៉ូលិស ទាហាន និងពួករដ្ឋការ ហើយបន្លំធ្វើជាប្រជាជនថ្មី ។ បន្ទាប់ពីវាធ្វើសកម្មភាពប្រឆាំងនឹងយើង ទើបយើងស្គាល់មុខវាច្បាស់ ទន្ទឹមនឹងនេះយើងបានបោសសម្អាតវាជាខ្សែចង្វាក់ ។ មកដល់ថ្ងៃនេះ សភាពការណ៍ខ្មាំងបង្កប់ត្រូវស្ងប់ស្ងាត់ ក្រោយពីយើងបោសសម្អាតចំនួនប្រមាណ២០ក្បាល ។ យើងក៏មានវិធានការបន្តរកចាប់ខ្សែពួកនេះតទៅទៀត ។ ឯខ្មាំងបង្កប់នៅតំបន់ព្រះវិហារ ក្រោយពីយើងបានបោសសម្អាតនិងកំពុងបោសសម្អាតតទៅទៀតនោះ ក៏គ្មានបណ្តាលឲ្យមានបាតុភាពអ្វីទេ សភាពការណ៍យើងដំណើរការធម្មតា" ។

◆◆◆ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ សែ បានផ្ញើទូរលេខ ៣២៤មក"គណៈ៨៧០"អំពីសភាពការណ៍បោសសម្អាតខ្មាំងនៅតំបន់១០៣ ។ សែ បានរាយការណ៍ថា "កាលពីមុន អ៊ិន តាំ ប្រើប្រាស់កម្លាំងនៅតំបន់១០៣ដែលមាន"អាហង់"ជាមេធ្វើជាបង្អែក ។ ប៉ុន្តែក្រោយពីយើងចាប់"អាហង់" និងដៃជើងរបស់វានៅក្នុងស្រុកជាំក្សាន្ត និងនៅក្នុងកងទ័ពតំបន់១០៣មក ពួក អ៊ិន តាំ ត្រូវអស់បង្អែក ។ សភាពការណ៍ខ្មាំងខាងក្នុងគ្មានអ្វីប្រែប្រួលធំដុំទេ យើងកំពុងបន្តបោសសម្អាតពួកនៅសេសសល់ជាបន្តបន្ទាប់ទៀតទោះបីជាវាប្រឆាំងបដិវត្តន៍យើងដោយចំហក្តីនិងដោយសម្ងាត់ក្តី ។ នៅតំបន់១០៣ យើងបានដំណើរការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងបានល្អ ហើយខ្មាំងងើបក្បាលឡើងវិញលែងរួច ។ ការបោសសម្អាតខ្មាំងនៅតំបន់១០៣នេះប្រជាជនមានការរីករាយជាអតិបរមា" ។ សែ បានបន្ថែមទៀតថា "នារីសុន ប្រពន្ធរបស់សមមិត្តម៉ាន ត្រូវខ្មាំងឆ្លៀយដាក់ច្រើនៗ ខ្ញុំសម្រេចដកនារីនេះឲ្យមកសម្រាកនៅមន្ទីរភូមិភាគ៨០១ដើម្បីទប់ទល់កុំឲ្យនារីនេះបន្តសកម្មភាពក្បត់តទៅទៀត ។ ចំពោះខ្មាំងជាចោរព្រៃដែលពីមុន"អាហង់" វាចាត់តាំងឲ្យមកនៅព្រៃស្អាកជាប់នឹងស្រុកវ៉ារិននោះ យើងបានចាប់ ហើយកម្ទេចវាជាបន្តបន្ទាប់ ។ យើងកំពុងដំណើរការរុករកវាតទៅទៀត" ។

**ហ៊ុយ វណ្ណៈ**

## ពាក្យស្លោកខ្មែរក្រហម

◆ **វាយសំរុកសម្រេចផែនការកសាងប្រទេសគ្រប់ផ្នែកឱ្យបាន ១០០ភាគរយដោយគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ច្នៃប្រឌិត គំនិតផ្តើម និងសន្សំសំចៃកម្រិតខ្ពស់បំផុត។**

◆ **សមរភូមិ សង្គមកិច្ច សុខាភិបាល សិក្សា ឃោសនាអប់រំ ប្តេជ្ញាវាយសំរុកសម្រេចផែនការ១០០ភាគរយនិងឱ្យលើសថែមទៀត។** *(សៀវភៅលេខ ០៧៦ កណប)*

◆ **ប្រមូលផល ទុកដាក់ផល និងថែរក្សាការពារផលឱ្យបានគត់មត់និងគង់វង្ស១០០ភាគរយ។**

*(ឯកសារ D១៣៧៩២)*

# សង្គមបរិសុទ្ធដែលគ្មានក្រដាសប្រាក់

នៅតាមតំបន់រំដោះមួយចំនួននៃស្រុកក្រូចឆ្មារក្នុងខេត្តកំពង់ចាមនិងមួយចំនួននៃស្រុកស្អាងនិងស្រុកកោះធំក្នុងខេត្តកណ្តាល ខ្មែរក្រហមបានលុបបំបាត់ទីផ្សារលក់ដូរតាំងពីឆ្នាំ១៩៧២ ហើយបានជំនួសវិញដោយបង្កើតពាណិជ្ជកម្មរដ្ឋនៅតាមសហករណ៍ ដោយអនុញ្ញាតឲ្យប្រជាជនទិញសម្ភារប្រើប្រាស់និងគ្រឿងឧបភោគបរិភោគពីពាណិជ្ជកម្មរដ្ឋនៅតាមសហករណ៍នីមួយៗក្រោមរបបកំណត់ដាក់លាក់។ នៅក្រោយឆ្នាំ១៩៧៥ នយោបាយនេះកាន់តែស៊ីជម្រៅ គឺកម្ទេចដាច់ខាតមូលដ្ឋាននៃវណ្ណៈនាយទុនសក្តិភូមិឲ្យបានឆាប់រហ័សជាងមុន។ ខ្មែរក្រហមបានបំបាត់ពាណិជ្ជកម្មរដ្ឋតាមសហករណ៍និងទុកឲ្យមានតែពាណិជ្ជកម្មរដ្ឋថ្នាក់មជ្ឈិម។ ដូច្នេះនៅពេលដែលលុបបំបាត់ពាណិជ្ជកម្មរដ្ឋថ្នាក់ក្រោម ខ្មែរក្រហមបានដាក់បញ្ញត្តិឲ្យអង្គការគ្រប់លំដាប់ថ្នាក់គ្រប់គ្រងទ្រព្យសម្បត្តិនិងសេដ្ឋកិច្ចរដ្ឋ។

ក្នុងការកសាងសេដ្ឋកិច្ច អង្គការបដិវត្តបានដាក់ចេញនូវគោលការណ៍ដែលបោះពុម្ពផ្សាយនៅក្នុងឯកសារទង់បដិវត្តន៍លេខពិសេសនៅក្នុងខែធ្នូ-មករា ឆ្នាំ១៩៧៥-១៩៧៦ មាន៣ចំណុចៈ "ចំណុចទី១គឺ មាគ៌ាបង្កបង្កើនផលផលិតកម្មស្រូវ។ មាគ៌ានេះបម្រើបានគោលជំហរឯករាជ្យម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនកម្រិតខ្ពស់បំផុតតាំងពីឆ្នាំ១៩៧២។ ចំណុចទី២ គឺរដ្ឋក្តាប់ផ្នែកពាណិជ្ជកម្មសំខាន់ទាំងអស់។ ចំណុចទី៣ គឺការរៀបចំចាត់តាំងសហករណ៍នៅតំបន់រំដោះ ទី១ ទី២កម្រិតទាប-កម្រិតខ្ពស់ដែលជាវិធានការវាយការទាក់ទងផលិតកម្មថ្មី។ សហករណ៍ជាបង្អែកឲ្យកសិករក្រនិងកសិករកណ្តាលថ្នាក់ក្រោម។ សហករណ៍នេះវាយទាំងចក្រពត្តិ សក្តិភូមិ ម្ចាស់ដី និងនាយទុន។ ចំណុចពិសេសទី៤ គឺការមិនចាយលុយ។ វិធានការនេះ យើងចាប់ផ្តើមពីឆ្នាំ១៩៧៣។ មិនចាយលុយមានន័យទាំងបដិវត្តប្រជាជាតិនិងប្រជាធិបតេយ្យ ហើយទប់ទល់ខ្លាំងបន្ទយកម្លាំងខ្លាំងខាងហិរញ្ញវត្ថុបាន។ ន័យខាងប្រជាធិបតេយ្យគឺជាមធ្យោបាយមួយកម្ទាត់កម្មសិទ្ធិឯកជន ជាសម្ភារ ជាគោលជំហរសតិអារម្មណ៍។ ជាកម្លាំងធំណាស់ក្នុងការធ្វើបដិវត្តប្រជាជាតិប្រជាធិបតេយ្យ។ បើគ្មានវិធានការទាំងនេះ យើងគ្មានកម្លាំងខាងសេដ្ឋកិច្ចហិរញ្ញវត្ថុ។"

លុយជាបញ្ហាមួយដែលធ្វើឲ្យមានកម្មសិទ្ធិឯកជន។ កម្មសិទ្ធិឯកជននេះហើយបណ្តាលឲ្យមានវិសមភាពសង្គមនិងអំពើពុករលួយ។ ខ្មែរក្រហមបានបញ្ឈប់ចរាចរណ៍ប្រាក់ដើម្បីវាយកម្ទាត់កម្មសិទ្ធិបុគ្គលសួនតួ។ ឯកឧត្តម ម៉ាត់ លី បានមានប្រសាសន៍ថា "ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ប៉ុល ពត បានថ្លែងក្នុងពេលបើកសន្និបាតមួយនៅក្រុងភ្នំពេញដើម្បីអនុមតិគោលការណ៍៨ចំណុច។ គោលការណ៍ទី៣បានចែងថា "បញ្ឈប់ការចាយលុយ ហើយលុបបំបាត់ទីផ្សារ"។ បើមានផ្សារមានការលក់ដូរ នឹងមានអ្នកជិះជាន់និងអ្នកដែលត្រូវគេជិះជាន់ សំណូមពររបស់ប្រជាជនយើងកុំឲ្យចាយលុយ។ បើចាយលុយពិបាកណាស់។ បើចាយលុយនៅមានអ្នកស៊ីលុយ អ្នកសូកប៉ាន់។ ត្រូវបង្កើតសហករណ៍ឲ្យទៅជាសហករណ៍ភាវូបនីយកម្ម។ ទាំងចៅហ្វាយស្រុកអីក៏ដោយ មានត្រឹមបង្ហុចដាក់លើខ្នងជាកម្មសិទ្ធសមរម្យរបស់គេហើយ។ ប៉ុល ពត បានបន្ថែមទៀតថា ពេលនេះប្រជាជនសម្រេចចិត្តមិនចាយលុយទេ។ ឥឡូវតើកម្មាភិបាលសម្រេចថាចាយឬមិនត្រូវចាយ សូមសមមិត្តសរសេរដាក់ជីវទស្សន៍។ ប៉ុន្តែបើតាមយើងមើលឲ្យឃើញទៅបើអ្នកណាសរសេរបែបប្រឆាំងបន្តិចនោះបាត់ខ្លួនតែម្តង។ ដូចនេះយើងថាមិនចាយលុយដូចតែគេដែរ"។

ដើម្បីសម្រេចតាមគោលនយោបាយបំបិទចរាចរណ៍ប្រាក់ ប៉ុល ពត ត្រូវតែកម្ទេចចោលចំពោះអ្នកដែលប្រឆាំងជាមួយការសម្រេចរបស់ខ្លួន។

លោក រៀល សន ប្រធានពេទ្យស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថា "មានការប្រជុំមួយនៅក្នុងស្រុកត្រាំកក់អំពីការ

ចាយលុយឬមិនចាយលុយ ។ ប៉ុន្តែមុននឹងសួរប្រជាជន ខ្មែរក្រហមបានធ្វើការណែនាំជាច្រើនថា លុយវាធ្វើឲ្យខូចសតិអារម្មណ៍មនុស្សនិងមានការភ្លើតភ្លើន ។ ដូចនេះគ្មាននរណាម្នាក់ហ៊ាននិយាយថាចាយលុយទេ ។ នៅស្រុកត្រាំកក់ ខ្មែរក្រហមបានប្រកាសមិនចាយលុយមុនគេ ដែលជាហេតុធ្វើឲ្យស្រុកដទៃទៀតអត់ហ៊ានថាចាយលុយដែរ រួចក៏អត់ចាយទូទាំងប្រទេសទៅ» ។

លោក គឹម ហេង អតីតកម្មាភិបាលពេទ្យនៅខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ បច្ចុប្បន្នរស់នៅភូមិគាលាក់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ បានឲ្យដឹងថា ឆ្នាំ១៩៧៦ មានការស្ទង់មតិនៅក្នុងតំបន់របស់គាត់ឲ្យប្រជាជនបញ្ចេញទស្សនៈថាចង់ចាយលុយឬមិនចង់ចាយលុយ ។ ហេង បន្ថែមថា កាលនោះរូបគាត់ព្រមទាំងមនុស្សមួយចំនួនទៀតបាននិយាយដោយត្រង់ថា ចាយលុយទើបល្អ មិនចាយលុយមិនល្អទេ ទោះមិនចាយជាបុគ្គលក៏ចាយជាសហករណ៍ឃុំដែរ ។ ប៉ុន្តែអ្នកដែលបាននិយាយថាចាយលុយល្អទាំងប៉ុន្មានត្រូវយកទៅសម្លាប់ចោលទាំងអស់ លើកលែងតែ ហេង ម្នាក់ដែលរួចជីវិត ដោយសារគណៈឃុំបានជួយគាត់ ។

ប៉ុល ពត បានប្រកាសនៅក្នុងឱកាសខួបលើកទី១៦របស់បក្សកុម្មុយនិសកម្ពុជាប្រារព្ធនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ថា «លុយឧបករណ៍មួយពិលពុលបំផុតវាអាចទាញយើងឲ្យមករកភាពឯកជនវិញរាល់ពេល ។ ឥឡូវនេះគ្មានអ្នកណានឹកចង់ចាយលុយទេ នេះជាលក្ខណៈសម្បត្តិមួយសំខាន់ដែលអនុគ្រោះឲ្យយើងកម្ចាត់ចោលគោលជំហរកម្មសិទ្ធិ និងបំពាក់គោលជំហរសមូហភាពបានឆាប់រហ័ស ។ បើមានលុយមានប្រាក់ខែ លុយវាគាបយើងជាប់ ហើយទាញយើងមិនឲ្យអនុវត្តទៅជាសមូហភាពបាន» ។

លោក វៀល សន បានបញ្ជាក់បន្ថែមថា «ប៉ុល ពត បាននិយាយថាមិនចាយលុយ ប៉ុន្តែ ហ៊ូ នឹម ជំទាស់ថាចាយលុយពីព្រោះលុយបានបោះពុម្ពរួចហើយ ។ ដោយសារការជំទាស់នេះទើប ហ៊ូ នឹម ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល» ។ តាមឯកសារដែលបន្សល់ទុកនៅមន្ទីរស-២១ (ឬគុកទួលស្លែង) បានឲ្យដឹងថា ហ៊ូ នឹម ត្រូវចាប់ខ្លួននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ និងត្រូវកម្ទេចនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ ដដែល ពីមូលហេតុ ចោទប្រកាន់ថាក្បត់បក្ស ។ នៅក្នុងសម័យខ្មែរក្រហម រដ្ឋកាន់កាប់ដោយផ្តាច់មុខនូវផលិតកម្មជាយុទ្ធសាស្ត្រ ឧស្សាហកម្មនានា ដោយយល់ថា លុយគ្មានប្រយោជន៍អ្វីទេ ហើយត្រូវតែបំបាត់ចោល ។ ប៉ុល ពត បានថ្លែងនៅក្នុងអង្គប្រជុំជាមួយគណៈប្រតិភូសមាគមបែលស៊ិក-កម្ពុជា នៅភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ថា «នៅក្នុងតំបន់រំដោះយើងខ្ញុំ តួនាទីរបស់ប្រាក់កាសក៏កាន់តែចុះថយ អស់យ៉ាងឆាប់នៅឆ្នាំ១៩៧៤ ។ មុនរំដោះអត់មានចាយលុយទេ ។ ទម្លាប់នេះនាំឲ្យយើងខ្ញុំឈប់ចាយលុយកាក់រហូតមកដល់សព្វថ្ងៃ» ។

ដើម្បីឲ្យការលុបបំបាត់ក្រដាសប្រាក់មានប្រសិទ្ធភាព ខ្មែរក្រហមត្រូវតែបំផ្លាញចោលនូវសកម្មភាពដោះដូរទំនិញ បំបាត់ទីផ្សារគ្រប់ប្រភេទ ដូចពាក្យស្លោកថា «គ្មានលក់ គ្មានដូរ គ្មានថ្លៃ គ្មានថ្លូច គ្មានលួច គ្មានប្លន់ គ្មានកម្មសិទ្ធិសួនតួ» ។ ការធ្វើបែបនេះ ខ្មែរក្រហមយល់ថាដើម្បីកសាងប្រទេសស្អាតស្អំមានសង្គមសមូហភាពនិងជាសង្គមថ្មីមួយ ត្រូវប្រឆាំងដាច់ខាតនឹងវប្បធម៌ពុករលួយប្រតិកិរិយារបស់វណ្ណៈជិះជាន់ទាយទុនសក្តិភូមិ រួចបង្កើតជំនួសវិញនូវ «ពាណិជ្ជកម្មរដ្ឋ» ។

ទោះជាមិនមានការចាយក្រដាសប្រាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ក្រដាសប្រាក់ត្រូវបានបោះពុម្ពរួចទៅហើយនៅក្នុងឆ្នាំ១៩៧៥ ។ ពេលដែលប្រទេសកម្ពុជាទើបតែធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យថ្មីៗ មានប្រជាជនមួយចំនួនតូចបានឃើញក្រដាសប្រាក់របស់ខ្មែរក្រហម ប៉ុន្តែបន្ទាប់ពីមានគោលការណ៍បិទមិនឲ្យមានការចាយក្រដាសប្រាក់ គ្មានប្រជាជនណាម្នាក់បានឃើញក្រដាសប្រាក់របស់របបនេះទៀតឡើយ ។

នៅឆ្នាំ១៩៩៣ ខ្មែរក្រហមបានបោះពុម្ពក្រដាសប្រាក់សាជាថ្មីម្តងទៀត ហើយដាក់ឲ្យចរាចរណ៍នៅក្នុងតំបន់ដែលខ្លួនកាន់កាប់ គឺប៉ៃលិននិងអន្លង់វែង ។ ក្រដាសប្រាក់ទាំងនេះមានរូបអង្គរវត្តព្រមជាមួយរូបផ្ទះនៅតាមដងទន្លេសាបនិងរូបថតពណ៌នាអំពីពិធីបុណ្យចូលឆ្នាំខ្មែរដែលប្រារព្ធនៅក្នុងព្រៃប៉ៃលិន ។ ក្រដាសប្រាក់ទាំងនេះមានសញ្ញាសំគាល់ជារូបិយប័ណ្ណដូរការ

ក្រដាសប្រាក់របបកម្ពុជាប្រជាធិបតេយ្យ (ផ្នែកមុខ)



ដោយមានហត្ថលេខារបស់ ខៀវ សំផន នៅខាងក្រោមនៃជ្រុងខាងឆ្វេង ។ ដោយគ្មានការលូកដៃពីសំណាក់រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា ធ្វើឲ្យក្រដាសប្រាក់របស់ខ្មែរក្រហមមានតម្លៃអាចប្រើការដោះដូរជាមួយប្រាក់បាតថៃក្នុងអត្រាប្តូរប្រាក់ ១ រៀលស្មើនឹង ១ បាតថៃ ។ ទោះបីក្នុងខណៈពេលមានការធ្លាក់ចុះនៃអត្រាប្រាក់រៀលផ្លូវការរបស់ខ្មែរក៏ដោយ ក៏ក្រដាសប្រាក់របស់ខ្មែរក្រហមនៅតែរក្សាតម្លៃថេរដដែល ។

ការបោះពុម្ពក្រដាសប្រាក់របស់ខ្មែរក្រហមជាមូលហេតុនាំដល់ការធ្លាក់ចុះនៃអត្រាប្រាក់រៀលរបស់កម្ពុជានៅខែមីនា ឆ្នាំ ១៩៩៣ ។ មានការសន្និដ្ឋានថា ខ្មែរក្រហមបានទិញប្រាក់រៀលផ្លូវការក្នុងបរិមាណច្រើនរួចយកមកចាក់ចូលក្នុងផ្សារ នៅទីក្រុងភ្នំពេញ ។ នៅខែសីហា ជាពេលដែលរដ្ឋាភិបាលបានវាយសន្ទាប់ខ្លាំងក្លាទៅលើមូលដ្ឋានចុងក្រោយរបស់ខ្មែរក្រហម បណ្តាមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់បានបញ្ជាឲ្យដុតក្រដាសប្រាក់របស់ខ្លួន ដើម្បីការពារកុំឲ្យក្រដាសប្រាក់ទាំងនោះធ្លាក់ចូលទៅក្នុងដៃរបស់ទាហានរដ្ឋាភិបាលកម្ពុជា ។ នៅពេលដែលទីក្រុងប៉ៃលិនត្រូវកងកម្លាំងរដ្ឋាភិបាលវាយយកបាននៅដើមឆ្នាំ១៩៩៤ រូបិយប័ណ្ណរបស់ខ្មែរក្រហមលែងមានដំណើរការទាំងស្រុងរួចទៅហើយ ។

គោលនយោបាយរបស់ខ្មែរក្រហមដែលមិនចាយក្រដាសប្រាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាយុទ្ធសាស្ត្រមួយដែលពួកខ្មែរក្រហមប្រើប្រាស់ក្នុងគោលបំណងបំបាត់កម្មសិទ្ធិនិងជម្លោះក្នុងការបែងចែកផលប្រយោជន៍ពុំស្មើគ្នា ដោយខ្លាចក្រែងលុយជាបញ្ហាមួយធ្វើឲ្យមានការវិលទៅរកសង្គមបែបមូលធននិយមនិងសេរីនិយម ។ ប៉ុន្តែខ្មែរក្រហមបានអនុវត្តជ្រុលហួសពីប្រទេសនានាដែលកាន់លទ្ធិសង្គមនិយម ព្រោះលទ្ធិសង្គមនិយមប្រកាន់យកត្រឹមតែ“សេដ្ឋកិច្ចផែនការ” ហើយពុំមានចំណុចណាមួយដែលបាននិយាយថាធ្វើសង្គមនិយមត្រូវបញ្ឈប់ការចាយវាយក្រដាសប្រាក់នោះទេ ។

ក្រដាសប្រាក់របស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ មានចំនួន៧ បែបគឺ ក្រដាស១កាក់ ក្រដាស៥កាក់ ក្រដាស១រៀល ក្រដាស ៥រៀល ក្រដាស១០រៀល ក្រដាស៥០រៀល និងក្រដាស

១០០រៀល ។ ក្រដាសប្រាក់ទាំងអស់សុទ្ធតែមានចារិកជាអក្សរខ្មែរនៅផ្នែកខាងលើថា "ធនាគារកម្ពុជា" ព្រមទាំងមានចុះអក្សរពីរតួសម្រាប់ចំណាំសំណុំក្រដាសប្រាក់ លេខរៀងក្រដាសប្រាក់ក្នុងសំណុំនីមួយៗ និងមានចុះឆ្នាំបោះពុម្ព ។

### ១) ក្រដាស១កាក់

បណ្តោយ ១០០,៥ម.ម ទទឹង ៥០,៥ម.ម ពណ៌ស្វាយថ្លាមានផ្ទៃពណ៌លឿងព្រឿងនៅកណ្តាល ខាងមុខមានរូបកងកាំភ្លើងធំ របស់កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា កំពុងតម្រង់កាំភ្លើង១២០ម.មទៅលើទីតាំងមួយនៅភ្នំពេញ ។ រីឯនៅខាងស្តាំរូបនេះមានចុះតម្លៃក្រដាសប្រាក់ជាអក្សរជាតិដាក់ថា "មួយកាក់" នៅជ្រុងខាងលើទាំងពីរមានចុះលេខ"០,១" ជាលេខជាតិ និងនៅខាងក្រោមពាក្យនេះមានចុះលេខសំគាល់ឆ្នាំបោះពុម្ព "១៩៧៥" ។ ខាងខ្នងមានរូបនារីកសិករមួយក្រុមកំពុងរោយស្រូវនិងអុំស្រូវ នៅខាងក្រោមទាំងពីរជ្រុងមានចុះលេខ "០.១" ជាលេខសកល ។

### ២) ក្រដាសប្រាក់៥កាក់

បណ្តោយ ១១០ម.ម ទទឹង ៥០,៥ម.ម រូបពណ៌ក្រហមនៅលើផ្ទៃពណ៌ត្រួយចេក នៅខាងមុខមានរូបកងទ័ពនារីមួយកងរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាកំពុងយាត្រាទ័ពទៅសមរភូមិ ។ នៅខាងស្តាំរូបនេះមានចុះតម្លៃក្រដាសប្រាក់ជាអក្សរជាតិថា "ប្រាំកាក់" ។ នៅជ្រុងខាងលើខាងឆ្វេងនឹងនៅជ្រុងខាងក្រោមខាងស្តាំមានចុះលេខ "០,៥" ជាលេខជាតិ ។ ខាងខ្នង មានរូបកម្មករកំពុងបញ្ជាម៉ាស៊ីនក្រឡឹងនៅខាងឆ្វេងរូបនេះ មានរូបព្រហ្មមុខបួននៃកំពូលប្រាសាទបាយ័ន ។ នៅជ្រុងខាងក្រោម ទាំងពីរជ្រុងមានចុះលេខ "០.៥" ជាលេខសកល និងមានលេខ ១៩៧៥ នៅចំកណ្តាលជ្រុងខាងក្រោម ។

### ៣) ក្រដាសប្រាក់១រៀល

បណ្តោយ ១២០ម.ម ទទឹង ៥៧,៥ម.ម ស៊ុមនិងរូបពណ៌ក្រហម ខាងមុខមានរូបកសិករមួយក្រុមកំពុងជីកប្រឡាយ នៅខាងស្តាំរូបនេះមានចុះតម្លៃក្រដាសប្រាក់ជាអក្សរជាតិថា "មួយរៀល" និងមានលេខ ១៩៧៥នៅខាងក្រោម ។ នៅលើជ្រុង

**ក្រដាសប្រាក់របបកម្ពុជាប្រជាធិបតេយ្យ (ផ្នែកក្រោយ)**



ស៊ុមទាំង៤មានចុះលេខ ១ ជាលេខជាតិ ។ រីឯនៅខាងខ្នងមានរូបនារីកម្មករម្នាក់កំពុងបញ្ជាម៉ាស៊ីនក្រឡឹង ។ នៅជ្រុងស៊ុមខាងក្រោមមានចុះលេខ ១ ជាលេខសកល ។

**៤) ក្រដាសប្រាក់៥រៀល**

បណ្តោយ ១២០ម.ម ទទឹង ៥៨ម.ម ស៊ុមពណ៌បៃតងចាស់ រូបពណ៌បៃតងចាស់លើផ្ទៃពណ៌ពងក្រសា ។ នៅខាងក្រោយរូបប្រាសាទអង្គរមានផ្ទៃពណ៌លឿងព្រឿងៗ ។ ខាងមុខមានរូបប្រាសាទអង្គរវត្ត នៅខាងឆ្វេងរូបប្រាសាទអង្គរវត្តនេះមានចុះតម្លៃក្រដាសប្រាក់ជាអក្សរជាតិថា "ប្រាំរៀល" ។ នៅគ្រប់ជ្រុងទាំងបួនមានចុះលេខ ៥ ជាលេខជាតិ ។ រីឯនៅខាងខ្នងមានរូបប្រជាជនកំពុងលើកទំនប់ នៅលើស៊ុមខាងលើមានចុះលេខ ៥ ជាលេខជាតិនិងនៅស៊ុមខាងក្រោមមានចុះលេខ៥ និងមានលេខ ១៩៧៥ នៅកណ្តាលជាលេខសកល ។


ធនាគារជាតិកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

**៥) ក្រដាសប្រាក់១០រៀល**

បណ្តោយ ១៣៨ម.ម ទទឹង ៥៨,៥ម.ម ស៊ុមពណ៌ឈាមជ្រូក ។ រូបពណ៌ឈាមជ្រូកលើផ្ទៃពណ៌ពងក្រសា មានពណ៌លឿងព្រឿងៗនៅចំកណ្តាលក្រដាសប្រាក់ ។ នៅខាងមុខមានរូបយុវជននៃកងកម្លាំងប្រដាប់អាវុធកំពុងតម្រង់កាំភ្លើងយន្ត នៅខាងស្តាំដៃមានចុះតម្លៃ "ដប់រៀល" សរសេរជាអក្សរជាតិ នៅខាងជ្រុងទាំងបួនមានចុះលេខ ១០ ជាលេខជាតិដែរ ។ រីឯខាងខ្នងមានរូបយុទ្ធជននៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា កំពុងជួយច្រូតស្រូវប្រជាជន ។ នៅជ្រុងស៊ុមទាំងពីរខាងលើមានចុះលេខ ១០ ជាលេខជាតិ នៅជ្រុងស៊ុមទាំងពីរខាងក្រោមមានចុះលេខ ១០ ជាលេខសកល ។

**៦) ក្រដាស៥០រៀល**

បណ្តោយ ១៤១ម.ម ទទឹង ៧២ម.ម ស៊ុមពណ៌ស្វាយក្រមៅ ។ រូបពណ៌ស្វាយក្រមៅលើផ្ទៃពណ៌ផ្កាឈូកព្រឿងៗនៅកណ្តាលក្រដាស ផ្ទៃពណ៌ផ្កាឈូកព្រឿងនៅខាងឆ្វេងផ្ទៃពណ៌ពងក្រសានៅខាងស្តាំ ។ នៅខាងមុខមានរូបកសិករនៃក្រុមសាមគ្គីកំពុងបង្កបង្កើនផលមួយក្រុមកំពុងភ្ជួរស្រែនិងស្ទូងស្រូវ ។ នៅខាងស្តាំមានរូបមុខព្រហ្មទាំង៤នៃកំពូលប្រាសាទបាយ័នមានចុះតម្លៃ "ហាសិបរៀល" ជាអក្សរជាតិនិងមានលេខ ១៩៧៥ នៅខាងក្រោម ។ ជ្រុងស៊ុមទាំងពីរខាងលើមានលេខ ៥០ និងនៅខាងក្រោមចំកណ្តាលស៊ុមមានលេខ៥០ ជាលេខជាតិ ។ នៅខាងខ្នង មានកងទ័ពនារីមួយក្រុមកំពុងប្រយុទ្ធនៅលើសមរភូមិ ។ នៅជ្រុងស៊ុមទាំងពីរខាងលើមានចុះលេខ៥០ ជាលេខជាតិ នៅផ្នែកខាងក្រោមទាំងពីរមានចុះលេខ៥០ ជាលេខសកល ។

**៧) ក្រដាសប្រាក់១០០រៀល**

ទំហំបណ្តោយ ១៨០ម.ម ទទឹង៧៣ម.ម ខាងមុខស៊ុមពណ៌បៃតងចាស់ រូបពណ៌បៃតងចាស់មានផ្ទៃលឿងនៅកណ្តាល និងផ្ទៃពណ៌ផ្កាឈូកនៅសងខាង ។ ខាងក្រោយមានស៊ុមនិងរូបពណ៌ប្រផេះ ។ ខាងមុខមានរូបកម្មករកំពុងធ្វើការនៅក្នុងរោងជាង ។ នៅខាងស្តាំមានចុះតម្លៃ "មួយរយរៀល" ជាអក្សរជាតិ ។ នៅជ្រុងស៊ុមទាំងបួនមានចុះលេខ ១០០ ជាលេខជាតិ និងចុះលេខឆ្នាំនៅកណ្តាលជ្រុងខាងក្រោម១៩៧៥ ។ ផ្នែកខាងខ្នងមានរូបកសិករកំពុងច្រូតកាត់ផលដំណាំស្រូវ ។ នៅជ្រុងស៊ុមទាំងពីរខាងលើមានចុះលេខ១០០ ជាលេខជាតិ និងនៅជ្រុងស៊ុមទាំងពីរខាងក្រោមមានចុះលេខ១០០ ជាលេខសកល ។ **ហ៊ុយ សោភ័ណ**



រូបថតបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ចូសេហ្វ កូហ្វម៉ាន់



# ខៀវ សំផន
# គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ

# អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម

អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅ អមនុស្សធម៌ ឬដែលធ្វើបាត់បង់តម្លៃជាមនុស្ស(១៩៨៤)មានការចុះហត្ថលេខាដោយរដ្ឋចំនួន៨៩និងឲ្យសច្ចាប័នដោយរដ្ឋចំនួន១៥កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៦ ។ អនុសញ្ញានេះបានចែងនូវវិធានការដ៏មានប្រសិទ្ធភាពជាងមុនក្នុងការទប់ស្កាត់ការធ្វើទារុណកម្មនិងការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។ មាត្រា១បានចែងនិយមន័យស្រដៀងគ្នាទៅនឹងនិយមន័យដែលកំណត់ដោយសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ក៏ប៉ុន្តែមានចំណុចខុសគ្នាសំខាន់ៗមួយចំនួនៈ ទី១ មូលហេតុដែលនាំឲ្យមានការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ ឬដែលអាចក្លាយទៅជាអំពើទារុណកម្ម អាចរាប់បញ្ចូលនូវ «មូលហេតុនៃការរើសអើងសព្វបែបយ៉ាង» ។ ទី២ ជនដែលរួមមានជនទាំងឡាយណាដែលប្រព្រឹត្តបទឧក្រិដ្ឋក្រោម«ការយល់ព្រមឬដឹងឮពីមន្ត្រីសាធារណៈ» មិនត្រឹមតែអ្នកប្រព្រឹត្តនៅក្រោម«ការញុះញង់របស់មន្ត្រីម្នាក់ប៉ុណ្ណោះទេ» ។ រដ្ឋនៅតែមានសិទ្ធិសេរីភាពក្នុងការផ្តល់ទស្សនៈរថាបទឧក្រិដ្ឋមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ទៅលើបុគ្គលម្នាក់ទៀតដោយមួយពុំមានការយល់ព្រមពីខ្លួនឡើយ ។

ផ្ទុយទៅវិញ ដោយហេតុថាសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សបានចែងថា និយមន័យការធ្វើទារុណកម្មមិនរួមបញ្ចូលនូវការឈឺចាប់ឬការរងរបួសស្នាមដែលកើតឡើងជាប់ជាមួយឬជាឧបទ្ទវហេតុដែលបណ្តាលមកពីការដាក់ទណ្ឌកម្មខាងផ្លូវច្បាប់ឲ្យស្របទៅតាមកម្រិតបទដ្ឋានដាច់ខាតចំពោះការប្រព្រឹត្តទៅលើអ្នកទោសនោះ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានលុបបំបាត់ចោលកម្រិតបទដ្ឋាននៃការប្រព្រឹត្តលើអ្នកទោសដែលធ្វើឲ្យករណីនៃការលើកលែងនៃ «ការដាក់ទណ្ឌកម្មខាងផ្លូវច្បាប់» រឹតតែគ្មានការដាក់កម្រិតឲ្យបានត្រឹមត្រូវទៅវិញ ។ ហេតុដូចនេះការប៉ាន់ស្មានចំពោះការដាក់ទណ្ឌកម្មលើរូបរាងកាយមិនត្រូវបានហាមប្រាមយ៉ាងតឹងរ៉ឹងដោយអនុសញ្ញានេះឡើយ ប្រសិនបើការដាក់ទណ្ឌកម្មទាំងនេះស្របទៅនឹងច្បាប់នៅក្នុងស្រុក ។

កាន់តែឃ្លាតឆ្ងាយពីមាត្រា១នៃសេចក្តីប្រកាសនេះ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មពុំបាននិយាយអ្វីអំពីការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស នៅក្នុងសារាចរឬការហាមប្រាមនានាឡើយ ។ នេះគឺដោយសារអ្នកព្រាងអនុសញ្ញាទាំងនោះមានការទើសទាល់អំពីការភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ដាក់លាក់មួយចំនួនទៅនឹងការហាមប្រាមមួយចំនួនប្រឆាំងនឹងការប្រព្រឹត្តដែលមានការលំបាកនឹងកំណត់និយមន័យ ។ ការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោឃៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស មិនទាន់មានឈ្មោះទេរហូតដល់មានការបង្កើតនូវមាត្រា១៦ដែលចែងទាំងស្រុងថា «នៅក្នុងវង្វង់នៃដែនសមត្ថកិច្ចរបស់ភាគីខ្លួន រដ្ឋនីមួយៗត្រូវមានភារកិច្ចទប់ស្កាត់រាល់ការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោឃៅអមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្សឬទណ្ឌកម្មទោះបីជាពុំទាន់មានសណ្ឋានជាការធ្វើទារុណកម្មដូចដែលបានកំណត់ក្នុងមាត្រា១ ក៏ដោយ នៅពេលដែលការប្រព្រឹត្តនោះត្រូវបានកើតឡើងក្រោមការញុះញង់ ឬដោយមានការយល់ព្រមឬការដឹងឮដោយមន្ត្រីសាធារណៈ ឬអ្នកដែលនៅក្នុងសមត្ថកិច្ចជាផ្លូវការ(នៃរដ្ឋាភិបាល) ។ ជាពិសេសកាតព្វកិច្ចទាំងឡាយដែលមានក្នុងមាត្រា១០, ១១, ១២ និង១៣ ត្រូវតែអនុវត្តចំពោះការធ្វើទារុណកម្មដែលសំដៅលើគ្រប់ទ្រង់ទ្រាយទាំងអស់នៃការដាក់ទណ្ឌកម្មឬការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។ «១» ទាំងឡាយនៃអនុសញ្ញានេះគឺពុំមានការរើសអើងប្រកាន់ចំពោះ «១» ដទៃទៀតនៃលិខិតូបករណ៍ច្បាប់អន្តរជាតិឬច្បាប់ដទៃទៀត

ដែលហាមប្រាមការប្រព្រឹត្តមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។ ច្បាប់ដែលទាក់ទងទៅនឹងការធ្វើបត្យាប័ន (ការចាប់បញ្ជូនជនជាប់ចោទមកប្រទេសដែលជននោះបានប្រព្រឹត្តបទឧក្រិដ្ឋ) ឬ«ការនិរទេស» ។

កាតព្វកិច្ចទាំងនោះសំដៅរួមបញ្ចូលនូវការផ្តល់នូវគោលការណ៍ណែនាំដល់បគ្គលិកដែលអាចជាប់ពាក់ព័ន្ធក្នុងការចាប់ដាក់គុក ការសួរចម្លើយឬការប្រព្រឹត្តយោរយៅលើអ្នកទោស (មាត្រា១០) ។ ពិនិត្យលើវិធានការ វិធីសាស្ត្រ និងការអនុវត្តនៃច្បាប់នានា (មាត្រា១១) ។ ការតាមដានស៊ើបអង្កេតអំពីការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស អាចកើតមានឡើង (មាត្រា១២) ។ ការធានានូវសិទ្ធិចំពោះបុគ្គលក្នុងការប្តឹងប្តល់អំពីការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស (មាត្រា១៣) ។ ដូច្នេះឃើញថា ការប្រឆាំងនឹងការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅ អមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស គឺមានលក្ខណៈខ្សោយជាងការការពារដែលប្រឆាំងនឹងការធ្វើទារុណកម្មជាច្រើន ។ ជាពិសេសអនុសញ្ញានេះពុំធានាការសងជំងឺចិត្តដល់ជនរងគ្រោះដោយអំពើប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ហើយក៏ទទួលយកភ័ស្តុតាងដែលទទួលបានដោយមធ្យោបាយទាំងនេះដែរ ហើយការហាមប្រាមមិនឲ្យមានអំពើប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស មិនអាចទទួលបាននូវការការពារប្រឆាំងនឹងការអនុញ្ញាឲ្យរួចទោសចំពោះស្ថានភាពនានាដូចជាសង្គ្រាមឬអស្ថេរភាពនយោបាយ ។ ជាងនេះទៅទៀត កាតព្វកិច្ចរបស់រដ្ឋទាំងឡាយក្នុងការនាំជនដៃដល់មកកាត់ទោសត្រូវបានទុកចំហចោល ។ ដោយសារមាត្រា២ដល់មាត្រា៩ អនុវត្តតែចំពោះការធ្វើទារុណកម្មនោះ បុគ្គលទាំងឡាយនោះពុំទទួលបាននូវការការពារពីការធ្វើបត្យាប័ន (ការចាប់បញ្ជូន) ទៅប្រទេសដែលពួកគេអាចប្រឈមមុខនឹងគ្រោះថ្នាក់នៃការទទួលខុសត្រូវចំពោះបទល្មើសនៃការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស (មាត្រា៣) ។ ភាគីរដ្ឋទាំងឡាយពុំតម្រូវឲ្យធានាឲ្យប្រាកដថា អំពើនៃការប្រព្រឹត្តផ្សេងៗដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស គឺជាបទល្មើសក្រោមច្បាប់របស់ខ្លួនឡើយ (មាត្រា៤) ។ ពុំតម្រូវឲ្យមានវិធានការច្បាស់លាស់ក្នុងការចាប់ខ្លួននិងការធ្វើបត្យាប័នឬការធ្វើទុក្ខបុកម្នេញចំពោះជនដែលគ្រាន់តែត្រូវបានសង្ស័យពីបទប្រព្រឹត្តអំពើទារុណកម្មនៅក្នុងករណីនៃការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវយោរយៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស (មាត្រា៦និង៧) ហើយរដ្ឋទាំងឡាយពុំចាំបាច់ត្រូវមានកាតព្វកិច្ចជួយគ្នាទៅវិញទៅមកក្នុងដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌប្រឆាំងនឹងជនសង្ស័យឡើយ (មាត្រា៧) ។

ផ្នែកទី២នៃអនុសញ្ញានេះនិយាយអំពីការអនុវត្តគណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ដែលមានសមាជិកជា«អ្នកជំនាញច្បាប់»ចំនួន១០នាក់ត្រូវបានបង្កើតឡើងដើម្បីទទួលយករបាយការណ៍ពីរដ្ឋជាសមាជិកទាំងឡាយអំពីវិធានការនានាដែលបណ្តារដ្ឋជាសមាជិកទាំងនោះបានចាត់ឡើងដើម្បីអនុវត្តឲ្យបាននូវការប្តេជ្ញាចិត្តរបស់ខ្លួនក្រោមអនុសញ្ញានេះ និងដើម្បីតាមដានស៊ើបអង្កេតរបាយការណ៍នៃប្រតិបត្តិការធ្វើទារុណកម្មក្នុងលក្ខណៈជាប្រព័ន្ធ ។ មិនតែប៉ុណ្ណោះ គណៈកម្មការនេះដោះស្រាយការចោទប្រកាន់នានាដែលថាភាគីរដ្ឋមួយកំពុងតែមិនអនុវត្តទៅតាម «ខ» ទាំងឡាយនៃអនុសញ្ញានេះ ។ តាមការសន្និដ្ឋាននេះមានន័យថា រដ្ឋមួយអាចត្រូវបានចោទប្រកាន់នៅចំពោះមុខគណៈកម្មការនេះ ឧទាហរណ៍ពីបទខកខានមិនបានធ្វើការស៊ើបអង្កេតបទល្មើសផ្សេងៗដែលមានលក្ខណៈសាហាវយោរយៅ អមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្ស ដែលអាចកើតមានឡើង ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ភាគីរដ្ឋមួយជាសមាជិកនៃអនុសញ្ញានេះត្រូវតែប្រកាសថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មការនេះថា ច្បាប់មួយដាច់ដោយឡែកក្រោមមាត្រា២២ មុននឹងអ្នកជំនាញច្បាប់ដែលជាសមាជិកនៃអនុសញ្ញានេះ

ពិចារណាពីទំនាក់ទំនងរបស់ខ្លួនជាមួយភាគីនោះ មានន័យថា ភាគីទាំងឡាយអាចសម្រេចមិនចូលរួមជាមួយគណៈកម្មការនេះបាន ។ ហេតុដូច្នេះហើយ វាជាការសំខាន់ណាស់ដែលផ្នែកទី២នៃមាត្រា១៦ (ស្តីពី«ការហាមឃាត់»ការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្ស) ចែងថា «ខ» ទាំងឡាយនៃច្បាប់នេះពុំមានការរើសអើងប្រឆាំងនឹងលិខិតូបករណ៍ច្បាប់ដែលមានស្រាប់ដទៃទៀត ឬច្បាប់ក្នុងស្រុកដែលហាមប្រាមការដាក់ទណ្ឌកម្ម ការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្ស ។ «ខ»បន្ថែមទាំងនេះអាចជា«សំណាញ់ដ៏មានប្រសិទ្ធិភាព»ការពារដល់ជនរងគ្រោះនៃការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ឬដែលបាត់បង់តម្លៃជាមនុស្ស បានមួយកម្រិតធំ ។

ជាពិសេស ភាគ៤នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចូលជាធរមាននៅឆ្នាំ១៩៦៦ ដែលហាមប្រាមការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្ស មាត្រា៧បានបង្កើតនូវគណៈកម្មការសិទ្ធិមនុស្សដើម្បីពិចារណាលើការចោទប្រកាន់ដែលថា ភាគីរដ្ឋមួយកំពុងតែរំលោភបំពានដោយមិនអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ។ រដ្ឋដទៃទៀតអាចប្តឹងរដ្ឋមួយបាន ហើយគណៈកម្មការនេះមាននាទីចេញជារបាយការណ៍មួយអំពីលទ្ធផលស៊ើបអង្កេតរបស់ខ្លួនតាមរយៈពេលកំណត់ណាមួយ ។ គណៈកម្មការប្រឆាំងនឹងការធ្វើទារុណ-កម្មមានសិទ្ធិតែទៅលើភាគីនៃរដ្ឋទាំងឡាយណាដែលទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មការនេះតាមរយៈការប្រកាសដាច់ដោយឡែកមួយប៉ុណ្ណោះ ។

មិនតែប៉ុណ្ណោះ ការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្សត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយបាន«ប្រសិនបើអំពើទាំងនោះត្រូវបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំក្នុងលក្ខណៈជាប្រព័ន្ធ ដោយសារមូលហេតុនយោបាយពូជសាសន៍ ឬសាសនា» ។ ប្រសិនបើការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅអមនុស្សធម៌ ឬដែលបាត់បង់តម្លៃជាមនុស្ស ត្រូវបានប្រព្រឹត្តដោយចេតនាក្នុងលក្ខណៈធ្ងន់ធ្ងរដែលនាំឲ្យខូចខាតទាំងស្រុង ឬដោយផ្អែកដល់ក្រុមជាតិសាសន៍ ឬសាសនា ក៏អាចក្លាយទៅជាអំពើប្រល័យពូជសាសន៍បានដែរ ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**


វិចិត្រករៈ វ៉ាន់ ណាត អតីតអ្នកទោសនៅមន្ទីរ ស-២១

## ពាក្យស្លោកខ្មែរក្រហម

◆ ពង្រឹងបន្ថែមស្នេហាជាតិ និយមបដិវត្តន៍ និងមោទនភាពបដិវត្តន៍ចំពោះជាតិខ្លួន ប្រជាជន កងទ័ព បដិវត្តន៍ និងបក្សខ្លួន ដូចដែកថែបជាប់ជានិច្ច។

◆ បង្កើនកម្លាំងចិត្ត កម្លាំងកាយ កម្លាំងប្រាជ្ញាទាំងអស់របស់បុគ្គល របស់អង្គភាព របស់ប្រជាជាតិទាំងមូលសាមគ្គីជាធ្លុងមួយ តស៊ូកម្ចាត់ខ្មាំងគ្រប់ប្រភេទ ពិសេសខ្មាំងយួនឈ្លានពានទឹកដី រក្សាការពារជាតិនិងពូជសាសន៍កម្ពុជាឱ្យគង់វង្សទាំងស្រុងជារៀងរហូត។ *(សៀវភៅលេខ ០៧៦ គណប)*

# តុលាការនៅទីម័រខាងកើតៈ ក្រុមប្រឹក្សាអ្នកច្បាប់ពិសេសខាងព្រហ្មទណ្ឌកម្រិតធ្ងន់

***(តពីលេខមុន)***

IV. ***គម្រោងសិក្សាបទល្មើសកម្រិតធ្ងន់នៅទីម័រខាងកើត នៅតុលាការស្រុកឌីលី***

***ក) ទិដ្ឋភាពរួម***

*គម្រោងសិក្សាបទល្មើសកម្រិតធ្ងន់របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ត្រូវបានបង្កើតឡើងតាមរយៈច្បាប់លេខ ២០០០/១១ ស្តីពីការរៀបចំតុលាការនៅទីម័រខាងកើតនិងច្បាប់លេខ ២០០០/១៥ ស្តីពីការបង្កើតក្រុមការងារមួយដែលមានសមត្ថកិច្ចពេញលេញទៅលើបទព្រហ្មទណ្ឌកម្រិតធ្ងន់ ។ ច្បាប់លេខ ២០០០/១៥ នេះផ្អែកស្ទើរតែទាំងស្រុងទៅលើច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមឆ្នាំ ១៩៩៨ ដើម្បីបង្កើតតុលាការអន្តរជាតិ ហើយជាឯកសារសម្រាប់យោងក្នុងកិច្ចការងារនេះដែរ ។ ប្រសិនបើគ្មានការបញ្ចេញបញ្ចូលនៅក្នុងសមិទ្ធផលនៃច្បាប់តុលាការអន្តរជាតិនោះទេ «វា» ដែលមានចែងក្នុងច្បាប់នឹងត្រូវបានទទួលស្គាល់ថាជាលទ្ធផលដែលកើតចេញពីការសម្របសម្រួលការទូត ហើយមិនឆ្លុះបញ្ចាំងពីច្បាប់ទម្លាប់អន្តរជាតិគ្រប់ពេលទេ ។ សូមបញ្ជាក់ថា ច្បាប់អនុម័តនៅទីក្រុងរ៉ូមនេះបង្កើតឡើងសម្រាប់តែកាលៈទេសៈពិសេសៗរបស់តុលាការអន្តរជាតិ ហើយមានការផ្តោតសំខាន់ដែលអាចប្រមើលឃើញនៅថ្ងៃមុខ (ទៅលើបទល្មើសដែលប្រព្រឹត្តឡើងក្រោយពេលច្បាប់នេះចូលជាធរមាន) ។ ដូចនេះ «វា» ដែលមានចែងនៅក្នុងច្បាប់អនុម័តនៅទីក្រុងរ៉ូមមិនគួរចាត់ទុកជាស្វ័យប្រវត្តិថាមានភាពសមស្របសម្រាប់យកមកប្រើប្រាស់ដើម្បីកាត់សេចក្តីចំពោះអំពើឃោរឃៅជាលក្ខណៈប្រវត្តិសាស្ត្រដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលសំខាន់មួយពេលដូចជារយៈពេល២៤ឆ្នាំនៃការកាន់កាប់ទឹកដីទីម័រខាងកើតជាដើម ។ មានបញ្ហាធំៗជាច្រើនដែលកើតចេញពីច្បាប់លេខ ២០០០/១៥ ដោយសារច្បាប់នេះផ្អែកខ្លាំងពេកទៅលើច្បាប់បង្កើតតុលាការអន្តរជាតិដែលអនុម័តនៅទីក្រុងរ៉ូម ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ជាការសំខាន់ដែរក្នុងការបញ្ជាក់ច្បាស់ថា ដោយសារមកដល់ពេលនេះទើបតែមានគម្រោងសិក្សាបទល្មើសកម្រិតធ្ងន់ដើម្បីកាត់សេចក្តីទៅលើអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅឆ្នាំ១៩៩៩ បញ្ហាទាំងនេះភាគច្រើនដែលទាក់ទងនឹងការកាត់សេចក្តីអំពើឃោរឃៅជាលក្ខណៈប្រវត្តិសាស្ត្រនៅតែជាទ្រឹស្តីនៅឡើយ ។*

*ច្បាប់កម្ពុជាកំណត់ច្បាស់ទៅលើការកាត់ទោសមេដឹកនាំនិងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ហើយក្រុមដែលជាមុខសញ្ញាត្រូវបានកំណត់ច្បាស់លាស់ ។ រូបមន្តប្រហាក់ប្រហែលគ្នានេះត្រូវបានអនុវត្តរួចមកហើយដោយតុលាការពិសេសនៅប្រទេសសេរ៉ាឡេអូន ។ ក៏ប៉ុន្តែនៅទីម័រខាងកើត ក្រុមដែលជាមុខសញ្ញារបស់គម្រោងសិក្សាពីបទល្មើសកម្រិតធ្ងន់ធ្ងរនេះមិនទាន់កំណត់ច្បាស់នៅឡើយទេ ហើយក្រុមប្រឹក្សាតុលាការពិសេសក៏បានចាប់ផ្តើមសិក្សាករណីរបស់កងជីវពលថ្នាក់មូលដ្ឋានដែរ ។ គ្មានកងជីវពលណាម្នាក់មានតួនាទីសំខាន់នៅក្នុងខ្សែបញ្ជានិងគ្រប់គ្រងទេ ។ សូមបញ្ជាក់ថា ជាការច្បាស់ណាស់តាមសភាពជាក់ស្តែងឃើញថា ជនដែលត្រូវបានចាត់ទុកជាទូទៅថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត មេដឹកនាំនិងមេបញ្ជាការកងជីវពលនិងជនស៊ីវិលនៃកងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ី កំពុងរស់នៅប្រទេសឥណ្ឌូនេស៊ីនៅឡើយ ។ ប្រទេសនេះបានបដិសេធហើយបដិសេធទៀតមិនព្រមធ្វើបត្យាប័នឲ្យយកជនជាតិឥណ្ឌូនេស៊ីមកជម្រះទោសនៅលើទឹកដីទីម័រខាងកើតទេ ហើយខកខានមិនបានកាត់ទោសបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅទីនោះទៀតផង ។*

*នៅទីម័រខាងកើត មានការិយាល័យបង្កើតឡើងជាពិសេសមួយសម្រាប់ធ្វើការស៊ើបអង្កេតនិងកាត់សេចក្តីបទល្មើសកម្រិត*

ធ្ងន់ ។ ការិយាល័យនេះមានចៅក្រមស៊ើបអង្កេតនិងរដ្ឋអាជ្ញា (មានសមាសភាពជាអន្តរជាតិស្ទើរតែទាំងអស់) ដែលដំណើរការក្រោមការគ្រប់គ្រងរបស់អគ្គរដ្ឋអាជ្ញារងសម្រាប់បទល្មើសកម្រិតធ្ងន់ធ្ងរ ។ ការិយាល័យនេះអនុវត្តបណ្តឹងទៅលើបទល្មើសធ្ងន់ធ្ងរមុនពេលក្រុមចៅក្រមដែលតែងតាំងដោយអន្តរជាតិដែលមានឈ្មោះថាក្រុមប្រឹក្សាតុលាការពិសេស ដែលជាផ្នែកមួយនៃតុលាការស្រុកឌីលី ។ ក្រុមប្រឹក្សាតុលាការពិសេសនីមួយៗមានចៅក្រមជនជាតិទីម័រមួយរូបនិងចៅក្រមអន្តរជាតិពីររូប ។ សាលាឧទ្ធរណ៍ (ដែលតែងតាំងដោយអន្តរជាតិដែរ) បើកសវនាការវិនិច្ឆ័យរឿងក្តីទាំងឡាយមកពីតុលាការស្រុកទាំងបួនរបស់ទីម័រខាងកើត ។ អ្នកការពារចុងចោទសាធារណៈទាំងក្នុងស្រុកទាំងអន្តរជាតិឡើងការពារជនជាប់ចោទដែលមិនមានមធ្យោបាយជួលអ្នកតំណាងផ្នែកច្បាប់ ។ ថវិកាបានមកពីខ្ទង់ចំណាយថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ ដូច្នេះ ត្រង់ចំណុចនេះយើងឃើញច្បាស់ហើយថា ភាពខុសគ្នារវាងទីម័រខាងកើតនិងប្រទេសកម្ពុជាគឺថាគ្រប់ចំណុចទាំងអស់នៃគម្រោងសិក្សាបទល្មើសធ្ងន់ធ្ងរនៅប្រទេសទីម័រត្រូវបានគ្រប់គ្រងដោយអង្គការសហប្រជាជាតិមិនដូចជាអង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជាទេ ។

### ១) បទល្មើស

ទាំងក្រុមប្រឹក្សាតុលាការពិសេសនិងអង្គជំនុំជម្រះវិសាមញ្ញ សុទ្ធតែមានដែនសមត្ថកិច្ចតាមពេលវេលាទៅលើបទឧក្រិដ្ឋដែលកើតឡើងតាំងពីឆ្នាំ១៩៧៥ ។ ជាការសំខាន់ណាស់ក្នុងការប្រៀបធៀបសាច់រឿងទាក់ទងនឹងដែនសមត្ថកិច្ចនេះ ។

ផ្នែកទី៤នៃច្បាប់របស់ទីម័រខាងកើតលេខ ២០០០/១៥ យកនិយមន័យច្បាប់ទម្លាប់អន្តរជាតិនៃអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋនៃការប្រល័យពូជសាសន៍មកប្រើ ។ ចំណែកច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជាក៏យកអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋនៃការប្រល័យពូជសាសន៍មកប្រើដូចគ្នាដែរ ។ ទម្រង់សំខាន់នៃនិយមន័យនេះគឺថា បទព្រហ្មទណ្ឌដែលត្រូវបានរកឃើញថាមានមែន អាចចូលជាបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដរាបណាអំពើនេះសំដៅទៅលើក្រុមជនជាតិ ជាតិសាសន៍ ជាតិពន្ធុឬក្រុមសាសនា ក្នុងគោលបំណងកម្ទេចទាំងស្រុងឬដោយផ្នែកទៅលើក្រុមដែលរៀបរាប់មកនេះ ។ គួរកត់សម្គាល់ថា ក្រុមនយោបាយមិនមានបញ្ចូលនៅក្នុងក្រុមខាងលើនេះទេ ។ តាមពិត ក្រុមនយោបាយក៏ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែរ ។ ពួកអ្នកធ្វើសេចក្តីព្រាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មានចេតនាចង់ទទួលស្គាល់តែក្រុម“ថិរវន្ត” (ពោលគឺក្រុមដែលមានសារជាតិនិងសមាជិកភាពដើមជាអចិន្ត្រៃយ៍មិនផ្លាស់ប្តូរ ដែលកើតមកយ៉ាងម៉េចនៅរក្សាដូចដើម) ថាជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ អ្នកធ្វើសេចក្តីព្រាងអនុសញ្ញាមានចេតនាមិនរាប់បញ្ចូលក្រុមដែលមិនឋិតថេរ ដែលបង្កើតឡើងទៅតាមសមាជិកភាពស្ម័គ្រចិត្ត ឬសមាជិកភាពដែលគ្រាន់តែជាការសន្មតមានដូចជាក្រុមនយោបាយនិងក្រុមសេដ្ឋកិច្ច ។ ប្រសិនបើដូច្នោះមែន ហេតុផលទាំងអស់នេះមិនបានបញ្ឈប់ពីការរួមបញ្ចូលក្រុមសាសនាដែលមានចរិតមិនឋិតថេរ បង្កើតឡើងតាមការស្ម័គ្រចិត្តនិងតាមអត្តសញ្ញាណបុគ្គលដែលជឿជំនឿរៀងខ្លួនផងទេ ។ កំណើតអាចដើរតួនាទីនៅក្នុងអត្តសញ្ញាណសាសនា ប៉ុន្តែវាមិនមែនជាកត្តាកំណត់ដាច់ខាតទេ ។

និយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រកាន់យកដោយទីម័រខាងកើត ដូចគ្នាទៅនឹងច្បាប់អនុម័តនៅទីក្រុងរ៉ូមដែលមានចែងយ៉ាងច្បាស់ល្អិតល្អន់ថា ទាំងអំពើដែលត្រូវផ្តន្ទាទោស ទាំងការវាយប្រហារក្នុងទ្រង់ទ្រាយធំឬជាប្រព័ន្ធត្រូវតែធ្វើឡើងចំពោះជនស៊ីវិល ។ នេះជាចំណុចខុសប្លែកពី “១” ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញរបស់កម្ពុជាដែលដកស្រង់មកពីច្បាប់បង្កើតតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ ច្បាប់បង្កើតតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាតម្រូវថា គ្រប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែបានប្រព្រឹត្តដោយមានចេតនារើសអើង (អំពើត្រូវតែជាការវាយប្រហារដែលធ្វើឡើងក្នុងទ្រង់ទ្រាយធំឬជាប្រព័ន្ធមកលើជនស៊ីវិល ក្រុមជនជាតិ ក្រុមនយោបាយ ក្រុមជាតិពន្ធុ ក្រុមជាតិសាសន៍ ឬដោយហេតុផលសាសនា) ។ គួរកត់សម្គាល់ដែរថា គ្មាននិយមន័យណាមួយក្នុងនិយមន័យដែលលើកឡើងខាងដើមតម្រូវថាត្រូវតែមានសម្ព័ន្ធជម្លោះប្រដាប់

អាវុធទេ ។ នេះមានន័យថា ខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលមាន“សន្តិភាព”និងពេលមានជម្លោះប្រដាប់អាវុធ ។

រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត បានប្រកាន់យកនិយមន័យខក្រិដ្ឋកម្មសង្គ្រាមដែលចម្លងតាមទាំងដុលពីមាត្រាទី៨(២) នៃច្បាប់តុលាការអន្តរជាតិនិងអនុញ្ញាតឲ្យមានការកាត់សេចក្តីទៅលើខក្រិដ្ឋកម្មសង្គ្រាមបួនប្រភេទ ÷

◆ ការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលអាចអនុវត្តបាននៅពេលមានជម្លោះប្រដាប់អាវុធ ។

◆ ការរំលោភផ្សេងទៀតទៅលើច្បាប់ និងទំនៀមទម្លាប់ដែលអាចអនុវត្តបានពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។

◆ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើមាត្រាទី៣នៃអនុសញ្ញាទីក្រុងហ្សឺណែវដែលកើតឡើងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ ។

◆ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់និងទំនៀមទម្លាប់ដែលអាចអនុវត្តបាននៅពេលមានជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ ។

នេះបញ្ជាក់ថា ក្រោមអនុសញ្ញានិងច្បាប់ទម្លាប់អន្តរជាតិមានវិធានក្នុងការអនុវត្តផ្សេងៗគ្នានៅពេលមានជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ និងពេលដែលគ្មានជម្លោះប្រដាប់អាវុធជាអន្តរជាតិ ។ រូបមន្តដែលយកមកប្រើនេះមានន័យថានៅទីម័រខាងកើត ការរំលោភទៅលើច្បាប់គ្រប់គ្រង“មធ្យោបាយនិងវិធីសាស្ត្រ”នៃច្បាប់សង្គ្រាម (របៀបជម្លោះកើតឡើង) និងច្បាប់មនុស្សធម៌ (ដែលមានបំណងការពារជនទាំងឡាយណាដែលមិនមែនឬលែងជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងការវាយប្រយុទ្ធគ្នា) អាចយកមកជម្រះក្តីបានជាខក្រិដ្ឋកម្មសង្គ្រាម ។

ផ្ទុយមកវិញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ចែងត្រឹមតែពីការកាត់សេចក្តីខក្រិដ្ឋកម្មសង្គ្រាមនៅក្នុងទម្រង់ជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវប៉ុណ្ណោះ ។ បញ្ញត្តិទាំងនេះអនុវត្តបានតែនៅក្នុងករណីមានជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ ។ ទោះបីជាការសម្រាំងបង្កើតជារូបមន្តពិសេសនេះស្តែងឲ្យឃើញថាអ្នកធ្វើសេចក្តីព្រាងច្បាប់ខ្មែរក្រហមបានជឿជាក់ថាពិតជាមានជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ក៏ការកាត់សេចក្តីលើការរំលោភធ្ងន់ធ្ងរនឹងចាប់ដំណើរការដោយមានបញ្ហាថាតើព្រះរាជអាជ្ញាអាចបង្ហាញវិមតិសង្ស័យជាថាពិតជាមានជម្លោះអន្តរជាតិនៅកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ឬទេ ហើយរបបកម្ពុជាប្រជាធិបតេយ្យពិតជាបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវមែនដែរឬទេ ។

ទារុណកម្មដែលជាបទល្មើសធ្ងន់ធ្ងរនៅទីម័រខាងកើតអាចនឹងត្រូវកាត់សេចក្តីក្នុងលក្ខណៈជាបទខក្រិដ្ឋទោល ឬខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ខក្រិដ្ឋកម្មសង្គ្រាម ឬខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជាវិញ ទារុណកម្មដូចគ្នានេះដែរ អាចនឹងត្រូវកាត់សេចក្តីក្នុងលក្ខណៈជាបទរំលោភទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ខក្រិដ្ឋកម្មសង្គ្រាម ខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ធាតុផ្សំនានាដែលនាំឲ្យចូលជាការប្រព្រឹត្តទារុណកម្ម វាអាស្រ័យទៅលើការចាត់ជាចំណាត់ថ្នាក់ដែលត្រូវយកមកប្រើ ។ លក្ខណៈមួយក្នុងចំណោមលក្ខណៈសំខាន់ៗនៃ “តុលាការក្នុងស្រុកមានកម្រិតជាតុលាការអន្តរជាតិ” គឺការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌក្នុងស្រុកយកមកកាត់សេចក្តីអំពើឃោរឃៅ ។ ហេតុផលនៃការយកច្បាប់ព្រហ្មទណ្ឌក្នុងស្រុកមកប្រើនេះគឺថា ខក្រិដ្ឋកម្មអន្តរជាតិគឺជាខក្រិដ្ឋកម្មក្នុងស្រុកមុនគេនិងដឹងច្បាស់ជាងគេបង្អស់ ។ ឃាតកម្មជាលក្ខណៈខក្រិដ្ឋកម្មសង្គ្រាម ក៏រំលោភទៅលើវិធានប្រឆាំងនឹងការដកហូតជីវិតមនុស្សក្រោមច្បាប់ក្នុងស្រុកដែរ ។ ដូចគ្នានេះដែរគឺថា ការទទួលស្គាល់ថារដ្ឋអធិបតេយ្យ មានសិទ្ធិកាត់សេចក្តីជនទាំងឡាយណាដែលរំលោភទៅលើច្បាប់ជាតិ ហើយថា តុលាការនៅក្នុងរដ្ឋដែលមានផលប៉ះពាល់គួរតែអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនដូចសព្វមួយដង ។ ហេតុផលមួយទៀតក្នុងការប្រើច្បាប់ក្នុងស្រុកគឺថាវាផ្តល់នូវភាពអាចផ្លាស់ប្តូរបាន ក្នុងការចោទប្រកាន់ដែលជាការសំខាន់នៅពេលស្ថាប័ននេះ មិនសូវរឹងមាំនិងខ្វះធនធាននិងមិនអាចបង្កើតចេញជារូបរាង ភស្តុតាងដែលជាការចាំបាច់

សម្រាប់សំអាងថា មានឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានប្រព្រឹត្តឡើង ។ នៅទីម័រខាងកើត ឃាតកម្ម និងបទល្មើសខាងផ្លូវភេទដែលកើតឡើងក្នុងអំឡុងពេលគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៩ គឺជាបទឧក្រិដ្ឋកម្រិតធ្ងន់ ហើយអាចកាត់សេចក្តីថាជាការរំលោភទៅលើក្រមព្រហ្មទណ្ឌឥណ្ឌូនេស៊ីដោយក្រុមប្រឹក្សាតុលាការពិសេសមួយ ។ ប៉ុន្តែការកំណត់នៃច្បាប់ត្រូវបានរក្សាទុកឲ្យនៅដដែល ហើយការកំណត់នេះអាចរារាំងដល់ការកាត់សេចក្តីទៅលើការរំលោភបំពានជាលក្ខណៈប្រវត្តិសាស្ត្រទៅលើក្រមព្រហ្មទណ្ឌប្រទេសឥណ្ឌូនេស៊ី ។ ចំណែកនៅប្រទេសកម្ពុជាវិញ ច្បាប់ស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញចែងថា បទល្មើសមនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនាអាចកាត់សេចក្តីជាការរំលោភទៅនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានរយៈពេលកំណត់១០ឆ្នាំ ប៉ុន្តែត្រូវបានពន្យារពេលបន្ថែម២០ឆ្នាំទៀត ។

### ក) គោលការណ៍មូលដ្ឋាន

*ការទទួលខុសត្រូវជាបុគ្គល*

សំអាងបញ្ជាក់ពីការទទួលខុសត្រូវជាបុគ្គលដែលមានចែងច្បាស់ នៅក្នុងច្បាប់ទីម័រនិងច្បាប់កម្ពុជាគឺមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែច្បាប់របស់ទីម័រខាងកើតដែលចម្លងពីរូបមន្តនៃធម្មនុញ្ញតុលាការអន្តរជាតិទូលំទូលាយជាង ហើយរួមមានទាំងការចូលរួម ការញុះញង់ និងជនទាំងឡាយណាដែលជួយជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មឬឈានទៅដល់ការប្រព្រឹត្តដោយខ្លួនឯងផង ។ ច្បាប់នេះក៏បញ្ចូលជនទាំងឡាយណាដែលចូលរួមប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តឧក្រិដ្ឋកម្មនេះ (ការចូលរួមត្រូវតែមានចេតនា ព្រមទាំងធ្វើឡើងដោយមានគោលបំណងច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពឧក្រិដ្ឋ ឬគោលបំណងរបស់ក្រុម ឬដោយមានការដឹងឮពីចេតនារបស់ក្រុមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម) ។ ការញុះញង់ជាសាធារណៈឬដោយផ្ទាល់ឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ត្រូវបានយកជាសំអាងយ៉ាងច្បាស់តាមរយៈការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនានាទាំងនៅទីម័រនិងនៅកម្ពុជា ។

*ឋានៈ*

ច្បាប់របស់ទីម័រលេខ ២០០០/១៥ ចែងច្បាស់ថា ឋានៈជាប្រមុខរដ្ឋឬរដ្ឋាភិបាលឬដែលកើតចេញពីការតែងតាំងតាមលក្ខណៈប្រជាធិបតេយ្យ មិនអាចជួយឲ្យបុគ្គលណាម្នាក់រួចផុតពីការទទួលខុសត្រូវជាបុគ្គលបានឡើយ ។ មិនតែប៉ុណ្ណោះ ច្បាប់នេះបានប្រើពាក្យដែលរក្សាទុកនូវឋានៈដែលអាចបង្កើតជាសំអាងប្រឆាំងនឹងការសម្រាលទោស(ច្បាប់នេះមិនត្រូវបង្កើតជាសំអាងនាំដល់ការបន្ធូរបន្ថយទោសទេ) ។ (នេះជាចំណុចផ្ទុយគ្នាជាមួយច្បាប់ស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញរបស់កម្ពុជាដែលតួនាទីឬឋានៈរបស់ជនសង្ស័យអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឬជួយបន្ថយទោសដល់ជននេះបាន) ។ ច្បាប់កម្ពុជាអាចមានន័យថា ទាហានថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជាមិនអាចទទួលការសម្រាលទោសបានឡើយ ។ ប៉ុន្តែដោយសារតែច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនោះ ចំណុចនេះមិនមែនជាបញ្ហាទេ ល្គឹកណាទាហានថ្នាក់ក្រោមមិនត្រូវបានចាត់ទុកថាជាបុគ្គលស្ថិតក្នុងចំណោម“ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត”ចំពោះឧក្រិដ្ឋកម្មទេនោះ ។

*ការទទួលខុសត្រូវជាខ្សែសង្វាក់បញ្ជា*

ច្បាប់របស់ទីម័រខាងកើតចែងថា គោលការណ៍នៃការទទួលខុសត្រូវជាខ្សែសង្វាក់បញ្ជា (ដែលក្នុងនោះមេបញ្ជាការឬថ្នាក់ដឹកនាំទទួលខុសត្រូវចំពោះអំពើដែលកូនចៅបានប្រព្រឹត្ត) កើតឡើងនៅពេលណាដែលៈ ក) ថ្នាក់លើបានដឹងឮឬមានហេតុផលដឹងថាកូនចៅរបស់ខ្លួនហៀបនឹងប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់ ឬបានប្រព្រឹត្តឧក្រិដ្ឋរួចហើយ និង ខ) ថ្នាក់លើមិនបានចាត់វិធានការចាំបាច់និងសមហេតុផលដើម្បីទប់ស្កាត់អំពើទាំងនេះ ឬមិនបានផ្តន្ទាទោសចារី ។ ដូច្នេះអ្នកធ្វើសេចក្តីព្រាងច្បាប់សម្រេចចិត្តមិនអនុវត្តបញ្ញត្តិដែលប្រើនៅក្នុងលក្ខន្តិកៈច្បាប់តុលាអន្តរជាតិ ប៉ុន្តែបានប្រើរូបមន្តតាមតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ូវ៉ាន់ដាទៅវិញ ។ **(នៅមានត)**

**ស៊ូហ្សាណា លីនតុន**

# អង្គការសហប្រជាជាតិមិនចូលរួមកាត់ទោសមេដឹកនាំខ្មែរក្រហម



***សន្និសីទសារព័ត៌មានសង្ខេបប្រចាំថ្ងៃរបស់ការិយាល័យអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២***

ខាងក្រោមនេះគឺជាកំណត់ត្រាជាលាយលក្ខណ៍អក្សរស្ទើរតែទាំងស្រុងនៃការពន្យល់ប្រាប់យ៉ាងសង្ខេបរបស់លោក ហ្វ្រេដ អេកហាដ អ្នកនាំពាក្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ៖

សូមជម្រាបសួរអស់លោកលោកស្រី ។ កាលពីម្សិលមិញ យើងបានប្រកាសថា ភ្ញៀវរបស់យើងដែលនឹងមកធ្វើការពន្យល់ប្រាប់យ៉ាងសង្ខេបថ្ងៃរសៀលនេះគឺលោក ម៉ៃឃើល ស្តេនន័រ ដែលជាតំណាងពិសេសថ្មីរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកបញ្ហាយូហ្គោស្លាវី ។ កម្មវិធីនៅតែដដែលទេ ប៉ុន្តែយើងមានសេចក្តីប្រកាសសំខាន់មួយមកជម្រាបជូនទាក់ទងនឹងបញ្ហាកម្ពុជា ដែលក្នុងសេចក្តីប្រកាសនេះ យើងបានអញ្ជើញលោក ហេន ខូរេល ជាទីប្រឹក្សាច្បាប់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិមកចូលរួមដែរ ។

ការពន្យល់ប្រាប់យ៉ាងសង្ខេបនៅថ្ងៃនេះមានតែមួយចំណុចប៉ុណ្ណោះដែលលោក ហេន ខូរេល នឹងជម្រាបជូន។ ព័ត៌មានចេញពីការពន្យល់សង្ខេបនេះនឹងបញ្ចូលទៅក្នុងវេបសៃដោយផ្ទាល់ ។ បន្ទាប់មកលោក ស្តេនន័រ នឹងជម្រាបជូនពីបញ្ហាកូសូវ៉ូ ។ ពេលនេះសូមជម្រាបជូនបញ្ហាកម្ពុជាសិន ។

## កម្ពុជា

ថ្ងៃនេះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្គាប់ឲ្យទីប្រឹក្សាច្បាប់គឺ លោក ហេន ខូរេល ចេញលិខិតមួយច្បាប់ជូនរដ្ឋាភិបាលកម្ពុជាដោយជម្រាបថាអង្គការសហប្រជា-ជាតិនឹងឈប់ចរចាជាមួយរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ ទៀតហើយ ។

លិខិតនេះពន្យល់ហេតុផលពីរយ៉ាងដែលនាំដល់ការសម្រេចចិត្តបែបនេះ ។ **ហេតុផលទី១** គឺថា ឆ្លងតាមការពិនិត្យអង្កេតទៅលើដំណើរការចរចាទាំងមូលអង្គការសហប្រជាជាតិឈានដល់ការសន្និដ្ឋានស្របនឹងការប្រមើលកាលពីពេលថ្មីៗនេះដែរថា តុលាការកម្ពុជាមិនអាចធានាឲ្យបានប្រាកដនូវឯករាជ្យភាព ភាពគ្មានលំអៀង និងការសម្រេចតាមគោលដៅ ។ ចំណុចទាំងនេះគឺជាតម្រូវការរបស់អង្គការសហប្រជាជាតិមុននឹងខ្លួនយល់ព្រមធ្វើសហប្រតិបត្តិការជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

**ហេតុផលទី២** រដ្ឋាភិបាលកម្ពុជាបានបដិសេធសំណើរបស់អង្គការសហប្រជាជាតិដែលដាក់លក្ខខណ្ឌថា ជំនួយដែលអង្គការសហប្រជាជាតិនឹងផ្តល់ឲ្យនឹងត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ។ កម្ពុជាទទូចថាមានតែវិធានរបស់ខ្លួនទេដែលអាចគ្រប់គ្រងលើជំនួយនេះបាន ។

លោក ហេន ខូរេល នៅទីនេះស្រាប់ ។ លោកនឹងឡើងមកពន្យល់អំពីជំហររបស់អង្គការសហប្រជាជាតិនឹងឆ្លើយនូវសំណួររបស់អស់លោក និងលោកស្រី ។

ការពន្យល់សង្ខេបរបស់លោក ហេន ខូរេល អគ្គលេខា-ធិការរងនៃអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់និងជាទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ៖

សូមអរគុណចំពោះលោក អេក ហាដ និងសូមជម្រាបសួរអស់លោក និងលោកស្រី ៖

តាមសេចក្តីបង្គាប់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ អង្គការសហប្រជាជាតិនឹងឈប់បន្តការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាទៀត ហើយទាក់ទងនឹងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជា-ធិបតេយ្យ ។ ហេតុផលដែលឈានដល់ការសម្រេចចិត្តបែបនេះមានដូចខាងក្រោមៈ

ការចរចារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា

គឺចាប់ផ្តើមឡើងដំបូងតាមរយៈសំណើរបស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន ដែលជាសហនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។ នៅក្នុងសំបុត្រចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សម្តេចក្រុមព្រះនិងសម្តេច ហ៊ុន សែន សហការរួមគ្នាស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងការនាំយកជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងអំឡុងសម័យខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ មកកាត់ទោស ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញការមួយក្រុមដែលតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានស្នើសូមឲ្យបង្កើតតុលាការអន្តរជាតិមួយ ។ ក៏ប៉ុន្តែគម្រោងការនេះត្រូវបានផ្លាស់ប្តូរ ។ នៅក្នុងខ្លឹមសារលិខិតចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ផ្ញើមកលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ពោលគឺរយៈពេល២ឆ្នាំក្រោយពីសំណើលើកដំបូង សម្តេច ហ៊ុន សែន ដែលសព្វថ្ងៃនេះជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាតែម្នាក់ឯង បានផ្លាស់ប្តូរសំណើច្បាប់ ។ ការផ្តោតសំខាន់ថ្មីគឺការបង្កើតតុលាការជាលក្ខណៈជាតិដោយមានការចូលរួមពីសំណាក់ចៅក្រមនិងព្រះរាជអាជ្ញាបរទេស ។

ទោះបីជាលែងមានសំណើសុំបង្កើតតុលាការអន្តរជាតិក៏ដោយ ប៉ុន្តែអង្គការសហប្រជាជាតិត្រូវបានជម្រុញពីសំណាក់រដ្ឋជាសមាជិកឲ្យបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ហេតុដូចនេះ អង្គការសហប្រជាជាតិបានចរចាលើកិច្ចព្រមព្រៀងមួយរវាងអង្គការនេះនិងរដ្ឋាភិបាលកម្ពុជា ។ គណៈប្រតិភូអង្គការសហប្រជាជាតិបានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញចំនួន៣លើកតាមតាមការអញ្ជើញរបស់រដ្ឋាភិបាលកម្ពុជា ។ ទស្សនកិច្ចទាំង៣លើកនេះធ្វើឡើងក្នុងខែសីហាឆ្នាំ ១៩៩៩ ខែមីនា ឆ្នាំ២០០០ និងខែមករា ឆ្នាំ២០០០ ម្តងទៀត ។ ក្នុងទស្សនកិច្ចលើកចុងក្រោយ គឺធ្វើឡើងដោយប្រមុខគណៈប្រតិភូតែម្តង ។ ខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ដោយមានសេចក្តីប្រកាសព័ត៌មានខ្លីមួយបញ្ជាក់ថា មានការយោគយល់គ្នាទាក់ទងទៅនឹងលទ្ធផលនៃការចរចា ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានឃើញសេចក្តីព្រាងច្បាប់និងអត្ថបទកិច្ចព្រមព្រៀងដែលនឹងត្រូវចុះហត្ថលេខាដោយអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការពិនិត្យពិច័យឲ្យកាន់តែលម្អិត ។

កិច្ចចរចារវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចេះតែធ្វើដំណើរឆ្ងាយទៅៗជាងការសង្ឃឹមទុកក្នុងខណៈដែលការពិភាក្សានានាបានចាប់ផ្តើមជាង២ឆ្នាំទៅហើយ ។ ពេលវេលាចេះតែកន្លងទៅ ការផ្តើមគំនិតគឺស្ថិតនៅខាងរដ្ឋាភិបាលកម្ពុជា ទោះបីជាមានសេចក្តីថ្លែងដោយមន្ត្រីជាន់ខ្ពស់កម្ពុជាថាអង្គការសហប្រជាជាតិជាអ្នកទទួលខុសត្រូវចំពោះការយឺតយ៉ាវនេះក៏ដោយ ។ មិនតែប៉ុណ្ណោះក្នុងអំឡុងពេលក្រោយពីខែកក្កដាឆ្នាំ២០០០ អង្គការសហប្រជាជាតិបានរង់ចាំការអនុម័តច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ជាង១ឆ្នាំក្រោយមកទើបច្បាប់នេះត្រូវបានអនុម័ត ពោលគឺនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០១ ។ អង្គការសហប្រជាជាតិបានទទួលអត្ថបទច្បាប់បកប្រែជាផ្លូវការពីភាសាខ្មែរមកភាសាអង់គ្លេសនិងបារាំងដោយមានភ្ជាប់ជាមួយនូវសំបុត្ររបស់លោកទេសរដ្ឋមន្ត្រី សុខ អាន ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១ ។ នៅក្នុងអំឡុងពេលនោះ អង្គការសហប្រជាជាតិបានផ្តល់នូវយោបល់ជាច្រើនសំដៅជួយរដ្ឋាភិបាលឲ្យបង្កើតវិធីការគួរឲ្យទុកចិត្តបាន ហើយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយលោកទេសរដ្ឋមន្ត្រី សុខ អាន ដើម្បីឈានដល់សេចក្តីព្រាងទៅលើកិច្ចព្រមព្រៀងមួយស្តីពីការបង្កើតនិងដំណើរការនៃអង្គជំនុំជម្រះនេះ ។

ក្រោយពីមានការយឺតយ៉ាវយ៉ាងយូរមក អង្គការសហប្រជាជាតិមានលទ្ធភាពពិនិត្យទៅលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលខ្ញុំនឹងនិយាយត្រឹមថា “ច្បាប់” នៅពេលក្រោយមកទៀត ។ នៅក្នុងលិខិតមួយច្បាប់ចុះថ្ងៃទី១០ខែតុលា ឆ្នាំ២០០១ ផ្ញើមកទេសរដ្ឋមន្ត្រី សុខ អាន គឺ៤សប្តាហ៍ក្រោយ ខ្ញុំបាននិយាយថា នៅសល់បញ្ហាមួយចំនួនសម្រាប់អង្គការសហប្រជាជាតិដោះស្រាយ ។ បញ្ហាសំខាន់ទី១គឺថា តើឯកសារណាមួយ ច្បាប់ឬក៏កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដែលនឹងគ្រប់គ្រងទៅលើដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងគ្រា

ដែលមានភាពមិនត្រូវរ៉ូវគ្នារវាងឯកសារទាំងពីរនេះ ។ នៅក្នុងសំបុត្រផ្ញើជូនខ្ញុំ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ទេសរដ្ឋមន្ត្រី សុខ អាន មានប្រសាសន៍ថាៈ «ខណៈដែលមាត្រាមួយចំនួនស្តីពីកិច្ចសហប្រតិបត្តិការអាចបំភ្លឺបញ្ជាក់ទៅលើភាពលាំគ្នាមួយចំនួននៅក្នុងច្បាប់ និងបរិយាយយ៉ាងល្អិតល្អន់ទៅលើចំណុចលម្អិតទាំងនោះ ដូច្នេះគេមិនអាចកែប្រែច្បាប់ដែលត្រូវបានអនុម័តរួចហើយទេ កុំថាឡើយទៅបញ្ចុះបញ្ចូលនោះ» ។ អង្គការសហប្រជាជាតិត្រូវតែទទួលយកច្បាប់នេះដែលជាជំហរចុងក្រោយរបស់រដ្ឋាភិបាលកម្ពុជា ។

នេះគឺជាជំហរឥតងាករេរបស់អង្គការសហប្រជាជាតិដែលថា នៅក្នុងបរិបទបែបនេះ អង្គការនេះមិនអាចបង្ខំដោយច្បាប់ជាតិបានទេ ។ ហេតុដូចនេះ អង្គការសហប្រជាជាតិបានទទូចនៅរាល់ពេលមានកិច្ចចរចាដោយផ្អែកតាមការអនុវត្តធម្មតា ក្នុងការបញ្ចប់កិច្ចព្រមព្រៀងជាអន្តរជាតិថាអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាគួរតែឈានដល់កិច្ចព្រមព្រៀងដែលមានកម្រិតមួយ ។ ជាងនេះទៀត ជំហរឥតងាករេរបស់អង្គការសហប្រជាជាតិគឺថា ច្បាប់នេះនឹងអនុលោមទៅតាមមាតិកានៃកិច្ចព្រមព្រៀងនោះ ។ បញ្ហាអធិបតេយ្យភាពកម្ពុជាមិនមែនជាបញ្ហានៅត្រង់ចំណុចនេះទេ ។ បញ្ហានេះតម្រូវឲ្យមានកិច្ចព្រមព្រៀងមួយដែលនឹងត្រូវយកមកអនុវត្តក្រោមគោលការណ៍មួយដែលតាមច្បាប់អន្តរជាតិគេឲ្យឈ្មោះថា “*pacta sunt servanda*” ដែលមានន័យជាទូទៅថា លក្ខខណ្ឌនានាដែលចែងនៅក្នុងកិច្ចព្រមព្រៀងត្រូវតែចងភ្ជាប់ឲ្យភាគីទាំងពីរអនុវត្តតាមឲ្យបានត្រឹមត្រូវ» ។

បញ្ហាថាតើឯកសារណាមួយដែលគ្រប់គ្រងទៅលើដំណើរអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋាភិបាលដើម្បីដាក់ច្បាប់នេះជូនសភាជាតិមុនពេលឈានដល់កិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិ ។ អង្គការសហប្រជាជាតិចេះតែបន្តពិភាក្សាទៅជាមួយរដ្ឋាភិបាលកម្ពុជាលើកិច្ចព្រមព្រៀងនេះនិងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងស្មុក់ស្មើរ ទោះបីជាមានចែង «ខ» ប្រការមួយចំនួនស្តីអំពីដំណើរការទាំងមូលហើយក៏ដោយ ។ អង្គការសហប្រជាជាតិមិនដែលមានការព្រួយបារម្ភទៅលើនីតិវិធីទេ ។ ផ្ទុយមកវិញ ការឈានដល់កិច្ចព្រមព្រៀងមួយគឺជាលក្ខខណ្ឌដ៏សំខាន់សម្រាប់ឲ្យអង្គការនេះបានចូលរួមក្នុងអង្គជំនុំជម្រះទាំងមូល ។ ការធ្វើកិច្ចព្រមព្រៀងទៅជាឯកសារបច្ចេកទេសនិងរដ្ឋបាលដែលស្ថិតនៅក្រោមបង្គាប់ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនឹងធ្វើឲ្យច្បាប់នេះអស់មានតួនាទីសំខាន់នៅក្នុងការធានាឲ្យប្រាកដថា យុត្តិធម៌ដែលមានបទដ្ឋានអន្តរជាតិដែលជាចំណុចសំខាន់សម្រាប់ឲ្យមានការបន្តចូលរួមពីសំណាក់អង្គការសហប្រជាជាតិ នឹងត្រូវរក្សាបាននៅក្នុងប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ។

តាមរយៈជំហររបស់រដ្ឋាភិបាលកម្ពុជានៅក្នុងបញ្ហានេះ ឃើញថាភាគីទាំងពីរមិនអាចដោះស្រាយបញ្ហានេះតាមរយៈការចរចាបន្តទៀតបានទេ ។ មិនតែប៉ុណ្ណោះសោត ដោយបានពិនិត្យសាឡើងវិញទៅលើការទាក់ទងគ្នាអស់រយៈពេលប៉ុន្មានខែចុងក្រោយនេះ រួមទាំងសំបុត្រមួយច្បាប់ដែលខ្ញុំទទួលបានពីទេសរដ្ឋមន្ត្រី សុខ អាន ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ផង អង្គការសហប្រជាជាតិបានទាញសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះវិសាមញ្ញនេះដូចដែលបានប្រមើលនាពេលថ្មីៗនេះស្រាប់ គឺមិនអាចធានាបាននូវឯករាជ្យភាព ភាពគ្មានលម្អៀង និងការសម្រេចតាមគោលដៅដូចដែលតុលាការដែលបង្កើតឡើងដោយមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិចង់បាននោះទេ ។

នៅក្នុងអំឡុងពេលនៃកិច្ចចរចា អង្គការសហប្រជាជាតិបានប្រកាន់ជំហរថាត្រូវតែមានបទដ្ឋានយុត្តិធម៌អន្តរជាតិទើបអង្គការសហប្រជាជាតិចូលរួមជាមួយអង្គជំនុំជម្រះវិសាមញ្ញនេះ ។ អង្គការសហប្រជាជាតិបានខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហារបស់រដ្ឋាភិបាលកម្ពុជា ។ នៅទន្ទឹមពេលនោះដែរ យើងក៏បានព្យាយាមអស់ពីសមត្ថភាពក្នុងការការពារសុច្ចរិតភាពរបស់អង្គជំនុំជម្រះនិងការកាត់សេចក្តី ។ អង្គការសហប្រជាជាតិមានការសោកស្តាយដែលរដ្ឋាភិបាលកម្ពុជាមិនអាចដោះស្រាយបញ្ហារបស់ខ្លួនមុនពេលច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានអនុម័ត ។ ប្រសិនបើដោះស្រាយហើយមុននោះវានឹងចូលទៅក្នុងច្បាប់ហើយសំខាន់កិច្ចព្រមព្រៀងនោះនឹងគ្រប់គ្រងទៅលើបទដ្ឋានដែលបានយល់ព្រមជាមួយគ្នារួចហើយនោះ

យ៉ាងមានប្រសិទ្ធភាពបំផុត ។ ជាអកុសល រដ្ឋាភិបាលកម្ពុជាធ្វើតាមចិត្តរបស់ខ្លួនដោយមិនបានទទួលស្គាល់ថា កិច្ចព្រមព្រៀងមួយនេះគឺជាកិច្ចព្រមព្រៀងដែលចេញពីការយល់ស្របរបស់ភាគីទាំងសងខាងឡើយ ។

ចំណុច១ទៀត ។ ដោយជួបនូវកាលៈទេសៈដូចដែលខ្ញុំលើកមកនេះ អង្គការសហប្រជាជាតិបានពិនិត្យសាឡើងវិញទៅលើដំណើរការចរចានៅពេលដែលការចរចានេះវិវត្តន៍ពីការទាក់ទងដំបូងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាក្នុងខែមិថុនា ឆ្នាំ១៩៩៧ មកទល់នឹងបច្ចុប្បន្ននេះ ។ អ្វីដែលបានកើតឡើងនៅពេលនេះ និងជាពិសេសចាប់តាំងពីការចរចាជាលើកចុងក្រោយនៅកម្ពុជាកាលពីខែកក្កដាឆ្នាំ២០០០ បានបង្កជាបុព្វហេតុមួយឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងពីសំណាក់អង្គការសហប្រជាជាតិ ។ អង្គការសហប្រជាជាតិមានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើភាពយឺតយ៉ាវដូចដែលបានស្តែងឡើងនៅក្នុងអំឡុងពេល១ឆ្នាំកន្លះចាប់តាំងពីការធ្វើទស្សនកិច្ចនោះមក ។ ការយឺតយ៉ាវនោះបានពន្យារពេលកាន់តែយូរទៅៗ ។ តាមពិតទៅ បើយករយៈពេលនេះទៅដំណើរការអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែចាស់ វាជាការស្រេចបាត់ទៅហើយ ។ អង្គការសហប្រជាជាតិព្រួយបារម្ភថាភាពយឺតយ៉ាវនេះអាចនឹងបន្តទៅទៀត ហើយនឹងប៉ះពាល់ដល់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ។

ហេតុដូចនេះ ក្រោយពីពិចារណាទៅលើបញ្ហាទាំងនេះ អង្គការសហប្រជាជាតិបានឈានដល់សេចក្តីសន្និដ្ឋានថា ដំណាក់កាលជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញមិនអាចធានាបាននូវយុត្តិធម៌ដែលមានបទដ្ឋានអន្តរជាតិ ដែលជាលក្ខខណ្ឌតម្រូវរបស់អង្គការសហប្រជាជាតិដើម្បីឲ្យខ្លួនមានឱកាសបន្តចូលរួមធ្វើការជាមួយឆ្ពោះទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ហើយបានសម្រេចបញ្ចប់ការចូលរួមរបស់ខ្លួននៅក្នុងដំណើរការតុលាការនេះទាំងសោកស្តាយ ។

ដោយទទួលស្គាល់នូវគោលបំណងដែលបានលើកឡើងដោយរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដោយគ្មានការពន្យារពេល សេចក្តីសម្រេចនេះនឹងធ្វើឲ្យរដ្ឋាភិបាលកម្ពុជារៀបចំកិច្ចសម្រុះសម្រួលផ្សេងទៀតនិងចាប់ផ្តើមដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

អង្គការសហប្រជាជាតិមានសេចក្តីប្រាថ្នារួមជាមួយប្រជាជនកម្ពុជាក្នុងការបិទទំព័រប្រវត្តិសាស្ត្រខ្មែរក្រហមតាមវិធីដែលនាំមកនូវការផ្សះផ្សានិងបង្រួបបង្រួមជាតិនិងយុត្តិធម៌ ហើយសូមឲ្យរដ្ឋាភិបាលកម្ពុជាសុខភាពល្អដើម្បីខិតខំប្រឹងប្រែងឈានទៅសម្រេចគោលដៅនេះ ។

សូមអរគុណដែលបានយកចិត្តទុកដាក់ស្តាប់ ។

## សំណួរនិងចម្លើយ

**សំណួរៈ** តើលោកអាចមានប្រសាសន៍លម្អិតជាងនេះបានទេថា បទដ្ឋាននិងនីតិវិធីណាខ្លះ (ដូចដែលរដ្ឋាភិបាលបានប្រមើលគិតទុកក្នុងដំណើរការការកាត់ទោសនេះ) ដែលស្ថិតនៅក្នុងការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិ?


ហេន ខូរេល

**លោក ខូរេលៈ** មានបញ្ហាច្រើនណាស់ ។ ទីមួយគឺការរៀបចំរបៀបនេះ ជាការរៀបចំដែលមានភាពសាំញ៉ាំបំផុត ។ នៅក្នុងកិច្ចចរចាយើងបានព្យាយាមធ្វើឲ្យបានប្រាកដដោយប្រើមធ្យោបាយផ្សេងៗថា នៅក្នុងគ្រប់ជំហានទាំងអស់មានបីដំណាក់កាល នៅក្នុងដំណាក់កាលមុនជំនុំជម្រះក្តី ដែលបទដ្ឋានទាំងនេះត្រូវបានបំពេញហើយ ។ ប៉ុន្តែនៅមានបញ្ហាជាច្រើនទៀត ដែលយើងបានលើកទៅរដ្ឋាភិបាលកម្ពុជា ។ បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនោះគឺថា ជនជាប់ចោទមិនអាចទទួលការអនុញ្ញាតឲ្យរកមេធាវីតាមចិត្តរបស់ខ្លួនឡើយ ។

ប៉ុន្តែមានបញ្ហាមួយចំនួនដែលខ្ញុំគិតថាមិនគួរលើកមកនិយាយលម្អិតនៅទីនេះ ប៉ុន្តែគំនិតសំខាន់ទូទៅនិងការដែលរដ្ឋាភិបាលកម្ពុជាមិនបានរៀបចំខ្លួនអនុញ្ញាតឲ្យកិច្ចព្រមព្រៀងមួយនោះឲ្យក្លាយទៅជាឯកសារសម្រាប់គ្រប់គ្រងដំណើរការទាំងមូល មានន័យថាយើងមិនដឹងអំពីអ្វីដែលទាក់ទងនឹងបញ្ហានេះទៅថ្ងៃមុខនឹងវិវត្តន៍យ៉ាងដូចម្តេចទេ ។ ប្រសិនបើអង្គការសហ-

ប្រជាជាតិចង់ចូលទៅក្នុងកិច្ចខិតខំប្រឹងប្រែងកម្រិតនេះ ដែលតម្រូវឲ្យមានការគាំទ្រពីសំណាក់រដ្ឋជាសមាជិកក្នុងការផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ (ដូចដែលយើងឃើញស្រាប់នៅប្រទេសសេរ៉ាឡេអូន) នោះយើងត្រូវតែប្រាកដថាគម្រោងច្បាប់នេះបានត្រូវជាប់គាំងនៅត្រឹមកិច្ចព្រមព្រៀងនេះទៅហើយ ។ ចំណុចនេះរដ្ឋាភិបាលមិនបានយល់ស្របឡើយ ។

**សំណួរៈ** ដូច្នេះចំណុចដែលលោកជំទាស់មិនមានច្រើនទេ ចំណុចសំខាន់គឺអំណាចគ្រប់គ្រង ។

**លោក ខូរេលៈ** ត្រឹមត្រូវហើយ ។

**សំណួរៈ** ប៉ុន្តែតើក្រៅពីរឿងមេធាវីនេះ មានបញ្ហាខុសពីនេះច្រើនទេ?

**លោក ខូរេលៈ** បាទមាន ។ មានបញ្ហាជាច្រើនដែលយើងបានលើកឡើងជាមួយគ្នានេះដែរ ។

**សំណួរៈ** លោកមិនចង់និយាយឲ្យគេដឹងទេថាបញ្ហាទាំងនេះជាបញ្ហាអ្វីខ្លះ?

**លោក ខូរេលៈ** ខ្ញុំចង់និយាយថា វាជាការអនុវត្តដែលមានលក្ខណៈទទឹសទទែងខ្លាំង ហើយមានកត្តាមួយចំនួនទៀតដែលត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធីដែលយើងបានប្រាប់ឲ្យដឹងជាមុន ហើយថាវាមិនអាចធ្វើបានទេ ។ យើងមិនអាចយល់ស្របទៅចំណុចទាំងនោះទេ ហើយគេ (រដ្ឋាភិបាលកម្ពុជា) មិនទទួលយកគំនិតនេះទេ ។

**សំណួរៈ** ក្នុងចំណោមរឿងទាំងអស់ តើអ្វីសំខាន់ជាងគេជាការខ្វះឆន្ទះនយោបាយរបស់រដ្ឋាភិបាលដែលលោកបានលើកឡើង ភាពយឺតយ៉ាវចាប់តាំងពីទស្សនកិច្ចខែកក្កដា ឆ្នាំ២០០២ ឬបញ្ហាបច្ចេកទេសទាំងនេះ? តើមួយណាសំខាន់ជាងគេ? តើលោកអាចប្រមើលទុកមុនទេថាអាចមានឱកាសណាមួយដែលលោកអាចវិលត្រឡប់ទៅរកកិច្ចសហប្រតិបត្តិការសាជាថ្មីជាមួយរដ្ឋាភិបាលកម្ពុជាលើបញ្ហានេះទេ?

**លោក ខូរេលៈ** អង្គការសហប្រជាជាតិបានប្រមើលដំណើរការនេះអស់រយៈពេល៤ឆ្នាំកន្លះ ។ ២ឆ្នាំដំបូងផ្តោតទៅលើជម្រើសផ្សេងៗដែលត្រូវបានពិនិត្យដោយក្រុមអ្នកជំនាញការហើយ ដែលនាំដល់អនុសាសន៍ច្បាស់លាស់ទៀតផង ។ អនុសាសន៍នោះ ពោលគឺតុលាការអន្តរជាតិមិនត្រូវបានទទួលយកឡើយ ។ ការណ៍នេះត្រូវបានកត់សម្គាល់នៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ។ ប៉ុន្តែរដ្ឋដែលជាសមាជិកបានជំរុញឲ្យយើងបន្តកិច្ចចរចាតទៅទៀត ។ ខ្ញុំសូមសារភាពថាយើងមានពិភាល់រួចទៅហើយ ប៉ុន្តែយើងបានព្យាយាមឲ្យអស់លទ្ធភាពក្នុងនាមជារដ្ឋការស៊ីវិល ក្នុងការសម្រេចឲ្យបានលទ្ធផលដែលអាចទទួលយកបាន ។ និយាយឲ្យត្រង់ទៅខ្ញុំបានទទួលការរិះគន់ជាច្រើនពីសំណាក់មនុស្សដែលដឹងពីបញ្ហាច្បាប់នេះថាយើងធ្វើជ្រុលពេកហើយ ។ ប៉ុន្តែយើងគិតថាយើងអាចការពារលទ្ធផលដែលសម្រេចបាននៅខែកក្កដា ឆ្នាំ២០០០ ប្រសិនបើលទ្ធផលនោះត្រូវបានគេទទួលយកកាលពីពេលនោះ ហើយប្រសិនបើមានការយល់ព្រមថាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាក្លាយជាឯកសារសម្រាប់គ្រប់គ្រងដំណើរការនោះ ។ ចំណុចនេះ រដ្ឋាភិបាលកម្ពុជាមិនទទួលយកទេ ។ ថាតើយើងនឹងត្រឡប់ទៅវិញឬយ៉ាងណានោះ លោកអគ្គលេខាធិការបានសម្រេចរួចទៅហើយ ហើយនេះគឺជាអ្វីដែលខ្ញុំទាក់ទងជាមួយអស់លោក-លោកស្រី នៅពេលនេះ ។ ខ្ញុំមិនចង់ចូលទៅជ្រៅរហូតដល់សម្មតិកម្មដែលហួសពីការពិតនោះទេ ។

**សំណួរៈ** រាល់ការទាក់ទងដែលលោកបានលើកឡើង តើឯកសារទាំងនោះជាឯកសារសាធារណៈដែរឬទេ?

**លោក ខូរេលៈ** ទេ ។ ទាំងអស់នេះជាឯកសារដែលខ្ញុំបានផ្លាស់ប្តូរជាមួយទេសរដ្ឋមន្ត្រី សុខ អាន ។ ខ្ញុំដឹងថាឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងអស់នោះមាននៅក្នុងកិច្ចប្រជុំ ។ ប៉ុន្តែការពន្យល់សង្ខេបនៅពេលនេះខ្ញុំនឹងជូននៅទីនេះ ។

**សំណួរៈ** តើសេចក្តីសម្រេចចុងក្រោយនេះធ្វើឡើងដោយក្រុមប្រឹក្សាសន្តិសុខមហាសន្និបាតឬការិយាល័យប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិ?

**លោក ខូរេលៈ** មិនមែនធ្វើឡើងដោយការិយាល័យប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិទេ ។ សេចក្តីសម្រេចនេះគឺចេញពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (កូហ្វី អាណាន់ ។ ប៉ុន្តែក្រុមប្រឹក្សាសន្តិសុខមិនទាន់មានការពាក់ព័ន្ធនៅក្នុងរឿងនេះនៅឡើយទេ ហើយខ្ញុំគិតថាក្រុមប្រឹក្សាសន្តិសុខ

មានការចាប់អារម្មណ៍ចង់ចូលរួមក្នុងរឿងនេះដែរ ។

មហាសន្និបាតអង្គការសហប្រជាជាតិបានដើរតាមក្រោយ ។ នៅពេលមហាសន្និបាតដើរតាមក្រោយរឿងនេះ ជាការច្បាស់ណាស់វាជាការជំរុញឲ្យអគ្គលេខាធិការដ្ឋានចូលរួមក្នុងកិច្ចរចាទាំងនេះដែរ ។ ប៉ុន្តែជាមូលដ្ឋាន អគ្គលេខាធិការដ្ឋាន និងលោកអគ្គលេខាធិការដែលបាននិងកំពុងដោះស្រាយបញ្ហានេះ ។

***សំណួរ:*** នៅក្នុងជំហរកម្ពុជាតើអ្វីដែលលោកចាត់ទុកថាជាការផ្លាស់ប្តូរ? លទ្ធផលនេះបានមកពីណា?

***លោក ខូរេលៈ*** ខ្ញុំមិននិយាយជំនួសមុខឲ្យរដ្ឋាភិបាលកម្ពុជាទេ ។ អ្វីដែលខ្ញុំចង់និយាយគឺថាតាំងពីដើមដំបូងមកម្ល៉េះ គឺយើងបានបញ្ជាក់អ្វីៗឲ្យច្បាស់លាស់អស់ហើយថា យើងនឹងត្រូវតែមានកិច្ចព្រមព្រៀងមួយដែលកំណត់ច្បាស់លាស់អំពីទ្រង់ទ្រាយ និងព្រំដែននៃការពិភាក្សាលក្ខខណ្ឌនានាសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ យើងបានសុំឲ្យរដ្ឋាភិបាលកុំអាលដាក់ច្បាប់ជូនរដ្ឋសភាមុនពេលឈានដល់កិច្ចព្រមព្រៀងមួយ ។ ទោះបីជាប្រាប់យ៉ាងដូច្នេះក៏ដោយ ក៏រដ្ឋាភិបាលនៅតែបន្តធ្វើ ហើយដាក់សេចក្តីព្រាងច្បាប់នេះជូនរដ្ឋសភាអនុម័ត ។ យើងបានពិភាក្សាបញ្ហានេះជាមួយលោកអគ្គលេខាធិការ ពីព្រោះក្នុងន័យនេះនិងកាលៈទេសៈនេះ បញ្ហានេះជាបញ្ហាបច្ចេកទេស ។ ដូច្នេះយើងសម្រេចចិត្តខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាព ។ យើងបន្តកិច្ចពិភាក្សា ។ ប៉ុន្តែនៅក្នុងអំឡុងពេលនោះ យើងបានបញ្ជាក់ទៅគណៈប្រតិភូផ្សេងទៀតថា យើងបានបញ្ចប់កិច្ចព្រមព្រៀងហើយ ។ លោក សុខ អាន ប្រាប់ខ្ញុំថា ប្រសិនបើមានកិច្ចព្រមព្រៀងដែលត្រូវបញ្ចប់ ត្រូវតែឲ្យសច្ចាប័ន ។ ឥឡូវនេះខ្ញុំបានទទួលសារមួយច្បាប់ដែលប្រាប់ថាគ្មានវិធីណាដែលអាចផ្លាស់ប្តូរឬធ្វើវិសោធនកម្មទៅលើច្បាប់នេះបានឡើយ ។ យើងអាចកែសម្រួលបានបន្តិចបន្តួចដែរ ។

ប៉ុន្តែនេះមិនមែនជាបញ្ហាពិតប្រាកដទេ ។ បញ្ហាផ្តាច់ព្រ័ត្រគឺទាល់តែគំនិតទាំងមូលនៃអង្គជំនុំជម្រះត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងមួយរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ អង្គការសហប្រជាជាតិមិនអាចចូលទៅក្នុងកិច្ចព្រមព្រៀងបានទេ ពីព្រោះវានឹងបើកចំហឲ្យរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាផ្លាស់ប្តូរអ្វីគ្រប់ចំណុចដែលខ្លួនយល់ថាជាការសមរម្យសម្រាប់ថ្ងៃខាងមុខ ។ នេះមិនមែនជាផ្លូវដែលអង្គការសហប្រជាជាតិចូលក្នុងកិច្ចព្រមព្រៀងជាមួយរដ្ឋជាសមាជិក ។

***សំណួរ:*** តើលោកអាចជូនការវាយតម្លៃរបស់លោកទៅលើគុណភាពនៃយុត្តិធម៌ដែលប្រជាជនកម្ពុជាប្រហែលជាទទួលបានសព្វថ្ងៃនេះក្នុងខណៈដែលអង្គការសហប្រជាជាតិដកខ្លួនថយបែបនេះ?

***លោក ខូរេលៈ*** ខ្ញុំសូមនិយាយយោងទៅអ្វីដែលខ្ញុំបាននិយាយចុងក្រោយនេះថា សម្តេច ហ៊ុន សែន តែងតែមិនពេញចិត្តចំពោះភាពយឺតយ៉ាវដោយចេតនារបស់អង្គការសហ-ប្រជាជាតិ ។ សម្តេចមានប្រសាសន៍ថាប្រសិនបើអង្គការសហ-ប្រជាជាតិមិនទៅជាមួយទេ យើងនឹងធ្វើដំណើរទៅមុខដោយខ្លួនឯង ដោយមានការជួយឧបត្ថម្ភពីសំណាក់រដ្ឋនានាដែលចាប់អារម្មណ៍ក៏ថាបាន ។ ខ្ញុំមិនដឹងដែររឿងហ្នឹង ។

***សំណួរ:*** តើអ្វីទៅជាការព្រួយបារម្ភទៅលើរឿងខ្មែរក្រហមទាក់ទងនឹងភាពយឺតយ៉ាវនេះ? មេដឹកនាំខ្មែរក្រហមនឹងរត់គេចខ្លួន ឬកាន់តែមានវ័យចំណាស់ ឬស្លាប់?

***លោក ខូរេលៈ*** ដំណើរការនេះចេះតែបន្តទៅអស់រយៈពេលជាយូរមកហើយ ។ រដ្ឋាភិបាលកម្ពុជាបានព្យាយាមផ្តោតការយកចិត្តទុកដាក់ទៅលើអង្គការសហប្រជាជាតិដែលថា យើងមានភាពយឺតយ៉ាវមិនឆ្លើយតបឲ្យបានរហ័ស ។ តាមពិតមិនមែនអ៊ីចឹងទេ ។ យើងមានការព្រួយបារម្ភណាស់នៅក្នុងការវិវត្តន៍ចុងក្រោយនេះ ។ ខ្ញុំមិនដឹងប្រាកដដែរថា គេចង់មានន័យយ៉ាងដូចម្តេច ប៉ុន្តែយើងកត់សម្គាល់ថា មានគេដោះស្រាយបញ្ហានេះដោយចំណាយពេលយ៉ាងច្រើនចាប់តាំងពីយើងដកខ្លួនចេញកាលពីខែកក្កដា ឆ្នាំ២០០០មក ។

**អ្នកនាំពាក្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិៈ** សូមអរគុណច្រើន ។ យើងមានកាលប្បវត្តិរបស់អង្គការសហ-ប្រជាជាតិទាក់ទងនឹងរដ្ឋាភិបាលកម្ពុជាលើបញ្ហានេះ ដែលអស់លោក និងលោកស្រីអាចយកបាន ។ **វប្បៃដ អេកហាដ**

**(បកប្រែក្រៅផ្លូវការដោយ សួ ប៊ុនស៊ុ)**

# ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះបញ្ហាការដកថយរបស់អង្គការសហប្រជាជាតិ អំពីការបង្កើតតុលាការសម្រាប់ជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម

**ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២**

**សម្តេច ហ៊ុន សែនៈ** *...មកដល់ពេលនេះខ្ញុំមិនទាន់បានទទួលលិខិតផ្លូវការ ហើយក៏គ្រាន់តែបានស្តាប់សេចក្តីប្រកាសនានានៃសារពត៌មានតែប៉ុណ្ណោះ ។ Today I do not receive the official respond. I've just learned that from newspapers ហើយខ្ញុំគិតថា នេះមិនទាន់ហួសពេលដើម្បីនឹងធ្វើការកែប្រែសេចក្តីសម្រេចចិត្ត ប្រសិនបើវាអ៊ីចឹងមែន មិនទាន់ហួសពេលទេ ហើយទ្វាររបស់កម្ពុជាមិនទាន់បានបិទនៅឡើយទេ ។ ទ្វារនេះនឹងចំហរង់ចាំតទៅទៀត ។ If they is so, then I feel that it is not yet over time to change such decision and for the Cambodian side outdoor remains open all the time. ខ្ញុំបានដឹងថា មានប្រទេសមួយចំនួនដែលសមាជិកដ៏មានឥទ្ធិពលនៅក្នុងសហប្រជាជាតិដូចជា ជប៉ុន អាមេរិក បារាំង និងប្រទេសខ្លះទៀត កំពុងសម្តែងនូវការភ្ញាក់ផ្អើលចំពោះការសម្រេចចិត្តបែបនេះរបស់អគ្គលេខាអគ្គលេខារងអង្គការសហប្រជាជាតិ ។ Some in foreign countries are member of the United Nations like America, Japan, French, they are so expected their surprised to such decision made by General-Secretary and Under General Secretary of the United Nations. អ៊ីចឹងទេ ខ្ញុំអាចនិយាយបានថា ទ្វាររបស់កម្ពុជានៅចំហជាប់ជានិច្ច ហើយវិលមកស្អែកក៏បាន ខានស្អែកក៏បាន ខ្ញុំអាចរង់ចាំមួយខែឬពីរខែតទៅទៀត ។ Cambodian door remains open all the time and we would welcome them even tomorrow they after tomorrow and we can wait for them for even more two months. កម្ពុជាមិនដែលផ្តាច់ស្ពានជាមួយនរណាទេ ប៉ុន្តែបើគេផ្តាច់ស្ពានគឺរឿងរបស់គេ ។ ឥឡូវស្ពានមិនទាន់ដាច់ទេ ចាត់ទុកមិនទាន់ដាច់ ព្រោះខ្ញុំមិនទាន់បានទទួលនូវអ្វីក្រៅតែពីតាមសារពត៌មានតែប៉ុណ្ណោះ ។ Normally, Cambodian will never destroy the bridge. It's the other people that broke the bridge. But so far what I've received is just the reports in the newspapers not the official ones. ឥឡូវចាត់ទុកថាខ្ញុំអត់ទាន់បានដឹងរឿងនេះទៅចុះ ។ So just consider that I do not know this yet.*

**អ្នកកាសែតៈ** *...តើនៅក្នុងពេលនេះ តើខ្មែរអាចដំណើរការកាត់ទោសតែឯងបានទេ បាទ?*

**សម្តេច ហ៊ុន សែនៈ** *បញ្ហានេះ ខ្ញុំមិនទាន់ផ្តល់ចម្លើយទេ ប៉ុន្តែគេស្គាល់ជំហររបស់កម្ពុជាស្រេចទៅហើយ យើងមិនអាចទុកឲ្យរឿងខ្មែរក្រហមនេះដោយគ្មានការកាត់ទោសនោះទេ ហើយក៏មិនអាចរង់ចាំដោយគ្មានទីកំណត់នោះដែរ ប៉ុន្តែអាចត្រឹមពីរឬបីខែ យើងអាចរង់ចាំ ។*

**អ្នកកាសែតៈ** *....អាចកែប្រែលក្ខន្តិកៈដើម្បីឲ្យមានការសម្របសម្រួលគ្នាដែរ?*

**សម្តេច ហ៊ុន សែនៈ** *ច្បាប់គឺច្បាប់ ខ្ញុំមិនមានសិទ្ធិធ្វើបែបនោះទេ ។*

**អ្នកកាសែតបរទេសៈ** *If the UN did not change the decision (not clear) your own trial? ប្រសិនបើអង្គការសហប្រជាជាតិមិនប្តូរជំហររបស់គេ តើឯកឧត្តមធ្វើការកាត់ទោសដោយខ្លួនឯង?*

**សម្តេច ហ៊ុន សែនៈ** *អ្នកណាមកធ្វើជំនួសកម្ពុជាបានក្រៅពីកម្ពុជាធ្វើ? Who will do that on behalf of Cambodia, if not Cambodia? ប៉ុន្តែខ្ញុំមានការសង្ឃឹមថា អង្គការសហប្រជាជាតិនឹងវិលត្រឡប់មកដល់ទីនេះដើម្បីនឹងធ្វើការជាមួយយើង ។ But I still have the hope that the United Nations will come here and work with us. ហើយប្រសិនបើគ្មានការវិលត្រឡប់ទេ វាជាកំហុសរបស់សហប្រជាជាតិដែលមានពីដើមដល់ចប់ ។ If they do not return that repeated mistakes of the United Nations that they committed the start and the end. មានពីពេលដែលការគាំទ្រឲ្យខ្មែរក្រហមអង្គុយនៅកៅអីអង្គការសហប្រជាជាតិសម្លាប់ប្រជាជនកម្ពុជា ហើយបន្តអង្គុយនៅអង្គការសហប្រជាជាតិដើម្បីបន្តសម្លាប់ប្រជាជនកម្ពុជា និងរហូតមិនអាចធ្វើអីខ្មែរក្រហមបាន និងមកដល់ពេលនេះក៏មិនចូលរួមជាមួយនឹងដំណើរការកាត់ក្តី ។ The mistake is spread at the time they allowed the Khmer Rouge seated at the United Nations and continued to kill Cambodian people and later they could not treat the Khmer Rouge and until now if they deny to participate that is another mistakes. ខ្ញុំមិនចង់ឲ្យសហប្រជាជាតិធ្លាក់ទៅក្នុងផ្លូវខុសម្តងហើយម្តងទៀត ដែលវាជាភាពអាម៉ាស់នៃបណ្តាប្រទេសជាសមាជិកនោះទេ ឥឡូវបណ្តាប្រទេសជាសមាជិកកំពុងតែខិតខំឲ្យសហប្រជាជាតិវិលត្រឡប់ ។ I don't want the United Nations to fall into committing a mistake again. It is ashamed to many member countries and many member countries of the United Nations they are now trying to convince the United Nations. សហប្រជាជាតិមានសមាជិកជិតពីររយប្រទេស មិនមែនមនុស្សម្នាក់ឬពីរនាក់នោះទេ ។ The United Nations has members close to two hundred countries, not just one or two persons.*

**អ្នកកាសែតៈ** *...តើមានផលប៉ះពាល់អីទេនៅក្នុងប្រទេសដែលផ្តល់ជំនួយខាងមុខនេះ នៅពេលដែលអង្គការសហប្រជាជាតិដើរចេញ?*

**សម្តេច ហ៊ុន សែនៈ** *តើមានអីដែលគួរត្រូវខ្វាចត្រូវប៉ះពាល់ ព្រោះប្រទេសអ្នកផ្តល់ជំនួយនោះកំពុងតែខកចិត្តជាមួយសហប្រជាជាតិ មិនមែនខកចិត្តជាមួយកម្ពុជាឯណា ។ អឺ! អារឿងហ្នឹងវាអីចឹង អស់លោកមើលសារព័ត៌មានទៅឃើញហើយ ប្រទេសដែលផ្តល់ជំនួយធំៗដូចជាជប៉ុន ដូចជាបារាំង រាប់ទាំងអាមេរិកដែលមិនមែនអ្នកផ្តល់ជំនួយ ក៏មានការខកចិត្តចំពោះការសម្រេចរបស់សហប្រជាជាតិ ដូច្នេះគ្មានរឿងអីប៉ះពាល់ជាមួយនឹងបញ្ហានេះទេ ខ្ញុំគិតថា អីចឹង...មិនមែនជាកំហុសរបស់កម្ពុជា ។*

**អ្នកកាសែតៈ** *អង្គសហប្រជាជាតិ...រាជរដ្ឋាភិបាលកម្ពុជាមិនកាត់ទោសខ្មែរក្រហម...កាត់ទោសម្នាក់ឯងមែនទេ?*

**សម្តេច ហ៊ុន សែនៈ** *ត្រូវ! ព្រោះយើងមិនអាចនឹងទុកចោលរឿងហ្នឹងពាក់កណ្តាលទីទេ ។ ច្បាប់គឺត្រូវអនុវត្ត យើងនឹងរង់ចាំ ហើយប្រសិនបើគ្មានការចូលរួមរបស់សហប្រជាជាតិទេ យើងនឹងអញ្ជើញប្រទេសនានាដែលចង់ចូលរួមដើម្បីបញ្ជូនរដ្ឋអាជ្ញានិងចៅក្រមមកចូលរួមក្នុងដំណើរការក្តីនេះ ។ ច្បាប់គឺអនុញ្ញាតឲ្យយើងធ្វើយ៉ាងដូច្នេះ ព្រោះមិនមែនបានសេចក្តីថា សហប្រជាជាតិមិនចូលរួម យើងធ្វើមិនកើតនោះទេ ហើយបរទេសមិនចូលរួមនោះទេ ។ ប្រទេសមួយចំនួនអាចនឹងបញ្ជូនចៅក្រមនិងរដ្ឋអាជ្ញាមកកាន់ទីនេះ ។*

**អ្នកកាសែតៈ** *សម្តេច! មួយទៀតចុងក្រោយថា តើ តាម៉ុក និង ឌុច សម្តេចមានបានឲ្យឯកឧត្តម សុខ អាន រៀបចំនីតិវិធីសុំបន្តពន្ធនាគារទេ?*

**សម្តេច ហ៊ុន សែនៈ** *បញ្ហានេះគឺត្រូវតែធ្វើ ព្រោះថាខែ៣នេះផុតពេលកំណត់នៃការឃុំខ្លួន តាម៉ុក ហើយ ដូច្នេះជម្រើសល្អបំផុតរបស់យើងគឺស្នើច្បាប់ មិនមែនស្នើធ្វើវិសោធកម្មតទៅទៀតទេ ស្នើសេចក្តីព្រាងច្បាប់មួយដើម្បីបន្តឃុំពិរុទ្ធជនដែលជាប់ពាក់ព័ន្ធអំពីអំពើប្រល័យពូជសាសន៍និងប្រឆាំងមនុស្សជាតិនេះបន្តទៅទៀត ទម្រាំដល់ការបើកសវនាការកាត់ទោស ។*

**(ដកស្រង់ចេញពីទូរទស្សន៍ជាតិកម្ពុជាដោយៈ ឌ៉ាន់ថាន់ ពៅដារ៉ា)**

# សេចក្ដីដកស្រង់អំពីសន្និសីទការសែតឯកឧត្តម សុខ អាន នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ នៅសាលប្រជុំនៃទីស្ដីការគណៈរដ្ឋមន្ត្រីលើបញ្ហានៃការផ្ដាច់ការចរចារបស់អង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម



**ឯកឧត្តម សុខ អាន:** *ឥឡូវនេះខាង AP បានលើកឡើងនូវសំណួរពីរ គឺទីមួយសួរថា ដូចម្ដេចបានជានៅក្នុងដំណើរដែលយើងជជែកគ្នានៅក្នុងរដ្ឋសភា យើងអត់ផ្សាយនូវខ្លឹមសារនូវលិខិតទាំង១១ចំណុចនេះ ហើយទីពីរបើសិនយើងផ្ញើសម្បទានអីទេ ដើម្បីដែលយើងនិយាយថាចង់បានការចូលរួមរបស់អង្គការសហប្រជាជាតិ នេះដែលសង្ស័យថា អង្គការសហប្រជាជាតិចូលរួម ។ ចំណុចទីមួយដូចដែលនៅក្នុងសេចក្ដីថ្លែងការដែលសរសេរមិញនេះខ្ញុំបានលើកឡើងហើយ យើងថាយើងមាន "Gentlemen's Agreement" មួយរវាងខ្លួនខ្ញុំហើយនិងឯកឧត្តម ហេន ខូរេល ដែលនិយាយថា នៅក្នុងដំណើរការនៃការចរចាដើម្បីឲ្យងាយស្រួលទទួលលទ្ធផលនោះយើងមិនបាច់ផ្សព្វផ្សាយមិនបាច់ពន្យល់ពីជំហររបស់ខ្លួនទីមួយៗជាសាធារណៈទេ ។ បើពន្យល់ទៅគឺថា ម្នាក់ ការពារជំហរខ្លួន ម្នាក់ទៀតការពារជំហរខ្លួនដែរនាំឲ្យដំណើរការនៃការចរចាមិនអាចមិនបានលឿនទៅមុខ ។ អ៊ីចឹងនេះជាអ្វីដែលយើង ហៅថា "Gentlemen's Agreement" គេអត់ផ្សព្វផ្សាយហ្នឹងបានន័យថាជាការឯកភាពគ្នា បាទ ។*

*ដូច្នេះហើយបានជានៅក្នុងដំណើរការនៃការចរចានេះ យើងមិនបានគ្រោងទុក ក៏មិនបានពន្យល់ពីខ្លឹមសារនេះ ហើយនៅពេលនោះគឺហាក់ដូចជាឯកឧត្តម ហេន កូរេល ក៏មិនបានបញ្ចេញនូវខ្លឹមសារនៃការចរចានោះដែរ គឺថាយើងបានសម្បទានគ្នាទៅវិញទៅមក...ហើយយើងអត់បានផ្សព្វផ្សាយបញ្ហានេះជាសាធារណៈទេ ដូច្នេះដែលនិយាយនៅក្នុងរដ្ឋសភាជាសាធារណៈគឺក៏ខ្ញុំមិនបានបញ្ចេញគំនិតលម្អិតនៃការដែលយើងជជែកគ្នាដំបូង យើងទាស់គ្នាកន្លែងណា ហើយយើង...ក៏មិនបានបញ្ចេញថាយើងជជែកទៅវាយើងមានចំណុចកន្លែងណាមិនចុះសម្រុង ហើយយើងសម្របសម្រួលគ្នារបៀបម៉េច គឺយើងមិនបានបញ្ចេញទាំងអស់នោះទេ ។*

*ឯចំណុចទីពីរអំបាញ់មិញលោកតំណាងខាង AP បានសួរថា បានសង្ស័យថា....តើកម្ពុជាសម្បទានអីទៀតទេ ។ ថ្មីៗនេះខ្ញុំសុំបញ្ជាក់ថា ការដែលយើងឈានមកដល់បានសម្រេចអភិវឌ្ឍន៍ច្បាប់សម្រាប់ការកាត់ទោសនេះ នោះយើងបានឆ្លងកាត់ការសម្បទានច្រើនគន្លាក់រួចមកហើយទៅលើគោលការណ៍ធំៗដែលខ្ញុំសុំរំឭកឡើងវិញដូចតទៅនេះ ÷*

*ពីដំបូងឡើងគឺតាំងពីឆ្នាំ១៩៩៨ ដល់ក្រោយមកចរចា....គឺជំហរយើងទាំងពីរនៅឃ្លាតគ្នាឆ្ងាយណាស់ ហើយយើងបានឆ្លងការសម្របសម្រួលជាដំណាក់កាលធំៗដូចតទៅនេះ ទីមួយ ពីដំបូងឡើងគឺខាង UN បានលើកឡើងអំពីការបង្កើតតុលាការអន្តរជាតិមួយ ហើយកម្ពុជាបានលើកឡើងអំពីការបង្កើតតុលាការជាតិ ។ ដូច្នេះខុសគ្នាឆាយណាស់ ម្ខាងទាមទារតុលាការជាតិ ម្ខាងទាមទារតុលាការអន្តរជាតិ ប៉ុន្តែចុងក្រោយយើងបានឈានទៅដល់ដំណាក់កាលមួយសម្របសម្រួលដែលយើងនិយាយអំពីតុលាការជាតិ ប៉ុន្តែមានការចូលរួមពីចៅក្រមបរទេសដែលយើងហៅថា ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ បើយើងនិយាយភាសាអង់គ្លេសថា Extraordinary Chamber in the court of Cambodia. ។*

ហេតុដូចម្តេចបានយើងឈានទៅដល់រូបមន្តនោះ ព្រោះថានៅពេលនោះទាំងអស់គ្នាមើលឃើញថា ការបង្កើតតុលាការអន្តរជាតិគឺទៅមិនរួចទេ គឺធ្វើទៅមិនបាន ពីព្រោះនៅក្នុងកម្រិតអង្គការសហប្រជាជាតិក៏មានការលំបាកដែរ ក្រុមប្រឹក្សាសន្តិសុខដែរ ហើយចំពោះយើង យើងក៏ចង់បានការកាត់សេចក្តីមួយដែលទទួលស្គាល់ដោយមតិអន្តរជាតិដែលអាចនិយាយបានថា *Internationally Accepted Standard* ដូច្នេះយើងក៏ចង់បានអ៊ីចឹងហើយខាងអង្គការសហប្រជាជាតិក៏ចង់បានតុលាការមួយដែលមានលក្ខណៈអន្តរជាតិ ប៉ុន្តែដោយឃើញក្នុងក្របខ័ណ្ឌតុលាការអន្តរជាតិសុទ្ធសាធទៅមិនរួចទេ ដូចខ្ញុំលើកឡើងមិញអ៊ីចឹងមិនមែនមកពីកម្ពុជាទេ គឺមកពីអង្គការសហប្រជាជាតិបង្កើតមិនបានដែរ ដូច្នេះយើងបានឈានមកដល់ជំហររួម ដែលជំហររួមនោះគឺដែលយើងហៅថា អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការជាតិកម្ពុជានោះ ។

មកឈានដល់ដំណាក់កាលទី២នៃការសម្របសម្រួលនៃសម្បទាន គឺក្រោយពីបានឯកភាពគ្នាថា ឥឡូវបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញហើយ នោះគឺនៅជជែកគ្នាថា នរណាជាអ្នកដែលមាន *Majority* នរណាដែលត្រូវមានសម្លេងភាគច្រើនដែលកម្ពុជាក៏ចង់បានសម្លេងភាគច្រើន *UN* ក៏ចង់បានសម្លេងភាគច្រើន ។ ដូច្នេះទីបំផុតគឺយើងបានសម្របសម្រួលគ្នាក្នុងរូបមន្តមួយដែលឲ្យកម្ពុជាមានភាគច្រើន ចំនួនចៅក្រមភាគច្រើន ប៉ុន្តែការសម្រេចត្រូវសម្រេចតាមវិធីមួយដែលមិនដែលមាននៅក្នុងតុលាការ គឺភាពដែលគេហៅថា ភាគច្រើនលើសលុប *Supper Majority* រូបមន្ត *Supper Majority* គឺលើកឡើងដើម្បីជារូបភាពសម្បទានជាសម្បទានពីភាគីទាំងសងខាង ។

ក្នុងការសម្បទានទីបី...គឺ *UN* ចង់បានប្រពន្ធ័ *Common Law* កម្ពុជាចង់បានប្រព័ន្ធ *Romano Germanic* បានន័យថា មានចៅក្រមស៊ើបអង្កេតមួយ និងមានព្រះរាជអាជ្ញាមួយ ។ ខាង *UN* ចង់បានប្រព័ន្ធ *Common Law* គឺមានតែ *Prosecutor* មួយ ។ អ៊ីចឹង *Compromise* នៅកន្លែងណា ហើយ *Compromise* ធំទីបីគឺថា ឲ្យមានជាអ្នកដែល *Prosecutor* ផង ហើយឲ្យមានអ្នកដែលគេហៅថាចៅក្រមស៊ើបអង្កេតផង ហ្នឹងគេហៅថា *Three instructions investigating judge* ហើយវាមានមួយម្នាក់ដែរ គឺមាន *Co-investigating Judge* អាហ្នឹងជារូបភាពសម្បទានទាំងសងខាង ធ្វើសម្បទានទាំងសងខាងហើយបានចេញរូបភាពហ្នឹង ។

សម្បទានធំទីបួនគឺថា ក្រោយពីបានអ៊ីចឹងហើយលើកសួរថា បើ *Co-prosecutor* ម្នាក់ថាចោទប្រកាន់ ហើយម្នាក់ថាមិនចោទប្រកាន់ ហ្នឹងគឺថាពីរនាក់ហ្នឹងទាស់គ្នា យោបល់មួយទៀតតើត្រូវធ្វើយ៉ាងម៉េច? គឺយើងឯកភាពគ្នាបង្កើតអ្វីដែលហៅថា *Pre-trial chamber* ។ *Pre-trial chamber* អង្គបុរេជំនុំជម្រះ អាហ្នឹងក៏មិនដែលមានដែរនៅក្នុងតុលាការយើង តុលាការឯណាក៏មិនដែលមានដែរ ប៉ុន្តែយើងឯកភាពគ្នាបង្កើតដែលជារូបភាពនៃសម្បទានទាំងសងខាង ។

**ឯកឧត្តម សុខ អាន:** ហេតុដូច្នេះយើងបានធ្វើសម្បទានជាបន្តបន្ទាប់ ឥឡូវលោកសួរថា តើយើងត្រូវធ្វើសម្បទានអីទៀតទេ ហើយការសម្បបទាននេះគឺបានលើកឡើងគឺដំណើរការនៃការចរចារនេះយូរគឺដោយសារភាគីទាំងសងខាងត្រូវធ្វើសម្បទានគ្នាទៅវិញទៅមកអ៊ីចឹងហើយ ឥឡូវនេះសួរថា តើត្រូវធ្វើសម្បទានអ្វីទៀតទេ? ខ្ញុំយល់ថា វាមិនមែនជាពេលវេលាដែលត្រូវនិយាយគ្នាពីសម្បទានទេ ។

**អ្នកការសែត:** ឯកឧត្តម! ខ្ញុំមកពីទីភ្នាក់ងារព័ត៌មានក្យូដូជប៉ុន មូលហេតុដែលប្អូនចង់ដឹងច្បាស់លាស់ ហេតុអីបានអង្គការសហប្រជាជាតិបានឈានទៅដល់ការដកខ្លួន ឬមួយក៏ចម្លើយរបស់ដែលគេសរសេរខាងរដ្ឋាភិបាលយើង ខ្ញុំបានអាននូវអត្ថបទដំបូងរបស់លោក ហេន កូរេល ហ្នឹងគឺថា មានជិត១៨មាត្រាដែលបានឆ្លើយថា អ៊ីដែលរដ្ឋសភាជាតិអនុម័តនោះគឺមិនដូចគ្នាទៅនឹងអ៊ីនដែលភាគីទាំងពីរបានចរចាគ្នា ។ ដូច្នេះផ្តើមពីហេតុផលនេះឬបានអង្គការសហប្រជាជាតិបានដកខ្លួនចេញ ហើយទីពីរទៀតឯកឧត្តមបានមានប្រសាសន៍ថា យើងមិនមានសម្បទានអីតទៅទៀតទេ តើអ៊ីដែលសម្តេចនាយកលោកបានមានប្រសាសន៍ម្សិលមិញទ្វារកម្ពុជានៅបើកចំហ តើបើកចំហលើគោលការណ៍អី?

**ឯកឧត្តម សុខ អាន:** *សូមអត្ថាធិប្បាយទៅលើការពិចារណាថា ហេតុអ្វីបានជាអង្គការសហប្រជាជាតិដក ជាពិសេសឯកឧត្តម ហេន កូរេល ឈប់ចរចា ។ ខ្ញុំយល់ថា យើងមិនអាចយល់ពីទឹកចិត្តពិតប្រាកដរបស់គាត់បានទាំងអស់១០០ភាគរយបាននោះទេ ប៉ុន្តែគ្រាន់តែតាមការពិចារណារបស់ខ្ញុំគឺថា សព្វថ្ងៃនេះប្រហែលជាឯកឧត្តម ហេន កូរេល គាត់រវល់ការងារច្រើនពេក មានការងារមកពី Afganistan ការងារពិសេសការងារសេរ៉ាឡេអូន ដូច្នេះអាចថារវល់ការងារច្រើនពេក អ៊ីចឹងទៅគាត់អាចថាមិនសូវចាប់អារម្មណ៍ពីបញ្ហាកម្ពុជា ហើយនៅសួរទៀតថា តើនៅពេលដែលថាឈប់ហ្នឹងឯកឧត្តមបានលើកឡើងថាមកពីមានចំណុចច្រើនដែលមិនដូចគ្នានៅក្នុងការចរចា ច្បាប់នៃការចរចា ខ្ញុំសុំបញ្ជាក់ថានេះជាចំណុចសំខាន់ណាស់ដែលយើងត្រូវស្វែងយល់ឲ្យច្បាស់ ផ្អែកដូច្នេះហើយ មូលហេតុនេះហើយបានខ្ញុំចែកផ្សាយនូវលិខិតរបស់ខ្ញុំដែលផ្ញើជូនឯកឧត្តម ហេន កូរេល ពន្យល់គាត់ ពន្យល់អំពីចំណុចដែលលោកបានលើកឡើងនេះ អ៊ីចឹងនៅក្នុងលិខិតនេះ ដែលបានចែកផ្សាយនេះ គឺអស់លោកនឹងបានមើលទៅនឹងយល់ហើយថា ចំណុចអ្វីខ្លះដែលបានជាចំណុចទាក់គ្នា ហើយការពន្យល់របស់ក្រុមការងារ ជាពិសេសរបស់រាជរដ្ឋាភិបាល ដែលជូនលើចំណុចទាំងនោះតើវាសមរម្យឬទេ? បាទ វាសមស្របឬទេ? ហើយតើចំណុចវាធំគួរឲ្យកាត់ផ្តាច់ការចរចាទេ? ព្រោះអត់មានចំណុចអី ក្រៅពីហ្នឹងទៀតទេ ចំណុចចុងក្រោយមានតែប៉ុណ្ណឹង ។*

*ចំណុចទាំងនេះគឺអស់លោកនឹងយល់ថា តើវាជាចំណុចមួយធំដែលខុសគ្នាខ្លាំងរហូតដល់ផ្តាច់ការចរចាឬទេ? ខ្ញុំមើលឃើញថាវាអត់មានអីធំនឹងកើតដល់ទៅថាជាចំណែកដែលដោះស្រាយមិនបានទេ ហើយចំណុចដែលធំជាងគេនៅក្នុងលិខិតចុងក្រោយរបស់ឯកឧត្តម ហេន កូរេល គឺនិយាយអំពីរឿង Article cooperation ហើយនិងច្បាប់ដែលខ្ញុំបានអត្ថាធិប្បាយនៅក្នុងសេចក្តីផ្តើមរបស់ខ្ញុំនេះ សាច់រឿងហ្នឹងវាអត់មែនជារឿងផង ដូចខ្ញុំលើកអម្បាញ់មិញ វាអត់មែនជារឿង ហើយមិនមែនជាបញ្ហាចោទថា អត្ថបទណាធំជាងអត្ថបទណាទៀត ព្រោះតាមគោលការណ៍យើងយល់ហើយ ។ បើកាលណារដ្ឋមួយចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិហើយ គឺអត្ថបទនោះគឺជាអត្ថបទដែលមានឧត្តមភាពបំផុត ប៉ុន្តែចំណុចដែលខ្ញុំលើកឡើងនោះគឺថា អាអត្ថបទពីរហ្នឹងវាអត់មានស្អីដែលត្រូវទំនាស់គ្នាឲ្យទៅជាជជែកគ្នាថា អាណាត្រូវឧត្តមភាពលើអាណាផង ពីព្រោះដូចខ្ញុំបានលើកឡើងមិញអ៊ីចឹង យើងមិនមានផលប្រយោជន៍អីនឹងទៅធ្វើច្បាប់មួយដែលឆ្លងកាត់រដ្ឋសភា ឆ្លងកាត់អង្គការនីតិបញ្ញត្តិរបស់រដ្ឋ របស់ព្រះរាជាណាចក្រ ហើយបានហើយយើងមកធ្វើកិច្ចព្រមព្រៀងមួយ ឬមួយយើងហៅថា មាត្រាឬក៏មូលដ្ឋាននៃកិច្ចសហប្រតិបត្តិការឲ្យខុសពីហ្នឹងដុយពីហ្នឹង ឲ្យទៅលុបច្បាប់ហ្នឹងវិញនោះទេ ។ ដូច្នេះវាអត់មានផលប្រយោជន៍អីត្រូវធ្វើអ៊ីចឹង ។ ដូច្នេះហើយបានខ្ញុំលើកឡើងថា អត្ថបទពីរហ្នឹងវាមានគោលដៅខុសគ្នា ។ អត្ថបទមួយគឺជាច្បាប់មូលដ្ឋាននៃការកាត់ទោស អត្ថបទមួយគឺជាច្បាប់មូលដ្ឋាននៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងអង្គការសហប្រជាជាតិ ។ ដូច្នេះច្បាប់ពីរហ្នឹងវាមានអីមិនជាន់គ្នា វាមានអីនឹងត្រូវតែលុបគ្នាទៅវិញទៅមកឯណា វាបំពេញគ្នាទៅវិញទៅមកទេ ។ អ៊ីចឹងទស្សនីយកិច្ចនៅក្នុងនេះគឺអស់លោកឯកឧត្តម អស់លោកនឹងមើលឃើញថា វាអត់មានរឿងអីដែលថាវាជ្រៅជ្រះដែលវាលំបាកស្មុគស្មាញរហូតដល់ត្រូវកាត់ផ្តាច់ការចរចានោះទេ ។*

*....ដូច្នេះហើយបានជាយើងសួរទៀតថា ហេតុដូចម្តេចបាននិយាយថាច្បាប់ហ្នឹងអត់ដូចការចរចា ចម្លើយរបស់ខ្ញុំគឺថាយើងពិនិត្យមើលនូវអត្ថបទនូវសំបុត្រដែលឆ្លងឆ្លើយចំណុចដែលទាក់គ្នា ខាងក្រោយវាអត់មានស្អីដែលខុសគ្នាដូចដែលគេនិយាយអ៊ីចឹងទេ ។ វាអត់មានស្អីដែលខុសគ្នាធំជាមូលដ្ឋាននោះទេ ។...អាចសម្របសម្រួលអាចចរចាគ្នាបាន ហើយចំណុចមួយទៀតសួរថា សម្តេចលោកនាយករដ្ឋមន្ត្រីលោកលើកឡើងថា ទ្វារនៅចំហ បាទ នេះជាជំហររាជរដ្ឋាភិបាល គឺថាយើងត្រូវតែបញ្ជាក់ថា ទ្វារនៅតែចំហ ប៉ុន្តែហេតុដូចម្តេចបានយើងនិយាយថា អត់មាន Concession ឥឡូវនេះគឺមិនមែនជាពេលវេលានិយាយពី Concession អម្បាញ់មិញពាក្យរបស់ខ្ញុំ នៅពេលដែលខ្ញុំពន្យល់អំពីសម្បទានខ្ញុំលើកឡើងថា សម្បទានមិនមែនជាអ្វីដែលត្រូវធ្វើដោយឯកតោភាគីទេ អ៊ីចឹងហើយមិនមានន័យថា ទាល់តែនិយាយអំពីសម្បទានបានទ្វារបើកនោះទេ អ៊ីចឹងគឺទ្វារនៅតែចំហ គ្រាន់តែយើងនៅតែ*

ត្រៀមបន្តការចរចាជានិច្ច គឺត្រៀមបន្តការចរចាជានិច្ចដើម្បីនិងធ្វើឲ្យសម្រេចឡើងនូវគោលដៅនេះ គោលដៅនេះគឺអី គឺការបង្កើតឡើងនូវអីដែលយើងហៅថា Extraordinary Chamber នេះ នោះជាគោលដៅ ដូច្នេះយើងនៅតែត្រៀមដើម្បីបន្តការចរចាជាមួយនឹង UN ហើយដើម្បីសម្រេចនូវគោលដៅនៃការបង្កើត Extraordinary Chamber នេះឯង ។

ដូច្នេះខ្ញុំសុំឆ្លើយនឹងសំណួរដូចតទៅនេះ ទីមួយសួរថាអាណឹងវា Stalemate អីមែនទេ? ខ្ញុំថាបើនិយាយពីដំណើរការចរចា ពីដំណើរការចរចា បើខាង...អាណឹងជា Stalemate ប៉ុន្តែយើងនិយាយពីអី និយាយពីការបង្កើតតុលាការ និយាយពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ អីចឹងវាមិនមែនជា Stalemate សម្រាប់ការបង្កើតតុលាការនោះទេ នឹងនាំឲ្យបង្កើតអង្គជំនុំជម្រះនោះទេ ប៉ុន្តែឥឡូវនេះក៏វាឆាប់ពេកដែរ ដែលយើងត្រូវនិយាយថាត្រូវធ្វើយ៉ាងណានោះ ចំណុចនេះយើងនឹងនិយាយនៅថ្ងៃក្រោយ បើសិនណាជាគ្មានការចូលរួមពីអង្គការសហប្រជាជាតិនោះ អាណឹងយើងត្រូវធ្វើម៉េចទេ ខ្ញុំមិនចង់និយាយឥឡូវទេ ឥឡូវនេះយើងគ្រាន់តែចង់បញ្ជាក់ថាបើនិយាយពីការចរចា បើម្ខាងអត់ចរចា អាណឹង Stalemate ហើយប៉ុន្តែវាមិនមែនជា Stalemate សម្រាប់គោលដៅចុងក្រោយនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះទេ អីចឹងសួរថាធ្វើម៉េច? ខ្ញុំគិតថា ឥឡូវនេះដូចជាពេលឆាប់ខ្លាំងពេកហើយ បើយើងនិយាយអំពីថាតើត្រូវធ្វើម៉េចនោះ អាណឹងយើងត្រូវបន្តការពិចារណាបន្តការពិគ្រោះយោបល់ពីមិត្តភក្តិជិតឆ្ងាយរបស់យើងទៀតថា តើយើងត្រូវធ្វើម៉េច?

ចំណុចមួយទៀតសួរថា តើមានប្រទេសណាសន្យាថាជួយយ៉ាងម៉េចអីម៉េច ខ្ញុំយល់ថាអស់លោកឯកឧត្តម លោក លោកស្រីជ្រាបហើយថា មកដល់ពេលនេះមានប្រទេសមិត្តភក្តិមួយចំនួន ជាពិសេសគឺប្រទេសដែលសំខាន់ៗ ចាប់អារម្មណ៍ខ្ពស់ពីការកាត់ទោសនេះ គេបានប្រកាសគាំទ្រជំហររបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការដែលយើងសម្តែងឆន្ទៈបន្តការចរចា បានន័យថា គេមិនចង់ឲ្យមានការផ្តាច់ការចរចាឯកតោភាគីនោះទេ ។ យើងខ្ញុំនឹងចែកជូននូវការដកស្រង់សេចក្តីថ្លែងការរបស់ប្រទេស នឹងចែកជូន ។ ...ហើយខ្ញុំក៏ជឿថាប្រហែលជាមិនទាន់ដល់ពេលដែលយើងត្រូវពិគ្រោះគ្នាថាត្រូវយកវិធានការយ៉ាងម៉េចនោះទេ ។ អាចថាយើងត្រូវការពេលវេលាបន្តិចទៀតដើម្បីយើងជំហរពីបញ្ហានេះ ។

**អ្នកកាសែត:** ភ្ជាប់នឹងសម្តីប្រសាសន៍របស់ឯកឧត្តម វាហាក់បីដូចជារហ័សពេកដែលត្រូវធ្វើយ៉ាងម៉េច ហើយនិងត្រូវការពេលវេលាដើម្បីដូចថាបើមានការសម្តែងនូវការព្រួយបារម្ភអំពីវ័យចំណាស់របស់ជនសង្ស័យដែលជាប់ពាក់ព័ន្ធទៅនឹងរឿងប្រល័យពូជសាសន៍ ហើយនិងការតួញត្អែរបស់មេធាវីរបស់ជនសង្ស័យដែលបានជាប់នៅក្នុងពន្ធនាគា ដូចជា តាឌុច ហើយនិងតាម៉ុក តាម៉ុកហ្នឹងគឺថាតើរាជរដ្ឋាភិបាលមានគម្រោងដើម្បីបង្កើតតុលាការកាត់ទោសឲ្យបានឆាប់ឬក៏រក្សានៅពេលប៉ុន្មានឆ្នាំទៀត?

**ឯកឧត្តម សុខ អាន:** អីចេះខ្ញុំជម្រាបថា សុំប្រែសំនួរជាអង់គ្លេស... បញ្ហានេះ ពាក្យដែលខ្ញុំនិយាយថាពាក្យដែលឆាប់ពេកនេះមិនមានន័យថាវង់ចាំដល់ទៅរាប់ខែរាប់ឆ្នាំនោះទេ ពាក្យឆាប់ពេកនេះប្រហែលជា....អាចថាផ្សេងៗ ហ្នឹងយើងត្រូវពេលវេលាតែប៉ុន្មានថ្ងៃប៉ុន្មានអាទិត្យនោះទេដើម្បីមើលជំហរ ហើយយើងខ្ញុំយល់ហើយថា មិនយូរដល់រាប់ខែរាប់ឆ្នាំនោះទេ បើមើលតែខាងជំហរនោះអាណឹងរាប់ថ្ងៃឬរាប់អាទិត្យទៅ ហើយកាលដែលសំខាន់ហ្នឹងគឺមានមាត្រា៤៦ ច្បាប់បានចែងអំពីអាដែងចំណុចនេះដែរ ។

**អ្នកកាសែត:** ខ្ញុំមកពីក្យូដូ ឯកឧត្តមសុំបន្តទៀតចំពោះទាក់ទងឯកឧត្តមអាចជម្រះមន្ទិលសង្ស័យពីមជ្ឈដ្ឋានជាតិយើងខ្លះថាការដកខ្លួនរបស់ UN វាទៅជាសេចក្តីជោគជ័យរបស់រដ្ឋាភិបាលទៅវិញ ពីព្រោះរដ្ឋាភិបាលដែលមកពីគណបក្សកាន់អំណាចនោះថាមិនមានចេតនាឲ្យមានការបង្កើតឲ្យមានការបង្កើតតុលាការទេរហូតដល់ក្រោយបោះឆ្នោត២០០៣នេះ ។

**ឯកឧត្តម សុខ អាន:** ខ្ញុំយល់ថានេះជាការបកស្រាយមិនត្រឹមត្រូវពីការពិតនោះទេ អ្វីដែលយើងចង់បានដូចខ្ញុំបានបញ្ជាក់តាំងពីដើមមក គឺថាយើងចង់បានចង់បានការមួយដែលគេហៅថាមាន Standard internationally accepted standard បានន័យថា

មានគំនិតមួយដែលទទួលស្គាល់ ហើយយើងក៏បាននិយាយតាំងពីមុនម៉ោហើយ បើយើងមិនចង់ឲ្យមានតុលាការមិនចំណាយពេលវេលា បាទ មិនចំណាយការខិតខំ មិនចំណាយអាដែងអ្វី...លុយកាក់ ប្រាក់កាក់ដើម្បីធ្វើការប្រជុំនោះទេ ព្រោះថាកិច្ចការងារនេះទោះបីតិចឬច្រើនយើងត្រូវចំណាយលុយ ចំណាយថវិកា ហើយយើងចំណាយពេលវេលាខិតខំ អ៊ីចឹងវាបើយើងមិនចង់បានយើងទុកពេលវេលាដើម្បីយើងធ្វើការងារដែងខាងការអនុវត្តកម្មវិធីនយោបាយយើងមានច្រើនណាស់ ការកែទម្រង់មានច្រើនបែបយ៉ាងណាស់ ការកសាងសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ គឺកម្មវិធីរាជរដ្ឋាភិបាល របស់យើងមានច្រើនណាស់ ការងារដែលយើងត្រូវធ្វើមានច្រើនណាស់ បើយើងមិនចង់បានម៉េចចំណាយពេលវេលាដើម្បីធ្វើធ្វើអី អ៊ីចឹងអ៊ីដែលយើងបានខិតខំអស់នេះគឺយើងបញ្ជាក់ច្បាស់ថា រាជរដ្ឋាភិបាលចង់បានឲ្យមានតុលាការនេះ អ្នកដែលនិយាយហ្នឹងគាត់បេះតែថាទៅ អ៊ីចឹងហើយដូចដែលខ្ញុំលើកពីមុនអ៊ីចឹង ដោយចេញពីគោលដៅហ្នឹងហើយបានយើងឈានទៅដល់មានការសម្បទាននឹងគ្នាជាជំហានៗនោះនេះជានយោបាយ ជាគោលដៅរបស់រាជរដ្ឋាភិបាល ។

**អ្នកកាសែត:** ឯកឧត្តមបានមានប្រសាសន៍ថា សម្បទានមិនមែនជាអ៊ីដែលធ្វើដោយឯកតោភាគីទេ បើសិនជាខ្ញុំអាចបកស្រាយជាភាសានេះបាន បានន័យថាឯកឧត្តមទន្ទឹងឬក៏ចង់បានឲ្យអង្គការសហប្រជាជាតិនេះក៏ធ្វើសម្បទានខ្លះដែរដើម្បីឲ្យមានដំណើរការចរចាឡើងវិញ តើ Specific ហ្នឹងតើអ៊ីដែលឯកឧត្តមចង់ឃើញឲ្យអង្គការសហប្រជាជាតិធ្វើជាសម្បទានដើម្បីឲ្យដំណើរការចរចានេះរស់ឡើងវិញ បាទ?

**ឯកឧត្តម សុខ អាន:** ខ្ញុំមិនទាន់បានគិតពីរឿងនោះទេ ឥឡូវនេះគឺអ៊ីដែលការគិតគូរចម្បងគឺថាការកំណត់ជំហរថាយើងចង់បន្តការចរចា យើងនៅរក្សាទ្វារចំហ ហើយដំណើរការធំនេះ ថាតើអាចថាអង្គការសហប្រជាជាតិប្រកាន់ជំហរ...។ អម្បាញ់មិញគឺថា....បានសួរថាតើយើងមានជំហរយ៉ាងណាដែលចំពោះការដែលមានអ្នកការពារ បានន័យថាមេធាវី តើមាន...ចំណុចនេះជាចំណុចមួយសំខាន់នៃការចរចា ប៉ុន្តែខ្ញុំយល់ថា បើយើងពិនិត្យចំណុចនេះគឺយើងឃើញជំហរជាវិជ្ជមានរបស់ព្រះរាជាណាចក្រកម្ពុជាលើបញ្ហានេះ ។ នៅក្នុងអត្ថបទច្បាប់ដែលខ្ញុំបានចែកជូនជាភាសាអង់គ្លេសហើយនេះ ចែកជូនអស់លោក-លោកស្រីមុនហ្នឹងឃ្លានិយាយអំពី និងឃើញមានការនិយាយអំពីថាការដែលរដ្ឋាភិបាលរកមេធាវីឲ្យចុងចោទ ប៉ុន្តែនៅក្នុងច្បាប់នេះមិនបានហាមមិនឲ្យមានមេធាវីបរទេសទេ ។

ដូច្នេះគឺនៅក្នុងការអនុវត្តន៍គឺគេអាចអនុវត្តច្បាប់ផ្ទៃក្នុងប្រទេស ហើយច្បាប់ផ្ទៃក្នុងប្រទេសគឺបាននិយាយអំពីមេធាវីបរទេស ។ បើលោកសិក្សាអំពីលក្ខន្តិកៈរបស់គណៈមេធាវីនោះនឹងឃើញថា ក្នុងច្បាប់នោះគេអនុញ្ញាតឲ្យមេធាវីបរទេសគឺអាចមកការពារកូនក្តីនៅក្នុងព្រះរាជណាចក្រកម្ពុជាបាន ដោយគេសហការជាមួយមេធាវីខ្មែរ ។ ប៉ុន្តែគេមានរបៀបរបបនិងវិធីធ្វើការ...គឺចំណុចត្រង់នេះដែលច្បាប់មានលក្ខណៈបើកទូលាយជាងច្បាប់នៅក្នុងប្រទេសជាច្រើន ។ ដូចលោកជ្រាបហើយ មានប្រទេសជាច្រើនណាស់ដែលជឿនលឿនជាងយើងដែលគេមិនអនុញ្ញាតឲ្យមេធាវីបរទេសទៅការពារកូនក្តីនៅប្រទេសគេទេ ។ ក៏ប៉ុន្តែនៅកម្ពុជា ច្បាប់យើង យើងបានអនុញ្ញាតរួចហើយ ។ ដូច្នេះច្បាប់នេះវាទូលាយជាងច្បាប់នៅក្នុងប្រទេសមួយចំនួនធំ ។

គួរលោកសិក្សាច្បាប់ Bar Association ដែលគេនិយាយអំពីរបៀបរបបដែលមេធាវីបរទេសត្រូវធ្វើការសហការជាមួយមេធាវីខ្មែរ...ខ្ញុំចង់បញ្ជាក់ចំណុចនេះ គឺថាច្បាប់យើងទូលាយបើកចំហនិងមានលក្ខណៈវិជ្ជមានជាងច្បាប់នៅក្នុងប្រទេសដែលខ្ញុំនិយាយថា ជាប្រទេសដទៃនោះច្រើនណាស់ ។ នៅប្រទេសជឿនលឿនមួយចំនួនធំ គេបានហាមឃាត់មិនឲ្យមេធាវីបរទេសទៅការពារកូនក្តីទេ ។

**អ្នកកាសែត:** ឯកឧត្តម! ខ្ញុំមកពីខាងទូរទស្សន៍ជាតិកម្ពុជា ខ្ញុំមានសំណួរ៣ៈ ទី១ តើឯកឧត្តមសង្ឃឹមថាអង្គការសហប្រជាជាតិនឹងសម្រេចចិត្តសារជាថ្មីដែរឬទេ? ទី២ តើការដកខ្លួនរបស់អង្គការសហប្រជាជាតិរួចហើយនោះ តើកម្ពុជាអាចរៀបចំ

ដំណើរការកាត់ទោសខ្មែរក្រហមដោយខ្លួនឯងដែរឬទេ ហើយសំណួរទី៣ តើឯកឧត្តមយល់យ៉ាងណាដែរចំពោះបន្ទូលរបស់សម្តេចក្រុមព្រះដែលថា បើគ្មានអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិប្រទេសកម្ពុជាយើងមិនអាចរៀបចំដំណើរការកាត់ទោសមួយប្រកបដោយការជឿទុកចិត្តបានទេ?

**ឯកឧត្តម សុខ អាន:** ចំពោះសំណួរទី១ ខ្ញុំយល់ថា សារពត៌មានគឺ.....ហើយសួរថាតើយើងអាចកាត់សេចក្តីដោយខ្លួនយើងបានដែរឬទេនោះ ខ្ញុំយល់ថាយើងគួរពិនិត្យមាត្រា៤៦ ។ នៅក្នុងមាត្រា៤៦ នេះបានចែងច្បាស់អំពីដំណើរការ ប្រសិនណាជាមានការដកខ្លួននោះច្បាប់នឹងអនុញ្ញាតឲ្យធ្វើយ៉ាងណា ។ អ៊ីចឹងហើយឃើញថា វាមិនអាចដូចដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញ វាមិនមែនជា Stalemate សម្រាប់ដំណើរការកាត់ទោស គ្រាន់តែឥឡូវនេះគឺវាលឿនពេក បើយើងនិយាយអំពីដំណើរការបន្តិចទៀតយើងដល់ពេលនិយាយរឿងហ្នឹង ហើយយើងមិនទុកអូសបន្លាយដល់រាប់ខែរាប់ឆ្នាំដូចសំណួរខាងដើមនោះទេ អ៊ីចឹងគឺក្នុងរយៈពេលឆាប់នេះគឺយើងនឹងពិចារណាថាយើងនឹងត្រូវធ្វើយ៉ាងណាឲ្យភាពដំណើរការនេះយ៉ាងម៉េច ប៉ុន្តែអ្វីដែលខ្ញុំបញ្ជាក់ជូនបានឥឡូវគឺថា វាអត់មានការទាល់ច្រកសម្រាប់ការកាត់ទោសទេ ។

អំពីសំណួរថាទាល់តែមានការចូលរួមពីអង្គការសហប្រជាជាតិនោះទើបមានការកាត់ទោសមួយ...(ម្ចាស់សំណួរបញ្ជាក់: បើគ្មានអង្គការសហប្រជាជាតិ គ្មានការកាត់ទោសមួយដែលអាចទុកចិត្តបាន) ខ្ញុំជឿថា អ្វីដែលខ្ញុំបាននិយាយពីខាងដើមគ្រាន់តែប៉ុណ្ណេះទេ គ្រាន់ថាខ្ញុំចង់បានអ្វីដែល Internationally accepted standard បើមានការចូលរួមពីអង្គការសហប្រជាជាតិនោះ យើងនឹងមានអំណោចផលដល់អ្វីដែលយើងថា Internationally accepted standard ស្តង់ដាមួយដែលអន្តរជាតិទទួលស្គាល់...ប៉ុន្តែមិនមានន័យថាយើងធ្វើអ្វីៗមិនបាននោះទេ ។ យើងបានលើកតាំងពីដើមទីមកហើយថា ដំណើរការកាត់ទោសនេះយើងផ្អែកទៅលើគោលការណ៍៣: ទី១គឺគោលការណ៍អធិបតេយ្យភាពជាតិ ទី២គឺគោលការណ៍រក្សាស្ថេរភាពជាតិ រក្សាការបង្រួបបង្រួមជាតិ ហើយទី៣គឺគោលការណ៍យុត្តិធម៌ដល់ជនរងគ្រោះ ។ យើងតែងតែពុះហើយគោលទាំងបីនេះ ដូច្នេះមិនមានអ្វីយើងថាគ្មានការចូលរួមកាត់ទោសមិនបាននោះទេ ។ បើយើងចង់បាន International standard យើងក៏ចង់មាន Internationally accepted standard... អ៊ីចឹងគឺអ្វីដែលយើងនិយាយថា ទាល់តែមានការចូលរួមរបស់អង្គការសហប្រជាជាតិបានយើងធ្វើកើតនោះទេ បើគ្មានក៏យើងធ្វើកើតដែរ ប៉ុន្តែបើយើងចង់បាន Internationally accepted standard គឺយើងចង់ឲ្យមានការចូលរួមពី UN ។

**(កំណត់ហេតុដោយ រ៉ា នៃរ៉ាន់ និង ខ៊ាន់ថាន់ ពៅដារ៉ា)**



# ការរំសាយចិត្តនិងការផ្សះផ្សា

នៅក្នុងវចនានុក្រមអង់គ្លេស បន្សុទ្ធកម្មនៃសតិអារម្មណ៍ មានន័យថា ជាបន្សុទ្ធកម្មតាមរយៈសិល្បៈកម្សាន្តគឺជាបន្សុទ្ធកម្មមួយដែលនាំមកនូវភាពស្រស់បស់ឡើងវិញខាងផ្លូវចិត្ត ឬនាំមកនូវការបន្ថយភាពតានតឹងក្នុងអារម្មណ៍ ។ ចំណែកពាក្យថា ការផ្លាស់ប្តូរដែលនាំឲ្យមានអារម្មណ៍ធូរស្រាលមានន័យថា ជាបន្លាស់ប្តូរភ្លាមៗដែលគួរឲ្យកត់សម្គាល់និងដែលគួរឲ្យភ្ញាក់ផ្អើល ។ ពោលគឺបន្លាស់ប្តូរដែលធ្វើឲ្យមនុស្សម្នាក់ទទួលបាននូវទស្សនៈថ្មីសន្លាងមួយចំពោះពិភពលោក ឬចំពោះស្ថានភាពបច្ចុប្បន្នដែលបុគ្គលនោះកំពុងជួបប្រទះ ។ មិនតែប៉ុណ្ណោះ ការផ្លាស់ប្តូរបែបនេះមានឥទ្ធិពលធ្វើឲ្យមនុស្សម្នាក់មានអារម្មណ៍កាន់តែប្រសើរឡើង ។ ជាក់ស្តែង អ្នកខ្លះយល់ថាការវាយប្រហារទៅលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកបង្កើតឲ្យមាន“ការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកត់សម្គាល់” នៅក្នុងនយោបាយដឹកនាំរបស់សហរដ្ឋអាមេរិក និងទៅលើទស្សនវិស័យរបស់ប្រពលរដ្ឋអាមេរិក ដែលជាហេតុធ្វើឲ្យប្រជាជនទាំងនោះយល់ថា ដំណោះស្រាយតែមួយគត់ដើម្បីកុំឲ្យមានការភ័យខ្លាចភេរវកម្ម គឺការធ្វើសង្គ្រាមជាមួយភេរវករនៅកន្លែងដែលខ្លួនរស់នៅ ។

ឧទាហរណ៍មួយទៀតគឺនៅក្នុងចិត្តិកិច្ចា (ការប្រើប្រាស់ក្បួនចិត្តសាស្ត្រដើម្បីព្យាបាលជំងឺផ្លូវចិត្ត) ។ សន្មតថាមានអ្នកជំងឺម្នាក់ដែលកំពុងមានជំងឺបាក់ទឹកចិត្តនិងភាពងឿងឆ្ងល់ បានចូលមកពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតចិត្តសាស្ត្រម្នាក់ ។ បន្ទាប់ពីមានការពិគ្រោះអំពីអាការៈជំងឺរួចមក អ្នកជំងឺនោះស្រាប់តែនឹកឃើញថា ការគាត់ចេះតែព្រួយបារម្ភគឺបណ្តាលមកពីបញ្ហាមួយចំនួនដែលគាត់ធ្លាប់ជួបប្រទះកាលនៅវ័យកុមារ ។ ប៉ុន្តែករណីនេះមិនមានឥទ្ធិពលអ្វីទៅលើរូបគាត់ទៀតទេនៅពេលបច្ចុប្បន្ន ។ ដូច្នេះគាត់ក៏មានអារម្មណ៍ធម្មតាឡើងវិញ ហើយរស់នៅដោយសប្បាយរីករាយ ។ ការដឹងខ្លួនបែបនេះអាចហៅថា “ការផ្លាស់ប្តូរដែលនាំឲ្យមានអារម្មណ៍ធូរស្រាល” ។

ក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជាវិញ ជាទូទៅអាចនិយាយបានថា ប្រជាជនខ្មែរភាគច្រើននៅតែរងឥទ្ធិពលពីខ្មែរក្រហមនៅឡើយ ។ ក្រុមយើងមួយចំនួនដែលបានធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាសព្វថ្ងៃនេះ បាននិងកំពុងតែទាញហេតុផលជាច្រើនឆ្នាំមកហើយថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងនាំមកនូវការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកត់សម្គាល់ជាមិនខាន ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងក្លាយជាព្រានដ៏ធំមួយសម្រាប់វាយបំបាក់“វប្បធម៌នៃភាពរួចទោស” និងផ្តល់ឲ្យជនរងគ្រោះភាគច្រើននូវភាពធូរស្បើយក្នុងអារម្មណ៍ ព្រមទាំងបង្ហាញដល់មហាជននូវហេតុការណ៍សម្ងាត់ផ្សេងៗជុំវិញអំពើប្រល័យពូជសាសន៍ ជាពត៌មានដែលប្រជាជនកម្ពុជាមិនបានដឹងពីមុនមក ។ ការដឹងពត៌មានចេញពីតុលាការនេះនឹងក្លាយជាការរំសាយផ្លូវចិត្តសម្រាប់អ្នកដែលកំពុងតែទទួលផលប៉ះពាល់ពីអំពើប្រល័យពូជសាសន៍ ។ ករណីនេះនឹងចូលទៅក្នុងករណីមួយហៅថា “ការពិតអាចធ្វើឲ្យអ្នកមានអារណ៍ធូរស្បើយលែងខ្វល់ខ្វាយ” ។

មជ្ឈមណ្ឌលឯកសារកម្ពុជាតែម្នាក់ឯងពុំអាចនាំមកនូវ “ការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យភ្ញាក់ផ្អើល”មួយសម្រាប់ប្រទេសកម្ពុជាទាំងមូលបានទេ ។ ផ្ទុយទៅវិញ កិច្ចការជាច្រើនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែអនុវត្ត អាចមានឥទ្ធិពលទៅលើប្រជាជនកម្ពុជាក្នុងទ្រង់ទ្រាយតូចមួយតែប៉ុណ្ណោះ ។ ជាក់ស្តែង ការងារស្វែងរកគ្រួសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់នូវការបន្ធូរអារម្មណ៍សម្រាប់បុគ្គលមួយចំនួនដែលបានទទួលពត៌មានទាក់ទងនឹងវាសនារបស់សាច់ញាតិរបស់ខ្លួន ។ ក្នុងឆ្នាំកន្លងទៅ ជនជាតិខ្មែរកាត់បារាំងម្នាក់មកពីប្រទេសស៊ុយអែដជាមួយម្តាយជាជនជាតិបារាំង បានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្វែងរកស្វាមីនិងឪពុករបស់ខ្លួនដែលជាអ្នកការទូតជនជាតិខ្មែរម្នាក់ត្រូវបានបានបាត់ខ្លួននៅក្នុងសម័យបដិវត្តខ្មែរ

ក្រហម ។ ជាង១ភាគ៤នៃទសវត្សរ៍ទៅហើយដែលអ្នកម្តាយ និងកូនមានមន្ទិលសង្ស័យ មានការព្រួយបារម្ភ និងមានភាពមិនប្រាកដប្រជាថាតើមានអ្វីកើតឡើងចំពោះស្វាមីនិងឪពុក ក្រោយពីគាត់វិលមកកម្ពុជាវិញដើម្បីកសាងប្រទេសជាតិ ។ អ្វីដែលអ្នកទាំងពីរបានដឹងគឺស្វាមីនិងឪពុកបានបាត់ស្រមោលឈឹងតែម្តង ។ ប៉ុន្តែឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ការពិតគាត់ត្រូវបានបញ្ជូនមកសម្លាប់ចោលនៅមន្ទីរស-២១ (គុកទួលស្លែង) ។ ក្រោយពីកូននិងម្តាយដឹងរឿងពិតអស់ហើយ អ្នកទាំងពីរពិតជាទទួលអារម្មណ៍ភ្លាមៗ និងគួរឲ្យកត់សម្គាល់នៅក្នុងឆាកជីវិតរបស់គាត់ ។ តាមពិតទៅអ្នកទាំងពីរមិនសប្បាយចិត្តចំពោះការជួបប្រទះពត៌មានបែបនេះទេ ក៏ប៉ុន្តែការដឹងប្រសើរជាងការមិនដឹង ។ ទោះការពិតនោះជាដំណឹងល្អក្តីឬអាក្រក់ក្តី វានៅតែអាចធ្វើឲ្យជនរងគ្រោះទាំងនោះទទួលបាននូវការរសាយចិត្តពីភាពមិនប្រាកដប្រជាដែលដក់ជាប់នៅក្នុងអារម្មណ៍អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដូចក្នុងករណីជនបរទេសទាំងពីររូបខាងលើស្រាប់ ។

ខ្ញុំដឹងថា ឆាំង យុ ពិតជាបានជួបប្រទះហេតុការណ៍នេះជាច្រើនលើកមកហើយ ។ យើងបានជួបករណីប្រហាក់ប្រហែលនេះជាច្រើនលើកជាច្រើនសាមកហើយនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទីនោះយើងតែងតែនិយាយថា "ការពិតនឹងធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់" ។

ការងារធំៗទាំងឡាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានលក្ខណៈប្រហាក់ប្រហែលនេះដែរ ។ ជាក់ស្តែង ការធ្វើផែនទីរណ្តៅសាកសពនៃអំពើប្រល័យពូជសាសន៍មានឥទ្ធិពលដល់ការផ្លាស់ប្តូរផ្នែកចិត្តសាស្ត្រទៅលើប្រជាជនកម្ពុជាមួយចំនួនដែលកន្លងមកមិនជឿថាខ្មែរសម្លាប់ខ្មែរគ្នាឯងដូច្នេះទេ ។ ប៉ុន្តែនៅពេលដែលប្រជាជនទាំងនោះបានឃើញរណ្តៅសាកសពរាយប៉ាយស្នេកស្នះពាសពេញផ្ទៃប្រទេសនៅក្នុងផែនទីដែលជាសញ្ញាណបញ្ជាក់អំពីការសម្លាប់រង្គាលលក្ខណៈជាប្រព័ន្ធ ពេលនោះប្រជាជនកម្ពុជានឹងទទួលស្គាល់ថានេះជាការពិតមិនខាន ។ ចំពោះការសិក្សាស្រាវជ្រាវវិញ បន្ទាប់ពីបានអានសៀវភៅមួយក្បាលសរសេរដោយ អៀ ម៉េង ទ្រី និង សឹម សុរិយ៉ា ដែលមានចំណងជើងថា "ជនរងគ្រោះឬជនដៃដល់" អ្នកអាននឹងយល់ឃើញភ្លាមថាគ្រប់ជនជាតិខ្មែរទាំងអស់សុទ្ធតែជាជនរងគ្រោះនៃរបបខ្មែរក្រហមសូម្បីតែខ្មែរក្រហមខ្លួនឯងក៏ដោយ ។ ការយល់ដឹងបែបនេះអាចធ្វើឲ្យប្រជាជនខ្មែរទាំងអស់ចាប់ផ្តើមផ្សះផ្សាគ្នាឡើងវិញ ។ ចំពោះទស្សនាវដ្តីស្វែងរកការពិតវិញនោះ ដោយសារការផ្តល់ពត៌មានពីអំពើប្រល័យពូជសាសន៍ទៅកាន់ប្រជាជនទូទៅនៅទូទាំងប្រទេស ទស្សនាវដ្តីនេះអាចពន្យល់ដោយងាយអំពីរបបខ្មែរក្រហមដោយបង្ហាញឲ្យឃើញថាខ្មែរក្រហមមិនមែនជាព្រះអាទិទេពឬជាបិសាចអ្វីទេ ។ ខ្មែរក្រហមទាំងនោះជាមនុស្សសាមញ្ញដូចគេដូចឯងអ៊ីចឹងដែរ ពោលគឺជាមនុស្សដែលប្រព្រឹត្តអំពើមិនល្អ ហើយត្រូវបានដឹកនាំទៅរកផ្លូវខុសពីសំណាក់មេដឹកនាំឆ្គួតលីលាមួយចំនួនតូច ។ ការងារផ្សេងៗទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែដំណើរការក៏មានគុណសម្បត្តិប្រហាក់ប្រហែលគ្នានេះដែរ ។

ហេតុដូចនេះ ការបង្កើតនូវប្រធានបទនេះគឺដើម្បីចង្អុលបង្ហាញឲ្យច្បាស់ថាអ្វីៗដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើគឺមានគោលបំណងនាំមកនូវ"ការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកាត់សម្គាល់" ដល់ប្រទេសកម្ពុជា និងដល់ប្រជាជនខ្មែរម្តងម្នាក់ៗ ហើយបន្តិចម្តងៗនិងនៅទីបញ្ចប់ អាចជួយសម្រួលដល់ការផ្សះផ្សាជាតិនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។ វាមិនអាចកើតឡើងក្នុងមួយប៉ព្រិចភ្នែកបានទេ ហើយក៏គ្មានវិធីណាដែលអាចផ្លាស់ប្តូរទស្សនៈរបស់ជនជាតិខ្មែរក្នុងការគិតចំពោះខ្លួនឯងនិងគិតចំពោះពិភពលោកទាំងមូលបានដែរ ។ ប៉ុន្តែតាមរយៈការបង្ហាញនូវការពិតពីអំពើប្រល័យពូជសាសន៍ គម្រោងទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីជា"គណៈកម្មាធិការស្វែងរកការពិត"មួយ ដែលទាញយកបញ្ហានេះចេញពីអ្នកនយោបាយដែលតែងតែកេងយកផលប្រយោជន៍ពីប្រជាជនដើម្បីបម្រើផលប្រយោជន៍នយោបាយរបស់ខ្លួន និងផ្តល់ដល់ប្រជាជនខ្មែរវិញនូវបំណកស្រាយមួយដែលប្រជាជនទូទៅងាយយល់និងចាប់បាន ។ បន្តិចម្តងៗ ប្រជាជនកម្ពុជាអាចទទួលស្គាល់នូវការពិតដោយស្ងប់ស្ងៀមនៅក្នុងចិត្ត ហើយនៅទីបញ្ចប់ប្រទេសកម្ពុជាទាំងមូលអាចសម្រេចបាននូវការផ្សះផ្សាជាតិដ៏"ពិតប្រាកដ"មួយ ។

**ក្រេច អិចឆេសិន**

## ការស្ទាបស្ទង់មតិអ្នកអានទស្សនាវដ្តី «ស្វែងរកការពិត» ឆ្នាំ២០០១
## ប្រធានបទ: *ការផ្សះផ្សានិងការបង្រួបបង្រួមជាតិ*

ក្រៅពីអ្នកអានទស្សនាវដ្តី«ស្វែងរកការពិត» មជ្ឈមណ្ឌលឯកសារកម្ពុជាក៏សុំយោបល់ពីសំណាក់អស់លោក លោកស្រី អ៊ំ ពូ មីង បង ប្អូន និងសិស្សានុសិស្ស ដែលមិនមែនជាអ្នកអាននិងមិនអាចអានទស្សនាវដ្តី«ស្វែងរកការពិត» ដោយសារតែអាយុនិងកាលៈទេសៈមិនអំណោយផលណាមួយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមកោតសរសើរគ្រប់ចម្លើយរបស់អស់លោក លោកស្រី អ៊ំ ពូ មីង បង ប្អូន និងសិស្សានុសិស្ស ទាក់ទងនឹងសំណួរទាំងអម្បាលមាននិងសូមថ្លែងអំណរគុណចំពោះអស់លោក លោកស្រី អ៊ំ ពូ មីង បង ប្អូន និងសិស្សានុសិស្ស ដែលបានជួយឲ្យបុគ្គលដែលគ្មានលទ្ធភាពអាចបំពេញទម្រង់ស្ទាបស្ទង់មតិនេះដោយខ្លួនឯងផ្ទាល់ ។

**សំណួរ :** **ចម្លើយ សូមគូស ☑**

១) តើលោកអ្នកយល់អំពីគោលបំណងក្នុងការបង្កើតទស្សនាវដ្តី«ស្វែងរកការពិត»ដែរឬទេ?

☐ យល់ច្បាស់

☐ មិនសូវយល់

☐ មិនយល់ទាល់តែសោះ

២) តើប្រជាជនទូទៅមានចំណាប់អារម្មណ៍យ៉ាងដូម្តេចខ្លះចំពោះទស្សនាវដ្តី«ស្វែងរកការពិត»ដែលចេញផ្សាយអស់រយៈពេលពីរឆ្នាំកន្លងមកនេះ? (សូមគូសចំណុចទាំងឡាយណាដែលលោកអ្នកយល់ថាត្រឹមត្រូវ)

☐ មានប្រយោជន៍ចំពោះប្រជាជនកម្ពុជាទូទៅ

☐ ធ្វើឲ្យប្រជាជនកម្ពុជាស្អប់អារម្មណ៍

☐ ជារឿងចាស់មិនគួររំឭកឡើងវិញ

☐ ផ្ទុកនូវព័ត៌មានសំខាន់ៗសម្រាប់អ្នកសិក្សាប្រវត្តិសាស្ត្រ ច្បាប់ វប្បធម៌និងសិល្បៈ

☐ គ្មានអ្វីសំខាន់ទាល់តែសោះ

☐ បង្ហាញពីជីវិតពិតៗរបស់ប្រជាជនកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)

☐ ជារឿងដដែលៗ ហើយកកូរកកាយ និងនាំឲ្យកើតបញ្ហាសង្គមសាជាថ្មី

☐ បង្ហាញអំពីស្មារតីផ្សះផ្សានិងបង្រួបបង្រួមជាតិ

៣) តើប្រជាជនទូទៅនៅតាមមូលដ្ឋានភូមិឃុំមានដែលជ្រាបអំពីព័ត៌មានដែលផ្សព្វផ្សាយដោយទស្សនាវដ្តី«ស្វែងរកការពិត»ដែរឬទេ?

☐ មិនដែលបានទទួលសោះកាលពីមុន

☐ អាជ្ញាធរខេត្ត-ស្រុកមិនដែលចែកជូន(ឬនិយាយអំពីទស្សនាវដ្តីនេះប្រាប់អ្នកភូមិទេ)

☐ អាជ្ញាធរមូលដ្ឋានចែកជូនប្រជាជនរៀងរាល់ខែ

☐ ឃើញម្តងម្កាលតែប៉ុណ្ណោះ

៤) ខ្លឹមសារទស្សនាវដ្តី«ស្វែងរកការពិត»បានរួមចំណែកឲ្យមានការផ្សះផ្សារបួសក្នុងសង្គមខ្មែរ

☐ ត្រឹមត្រូវ ។ ហេតុអ្វី? ........................................................................................................

.................................................................................................................................................

តើមាននៅផ្នែកណាខ្លះ? ..........................................................................................................

☐ មិនត្រឹមត្រូវ ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

៥) នៅពេលដែលបានយល់ដឹងអំពីប្រវត្តិនិងអំពើប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម តើលោកអ្នកមានគំនិតយ៉ាងដូចម្តេចខ្លះ?

☐ ខ្ញុំចង់ឲ្យតុលាការកាត់ទោសឲ្យបានឆាប់ដើម្បីជាគំរូដល់ក្មេងជំនាន់ក្រោយ

☐ ខ្ញុំចង់ឲ្យមានតុលាការ ប៉ុន្តែខ្លាចមានសង្គ្រាមនិងការច្របូកច្របល់សាជាថ្មី

☐ ខ្ញុំមិនចង់ទេ ព្រោះថ្នាក់លើមិនបានប្រព្រឹត្តខ្លួនឯងផង

☐ យោបល់ផ្សេងទៀត ។ ..........................................................................................

៦) ទស្សនាវដ្តី«ស្វែងរកការពិត» បានចុះផ្សាយប្រវត្តិសកម្មភាពអ្នកសួរចម្លើយឬកម្មាភិបាលថ្នាក់ក្រោមមួយចំនួន ។ ឆ្លងតាមសកម្មភាពនិងទង្វើទាំងអស់នេះ តើលោកអ្នកយល់ដូចម្តេចចំពោះកម្មាភិបាលប្រភេទនេះ (ជាជនដៃដល់ឬជាជនរងគ្រោះក្រោមរបបខ្មែរក្រហម?

☐ ខ្ញុំយល់ថាជាជនដៃដល់ពីព្រោះ..........................................................................................

..........................................................................................................................

☐ ខ្ញុំយល់ថាជាជនរងគ្រោះពីព្រោះ..........................................................................................

..........................................................................................................................

☐ ខ្ញុំយល់ថាជាជនដៃដល់ផងជនរងគ្រោះផង ពីព្រោះ..........................................................................................

..........................................................................................................................

៧) តើលោកអ្នកមានអារម្មណ៍ដូចម្តេចចំពោះជនដៃដល់ខ្មែរក្រហមនៅតាមមូលដ្ឋាន?

☐ អាណិត ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

☐ មិនអាណិតទេ ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

☐ មានអារម្មណ៍ក្រៅពីនេះ ។ សូមបញ្ជាក់..........................................................................................

..........................................................................................................................

៨) តើទស្សនាវដ្តី«ស្វែងរកការពិត» គួរតែលើកយកប្រធានបទអ្វីផ្សេងទៀតមកពិភាក្សាដើម្បីជួយដល់ការផ្សះផ្សានិងការបង្រួបបង្រួមជាតិ?

☐ និយាយអំពីជនដៃដល់បានហើយ ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

☐ និយាយអំពីជនរងគ្រោះបានហើយ ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

☐ និយាយអំពើទៅបានហើយ ។ ហេតុអ្វី? ..........................................................................................

..........................................................................................................................

☐ និយាយទាំងពីរចំណុចខាងលើតែម្តង ។ ហេតុអ្វី? ..................................................

..................................................

៩) នៅពេលដឹងថាអ្នកស្រុកអ្នកភូមិជាអតីតកម្មាភិបាលដែលធ្លាប់សម្លាប់បងប្អូនសាច់ញាតិ តើលោកអ្នកមានកំហឹងចង់សងសឹកដែរឬទេ?

☐ មិនចង់ទេ ។ ហេតុអ្វី? ..................................................

..................................................

☐ ត្រូវតែសងសឹក ។ ហេតុអ្វី? ..................................................

..................................................

១០) ទស្សនាវដ្តីស្វែងរកការពិតមានចុះផ្សាយរូបថតអដ្ឋិធាតុជនរងគ្រោះយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ រូបភាពបែបនេះ ÷

☐ គ្រាន់តែដើម្បីបង្ហាញពីទំហំនៃអំពើហិង្សារបស់ខ្មែរក្រហម

☐ ជាគម្រុយរឹតតែធ្វើឲ្យកំហឹងជនរងគ្រោះដែលនៅមានជីវិតពុះកញ្ជ្រោលឡើងវិញ

☐ មានចំណុចអ្វីផ្សេងទៀតទេ? ..................................................

..................................................

១១) នៅពេលដែលដឹងថា នរណាម្នាក់ជាអតីតកម្មាភិបាលសម្លាប់ឪពុកម្តាយ បងប្អូន ហើយកូនរបស់បុគ្គលនោះនៅរៀនសាលាជាមួយកូនរបស់លោកអ្នកដែរ តើលោកអ្នកមានដែលបញ្ឆេះកូនរបស់ខ្លួនឲ្យរើសអើងនិងមិនឲ្យនិយាយចូលជាមួយកូនរបស់ជនដៃដល់ទាំងនោះដែរឬទេ?

☐ ត្រូវតែបណ្តុះកំហឹងនិងរើសអើងជានិច្ច ។

☐ ខ្ញុំមិនចង់ធ្វើចងកម្មចងពៀរទេ ព្រោះពេលធំដឹងក្តីឡើងកូនជនដៃដល់នឹងសងសឹកមកលើកូនចៅរបស់ខ្ញុំវិញមិនខាន ។

☐ មានអ្វីផ្សេងទៀត? ..................................................

..................................................

១២) តើមានមធ្យោបាយអ្វីខ្លះក្នុងការផ្សព្វផ្សាយប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែទូលំទូលាយ?

☐ តាមរយៈប្រព័ន្ធឃោសនា សារព័ត៌មាន វិទ្យុ និងទូរទស្សន៍ ជាដើម

☐ តាមរយៈទីភ្នាក់ងាររដ្ឋាភិបាលតាមខេត្ត-ក្រុង

☐ តាមរយៈទីភ្នាក់ងារឯកជននានាដូចជាអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សជាដើម

☐ ចុះផ្សព្វផ្សាយតាមមូលដ្ឋានតាមរយៈសាលារៀន

១៣) ទស្សនាវដ្តី«ស្វែងរកការពិត» ចែកចេញជា៥ផ្នែក គឺផ្នែកឯកសារ ផ្នែកប្រវត្តិសាស្ត្រ ផ្នែកច្បាប់ ផ្នែកវេទិកាសាធារណៈ និងទំព័រស្រាវជ្រាវរកគ្រួសារ ។ តើសិស្សានុសិស្សនៅតាមវិទ្យាល័យឬអនុវិទ្យាល័យខេត្ត-ក្រុង គួរតែទទួលការអប់រំក្រៅប្រពន្ធ័ស្តីអំពីខ្លឹមសារទស្សនាវដ្តី«ស្វែងរកការពិត»ដែរឬទេ?

☐ គួរទទួល ហេតុអ្វី? ..................................................

..................................................

☐ មិនគួរទទួល ហេតុអ្វី..................................................

..................................................

១៤) ទស្សនាវដ្តី«ស្វែងរកការពិត»មានតួនាទីអ្វីខ្លះនៅពេលនិងក្រោយពេលមានតុលាការ? (សូមជ្រើសរើសយកចំណុចណាដែលលោកអ្នកយល់ថាសមស្រប) ។

☐ ជាសំឡេងរបស់ជនរងគ្រោះនិងជនដៃដល់

☐ ជាប្រភពឯកសារផ្នែកច្បាប់ និងពត៌មានទាក់ទងនឹងដំណើការវិនិច្ឆ័យក្តី

☐ ជាអាជ្ញាកណ្តាលសម្រាប់សម្របសម្រួល

☐ ជាស្ពានឆ្លងទៅរកការផ្សះផ្សានិងបង្រួបបង្រួមជាតិ

១៥) សូមឲ្យយោបល់របស់លោកអ្នកដែលទាក់ទងនឹងការបង្កើតគំនិតផ្សះផ្សានិងបង្រួបបង្រួមជាតិ ។ តើពាក្យផ្សះផ្សារនិងការបង្រួបបង្រួមជាតិមានន័យយ៉ាងដូចម្តេច? តើធ្វើដូចម្តេចទើបសម្រេចបាននូវគោលគំនិតនេះ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

(លោកអ្នកអាចសរសេរលើក្រដាសបន្ថែមប្រសិនបើចាំបាច់ក្នុងការឆ្លើយសំណួរទាំង១៥ខាងលើនេះ) ។

សូមបំពេញពត៌មានរួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខៈ១១១០ ភ្នំពេញ ។

ទូរស័ព្ទលេខៈ(៨៥៥)២៣-២១១៨៧៥ ឬ ទូរសារលេខៈ(៨៥៥)២៣-២១០៣៥៨ ។





អ្នកសួរចម្លើយ ម៉ុល មន

# អង្គការសហប្រជាជាតិចាំបាច់ត្រូវតែក្រឡេកមើលប្រវត្តិរបស់ខ្លួនជាមួយកម្ពុជា

ចាប់តាំងពីថ្ងៃដែលអ្នកជំនាញការច្បាប់អង្គការសហប្រជាជាតិចេញអនុសាសន៍ក្នុងឆ្នាំ១៩៩៩ គឺជាការច្បាស់ណាស់ដែលថា អង្គការសហប្រជាជាតិមានការព្រួយបារម្ភទៅលើកេរ្តិ៍ឈ្មោះរបស់អង្គការខ្លួនចំពោះ "ភាពត្រឹមត្រូវ" ជាជាងព្រួយបារម្ភទៅលើការឈានទៅដល់ការសម្របសម្រួលការងារដែលអាចបានត្រួសត្រាយផ្លូវទៅកាន់ការជំនុំជម្រះក្តីជាអន្តរជាតិ ។ ជាអកុសល អសមត្ថភាពរបស់អង្គការសហប្រជាជាតិក្នុងការ សម្រេចការងារច្បាប់និយមហួសហេតុ


តុលាការកាត់ទោសខ្មែរក្រហមឆ្នាំ១៩៧៩

អស់រយៈពេល៤ឆ្នាំកន្លះបានឈានដល់ទីបញ្ចប់ ហើយមិនខុសគ្នាទៅនឹងកិច្ចខិតខំប្រឹងប្រែងកាលពីពេលមុនៗរបស់អង្គការនេះនៅក្នុងប្រទេសកម្ពុជាទេ ។ តើអង្គការសហប្រជាជាតិភ្លេចប្រវត្តិរបស់ខ្លួនហើយឬនៅ? អង្គការសហប្រជាជាតិបានទទួលស្គាល់ខ្មែរក្រហមពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។ នេះមិននិយាយដល់ការដែលមិនបានលើកឡើងនូវឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសផង ដែលនាំដល់ការកាន់កាប់ និងការរៀបចំបោះឆ្នោតនៅឆ្នាំ១៩៩៣ ។ ដោយសារការពន្យារពេលកិច្ចចរចាកាន់តែវែងឆ្ងាយទៅៗ ជោគជ័យធំមួយអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា គឺថាអង្គការសហប្រជាជាតិធ្វើឲ្យមានការពិភាក្សាទៅលើឧក្រិដ្ឋកម្មសង្គ្រាមរបស់ខ្មែរក្រហម ។

សព្វថ្ងៃនេះ អំពើឃោរឃៅដ៏គួរឲ្យព្រឺព្រួចដែលបញ្ជាឲ្យប្រព្រឹត្តដោយបុគ្គលដែលអាចជាក្លាយចុងចោទនាថ្ងៃខាងមុខ ដូចជា ឌុច និងការឲ្យហេតុផលដ៏គួរឲ្យចង់សើចរបស់មេដឹកនាំរបស់គេ ដែលបានលុបលើដោយចំណុចមួយចំនួនដែលបណ្តាលមកពីភាពទាល់ច្រកដោយសារច្បាប់និយមហួសហេតុ។ បើតាមខ្ញុំ ខ្ញុំសុខចិត្តឲ្យសិទ្ធិរបស់ចុងចោទទាំងនេះ (ឌុច និង ម៉ុក) ត្រូវបានរំលោភ ជាជាងធ្វើទារុណកម្មផ្លូវចិត្តទៅលើជនរងគ្រោះតាមរយៈការដោះលែងជនសង្ស័យឧក្រិដ្ឋសង្គ្រាមឲ្យមានសេរីភាព ដោយផ្អែកលើបច្ចេកទេសភាព ។ តើពិភពលោកមានប្រតិកម្មយ៉ាងដូចម្តេច ប្រសិនបើសម្ព័ន្ធមិត្តដោះលែងមេបញ្ជាការនៅទីក្រុង អ៊ូស៊ីត ឈ្មោះ រូដុលហួស ដោយផ្អែកលើបច្ចេកទេសភាពនោះ?

**ភីតធ័រ ម៉ាខ្វាយ**

*ប្រលោមលោកបដិវត្តខ្មែរក្រហមៈ*

# ពលិកម្មម៉ែៗយើង

***(តពីលេខមុន)***

រដូវវស្សចូលមកដល់ ។ ពេលមួយ យើងកំពុងស្ទូងដកស្ទូងៗពេញស្រែ ស្រាប់តែឮសំឡេងឡានមកឈប់នៅមុខស្រែតាយុត ។ យើងងាកមើលទៅទាំងអស់គ្នាឃើញមនុស្សម្នាក់ចុះពីលើឡានពាក់អាវពណ៌ឆើត ស្លៀកខោពណ៌សផ្ទត់ត្រង់ភ្លីង ពាក់ស្បែកជើងឃ្មុបពណ៌ក្រហមក្រម៉ៅយ៉ាងរលោង ថែមទាំងដក់ខ្សៀមួយផង ។ ក្រោយបុរសនេះមានយុវជនម្នាក់កាន់កាតាបស្បែកដើរតាម ហើយសំដែងអាការៈគ្រុនៗនៅពេលបុរសដក់ខ្សៀនោះងាកទៅរកម្តងៗ ។ លើសពីនេះ ឃើញប៉ូលិសពីរនាក់ហែហមឆ្វេងស្តាំ ។ វាឈប់នៅឆ្ងាយពីពួកយើង ។ បន្តិចមកឃើញអាប៉ូលិសម្នាក់ហៅយើងឲ្យឡើងពីស្រែទាំងអស់គ្នាព្រោះលោកចៅហ្វាយស្រុកថ្មីអញ្ជើញមកចង់និយាយការជាមួយបន្តិច ។ យើងទាំងអស់គ្នាក៏ឡើងពីភក់ដើរសំដៅទៅឡានវា ។ នៅប្រហែលជា៥-៦ម៉ែត្រដល់ឡានវា ស្រាប់តែអានេះវាបក់ដៃជាសញ្ញាឲ្យយើងថយក្រោយវិញ ហើយវាញើសខ្យល់ច្រមុះវាធ្វើ ហ៊ុះ!ហ៊ុះ! ។ អាប៉ូលិសម្នាក់ដឹងចិត្តចៅហ្វាយវាក៏ស្រែកសន្ធាប់ដាក់យើងថា “កុំទៅជិតលោកពេក ក្លិនពួកឯងរាល់គ្នាមិនល្អទេ ជះខ្យល់ទៅលើលោក” ។ ខ្ញុំឮពុកនិងម៉ែរអ៊ូតិចៗថា “ញើសឈាមអ្នកក្រថោកដល់ម៉្លឹងនំ!” ។

អាចៅហ្វាយស្រុកថ្មីចាប់សួរចម្លើយពួកយើងខ្ញុំថា ពួឯងមីងឯងបានច្បាប់ពីណាមកធ្វើស្រែលើដីនេះ?

តាយុតឆ្លើយថា យើងខ្ញុំជួលដីលោក ឈួន ធ្វើទាំងអស់លោកយកឈ្នួលដីក្នុងមួយរដូវ១០០ថាំង ។

លោក ឈួន គាត់ទទួលខុសត្រូវតែខាងទាហានទេ ។ ចំណែកយើង យើងទទួលខុសត្រូវខាងស៊ីវិល ។ បើពួឯងចង់ធ្វើស្រែលើដីក្នុងស្រុកនេះ ត្រូវទៅសុំច្បាប់នៅឯសាលាស្រុកបង់ពន្ធដារជូនរដ្ឋត្រឹមត្រូវទើបមានសិទ្ធិធ្វើស្រែលើដីនេះបាន ។ និយាយឲ្យខ្លី ពួកឯងត្រូវគោរពច្បាប់ផ្នែករដ្ឋបាលថែមទៀត ។ ពូ ណាម គាត់ជ្រួញចិញ្ចើម ហើយសួរទៅអាដក់ខ្សៀនោះថា “ស្អីទៅច្បាប់រដ្ឋបាលអីគេនោះលោក?” កាលវានិយាយដំបូងវាឥតមើលមុខពួកយើងទេ ដល់ឮពូណាមសួរដូច្នេះវាក៏ងាកមករកម្ចាស់សំណួរ ហើយបើកភ្នែកក្រឡោតៗដាក់ ។

យី!ពួកនេះល្ងង់ខ្លៅមែនតែម្តង! អត់ស្គាល់ច្បាប់ទម្លាប់ស្អីនឹងគេសោះ ។ នែ!អញប្រាប់ឲ្យដឹងទៅ នៅម៉ារក្រោមមេឃលើដីនេះស្រុកណាក៏មានច្បាប់ទម្លាប់ទាំងអស់ ។ ពួកដែលរស់នៅគ្មានច្បាប់ គឺពួកស្វានៅក្នុងព្រៃឯណោះ ។ យើងមកធ្វើការនៅទីនេះគឺមកធ្វើឲ្យមានរបៀបរៀបរយ ។ ដូច្នេះ ចាប់តាំងពីថ្ងៃនេះតទៅពួកឯងត្រូវទៅបង់ពន្ធដារតាមច្បាប់កំណត់នៅសាលាស្រុកឲ្យបានគ្រប់ៗគ្នា ។ យើងមកប្រាប់តែប៉ុណ្ណេះទេ ។ និយាយចប់ ពួកវាឡើងឡានទៅវិញអស់ ។ ដល់អាចៅហ្វាយស្រុកទៅបាត់ អ្នកភូមិទាំងអស់ក៏លែងមានកម្លាំងធ្វើការតទៅទៀត ។ បងប្អូនជំនុំគ្នាសម្តែងការក្តៅក្រហាយឈឺចាប់យ៉ាងខ្លាំង ។ តាយុត ឈរឡើងក្តាប់ដៃយ៉ាងណែន ហើយនិយាយខ្លាំងៗថា “ពួកវាធ្វើនេះគឺធ្វើមិនឲ្យយើងរស់កើតតែម្តង!” “គ្រាន់តែអាឈួនមួយ ពួកយើងស្ទើរស្លាប់ស្ទើររស់ទៅហើយ ឥឡូវថែមអាដក់ខ្សៀមួយទៀត ប្រាកដជាពួកយើងត្រូវដាច់ខ្យល់ស្លាប់តែម្តងមិនខាន” ។

◆◆◆

យប់ជ្រៅបន្តិចទៅហើយ ។ ខ្ញុំដេកលក់តាំងពីក្បាលព្រលប់ ។ តែក្រោយបន្តិចមក ពេលខ្ញុំផ្ងារខ្លួនស្រាប់តែឮសំឡេងពុកនិយាយ រអ៊ុះៗ ។ ខ្ញុំបើកភ្នែកឡើងឃើញ ពុកម៉ែ តាយុត អ៊ីណាម និងមនុស្សម្នាក់មិនស្គាល់មុខ អង្គុយជំនុំគ្នា ។ គេជំនុំពី

រឿងអីទាំងកណ្តាលយប់ដូច្នេះ? ខ្ញុំខំប្រឹងផ្ទៀងត្រចៀកស្តាប់ដែរតែពួសួរពុំសូវច្បាស់ ពុំដឹងនិយាយពីរឿងអី ។ នេះមកពីខ្ញុំដេកឆ្ងាយពេក គឺនៅជិតបន្ទ្រានបាយឯណោះ ។ គេជំនុំគ្នាដោយឥតអុចចង្កៀងឡើយ ។ លុះយូរបន្តិច ឃើញបងខ្ញុំឡើងមកខ្សឹបប្រាប់អ្នកជំនុំ ។ មនុស្សចម្លែកក៏បញ្ចប់ការពិភាក្សា ហើយចាប់ដៃលាទាំងអស់គ្នាចុះទៅវិញបាត់កណ្តាលយប់ស្ងាត់ ។ ព្រឹកឡើងស្រាប់តែឃើញប្រជាជនភូមិខ្ញុំកាន់ដំបង ពូថៅ កាំបិត ខ្វេវ ដំបងព្រនង់ នាំគ្នាមកជុំនៅកណ្តាលភូមិ ហើយស្រែកខ្លាំងៗថា «ទៅសាលាស្រុក! ទៅសាលាស្រុក! ប្រគល់ដីយើងមកយើងវិញ! ប្រគល់ដីយើងមកយើងវិញ!» ។

ខ្ញុំឃើញម៉ែរត់ខ្វេងដៃខ្វេងជើងដើម្បីពន្យល់ អ៊ំសន មីងគ្រប់ មីងភួង មីងឡុំ មីងរ៉េន ឲ្យចូលរួម ក្នុងការហែក្បួនតវ៉ានេះ ។ បន្តិចមក មនុស្សក្នុងភូមិក៏មកជួបជុំគ្នាមីរដេរដាសទាំងក្មេងទាំងចាស់ចេញដំណើរទៅសាលាស្រុក ។ ទៅដល់មុខសាលាស្រុក ខ្ញុំឃើញ តាខឿន ពូត្រា អ៊ំព្រីង និងបងប្អូនយើងមួយចំនួនទៀតចាំនៅទីនោះស្រេច ។ គេពួតែសំឡេងស្រែកប្រឆាំងនឹងពន្ធដារទាមទារដីមកវិញ សម្រែកស្រែកហៅ អាឈួន និង អាផុន ចៅហ្វាយស្រុកឲ្យមកជួប លាន់កងរំពងពីគ្រប់ទិស ។ ខ្ញុំខំរកមើលអាសក្តិ៤ និងអាជក់ខ្សៀដែរ តែរកមើលវាពុំឃើញសោះ ។ បងប្អូននិយាយថា ពួកវាដឹងពត៌មានមុន ក៏ឡើងឡានរត់ទៅប៉ៃលិនបាត់អស់ ។

(នៅមានត)

# លិខិតថ្លែងអំណរគុណ

នាយក បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិតភាសាបទេសទាំងអស់

**គោរពជូន**

លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកនាយកជាទីរាប់អាន!

តាងនាមបុគ្គលិក សាស្ត្រាចារ្យ និស្សិត និងអ្នកអានអ្នកស្រាវជ្រាវរបស់បណ្ណាល័យវិទ្យាស្ថានភាសាបរទេសទាំងអស់ សូមសម្តែងនូវសេចក្តីអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអំណោយទស្សនាវដ្តី «ស្វែងរកការពិត» ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ដល់បណ្ណាល័យទុកជាឯកសារសិក្សាស្រាវជ្រាវ ។

ទស្សនាវដ្តី «ស្វែងរកការពិត» ពិតជាឯកសារមួយដ៏មានលក្ខណៈជាប្រវត្តិសាស្ត្រដែលកូនខ្មែរទាំងអស់ត្រូវតែចងចាំ ។ និស្សិតសិក្សានៅទីនេះភាគច្រើនជានិស្សិតដែលកើតក្រោយរបបប្រល័យពូជសាសន៍ ។ អ្វីៗទាំងអស់ដែលកើតក្នុងរបបប្រល័យពូជសាសន៍ ពិតជាមិនបានដឹងឡើយ គ្រាន់តែឮគេនិយាយ ។ ដោយសារទស្សនាវដ្តី«ស្វែងរកការពិត»នេះពិតជាធ្វើឲ្យប្អូនៗនិស្សិតទាំងអស់ដែលបានអានកើតក្តីរន្ធត់ឥតឧបមាសង្វេគ អាណិតអាសូរ ។

ជាថ្មីម្តងទៀត ខ្ញុំសូមគោរពសរសើរដល់លោកប្រធាន និងសហការីដែលពិតជាកុលបុត្រខ្មែរដ៏ឆ្នើមខិតខំអស់កម្លាំងកាយចិត្តទោះជាប្រឈមមុននឹងការលំបាកបែបណាក៏ដោយ ក៏ការស្រាវជ្រាវបង្កើតនូវទស្សនាវដ្តី«ស្វែងរកការពិត»នេះឡើងដើម្បីជាឯកសារដល់កូនខ្មែរជំនាន់ក្រោយចងចាំមិនឲ្យបំភ្លេច ។ ដោយឡែក យើងខ្ញុំជាបុគ្គលិកមម្រើការនៅបណ្ណាល័យវិទ្យាស្ថានភាសាបរទេស នឹងខិតខំរក្សាឯកសារដ៏មានសារប្រយោជន៍នេះឲ្យបានយូរអង្វែងសម្រាប់ការស្រាវជ្រាវរបស់ប្អូនៗជំនាន់ក្រោយ ដែលកន្លងមកឯកសារប្រភេទនេះនៅបណ្ណាល័យយើងខ្ញុំគ្មានសោះជាភាសាខ្មែរ ។

សូមឲ្យទស្សនាវដ្តី «ស្វែងរកការពិត» ក្លាយជាប្រទីបរកការពិតដល់សង្គមខ្មែរ និងជួយរកយុត្តិធម៌ដល់ជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ ។

សូមជូនពរថ្លៃថ្លាមហាប្រសើរដល់លោកប្រធាននិងសហការី ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានអំពីយើងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១

តំណាងថ្នាក់ដឹកនាំ បុគ្គលិកនិងសាស្ត្រាចារ្យវិទ្យាស្ថានភាសាបរទេស ។

**បណ្ឌិត ម៉ៅ សុភ្ភន**

កំណាព្យ

# កងទ័ពបដិវត្តន៍ប្រយុទ្ធបង្កបង្កើនផល រួមដោះស្រាយជីវភាពប្រជាជន

កងទ័ពបដិវត្តន៍កម្ពុជា សីលធម៌រាបសានិងទន់ភ្លន់ ស្មោះត្រង់បម្រើប្រជាជន អំណត់អត់ធន់គ្រប់វេលា ។

ម៉ឺងម៉ាត់ដាច់ខាតចំពោះខ្មាំង ឈានមុខតតាំងច្បាំងគ្មានរា រំដោះមាតុភូមិជាទីស្នេហា រំដោះប្រជាផុតទុក្ខភ័យ ។

ឃើញជាតិទើបចេញពីសង្គ្រាម មិត្តជាសាច់ឈាមអ្នកក្រីក្រ មិនព្រមសម្រាកបានមួយថ្ងៃ ស្មោះស្ម័គ្រស្មើដៃបង្កើនផល ។

ប្រជាជនខ្វះខាតមិត្តឈឺចាប់ រួសរាន់ប្រញាប់ចិត្តខ្វាយខ្វល់ យាមផងដាំផងយកភោគផល បានច្រើនជូនដល់ប្រជាជន ។

ដើមវស្សាឆ្នាំនេះមិត្តសម្រុក តាមភូមិឃុំស្រុកនិងតំបន់ ភ្ជួររាស់សាបស្ទូងជាបន្ទាន់ បានស្រែយ៉ាងច្រើនទាំងថ្មីចាស់ ។

ដោយរៀបចំភ្លឺនិងទំនប់ មានដីរទឹកគ្រប់ធានាច្បាស់ ស្រូវសាយត្រណោតលាស់រហ័ស បែកគុម្ពខៀវស្រស់គួរពេញចិត្ត ។

ស្រែនេះមិត្តជូនទៅសហករណ៍ រួចមិត្តបន្តរួមផលិត ក្នុងភូមិសហករណ៍ជាប់ជិតស្និទ្ធ សាបដកស្ទូងពិតទាន់រដូវ ។

នេះហើយកងទ័ពបដិវត្តន៍ សីលធម៌ប្រយុទ្ធក្រហមឆ្អៅ ដឹងសុខដឹងទុក្ខត្រជាក់ក្តៅ បម្រើម៉ែឪប្រជាជន ។

ក្រៅពីមិត្តបានរួមការងារ ជាមួយមីងមាយាយតាដូន មិត្តរំលែករបបពីបងប្អូន ដោះស្រាយបន្ទាន់ជីវភាព ។

រដូវចម្រូតចូលមកដល់ ស្រូវយើងហុចផលខ្ពស់មានប្រៀប លើឆ្នាំមុនៗមករៀងរាប មិត្តអររំភើបសោមនស្សក្រៃ ។

ចាត់តាំងកម្លាំងច្រូតបែនបោក ប្រមូលផលទុកញាប់ដើងដៃ តាមភូមិសហករណ៍យ៉ាងសប្បាយ ក្នុងស្រែជិតឆ្ងាយឲ្យរួចឆាប់ ។

នឹងអាលមិត្តចុះចូលប្រឡូក កាប់បារកាយចូកបុកបង្ហាប់ ធ្វើប្រព័ន្ធភ្លឺថ្មីជាលំដាប់ ពូនខ្ពស់ត្រង់ជាប់ជូនប្រជា ។

ដើម្បីបងប្អូនរឹតម្ចាស់ការ លើប្រាំងវស្សាបានធានា ផលស្រូវឡើងខ្ពស់រស់ធូរធារ ៣តោន១ហិកតាដល់ទិសដៅ ។

ប្រជាជនយើងរីករាយណាស់ បានកក់ក្តៅច្បាស់ព្រោះកូនចៅ កងទ័ពសាច់ឈាមដ៏ជ្រាលជ្រៅ សីលធម៌សន្ធៅយ៉ាងខ្ជាប់ខ្ជួន ។

មានមោទនភាពខ្ពស់បំផុត ប្តេជ្ញាប្រយុទ្ធសំរុកផ្ទួន បង្កើនផលឧបត្ថម្ភខ្លួន រួមផ្សំនឹងកូនសាងជាតិយើង ។

យើងខ្ញុំកងទ័ពសូមប្តេជ្ញា ថែទាំរក្សាខ្លួនឲ្យថ្កើន ជាកងទ័ពបដិវត្តដ៏រុងរឿង រាបសាមិនឆ្មើងជាប់ជានិច្ច ។

ទុកការបម្រើប្រជាជន ជ្រួតជ្រាបក្នុងខ្លួនជាភារកិច្ច ឧត្តុងឧត្តមខំសម្រេច បានល្អជានិច្ចរៀងរហូត ។

**ខែកុម្ភៈ ឆ្នាំ១៩៧៦**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the truth. Number 26, February 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.